ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ប្រព័ន្ធសុខាភិបាលដែលរើសអើងចំពោះប្រជាជនក្រីក្រ
- ការបំផ្លាញភស្តុតាងដោយអចេតនា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៨២ ខែកុម្ភៈ ឆ្នាំ២០១៥

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៨២ ខែកុម្ភៈ ឆ្នាំ២០១៥

## មាតិកា

◆ប្រព័ន្ធសុខាភិបាលដែលរើសអើងចំពោះប្រជាជនក្រីក្រ ........................ ១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាព ទី ស្រ៊ិន ហៅ មុត ពិធីការ ................................ ៤

◆ ត្រូវវាយសម្រុកខ្មាំងក្លាបំផុត និងជាប់ជានិច្ច ................................ ៨

◆ ចម្លើយសារភាពរបស់ អ៊ឹម ខន ប្រធានរោងចក្រ ........................ ១៣

◆ មីឆែលស្កុត ឌីដ ភ្នាក់ងារសម្ងាត់ សេ.អ៊ី.អា ................................ ២០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ មន្ទីរសន្តិសុខខ្មុំរចាស់ ................................................ ២៣

◆ អដ្ឋិធាតុនៅមានព្រលឹង ................................................ ២៨

◆ ចាប់ពីរបបខ្មែរក្រហមដល់ខប្បត្តិហេតុ ហាំបាលី ........................ ៣០

**ផ្នែកច្បាប់**

◆ តើការធ្វើពហិការមិនចូលរួមសវនាការរបស់ក្រុម ........................ ៣៦

**វេទិកាពិភាក្សាសាធារណៈ**

◆ ការផ្ដល់វិធានការការពារចំពោះសាក្សីផ្ដល់ ................................ ៣៩

◆ ការបំផ្លាញភ័ស្តុតាងដោយអចេតនា ........................................ ៤១

◆ ប្រព័ន្ធសុខាភិបាលដែលតម្រូវឲ្យមានឆន្ទៈ ................................ ៤៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ខ្សែជីវិតរបស់លោកយាយខ្ញុំក្នុងសម័យ ................................ ៤៦

◆ មានទោសព្រោះអ្វី ........................................................ ៤៨

◆ ដំណើរភៀសខ្លួនឆ្លងដែនពីរបប ................................................ ៥៣



សម្ដេចព្រះមហាអរិយវង្ស សៅរ៍ ចន្ទថុល ប្រោសទឹកលើអដ្ឋិធាតុរបស់សពកញ្ញា កែវ កុលធីតា ឯកស័ក ដែលបានធ្វើមរណកាល នៅថ្ងៃ១៩ ខែមករា ឆ្នាំ២០១៥

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** ម៉ែន ពិចិត្រ, ដុំ ម៉ាប់, ស៊ាង ចិន្ដា, ហ៊ុយ សម្ភស្ស, អេង កុកថាយ, លឹម ជ័យទត្ត, ឌេមុ៉ូស្សិន ស៊ី.វេយើស, សុខ ជីវ័ន្ត, ជូ សូភា, ជា សីហា **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ទាវ សារៈមុនិន្ទ, ឌី សុជាតា **អ្នកបកប្រែ ៖** សាយ សូលីដា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ ៖** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ ៖** ឆេង វេីង និង សន ល័ក្ខ Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ប្រព័ន្ធសុខាភិបាលដែលរើសអើងចំពោះប្រជាជនក្រីក្រ

នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៥ សភាពេញអង្គរបស់អង្គការសហប្រជាជាតិបានអនុម័តិកំណត់យកថ្ងៃទី២៧ ខែមករា ជាទិវានៃការចងចាំជាអន្តរជាតិស្តីពីការសម្លាប់រង្គាលនៅអឺរ៉ុប (Holocaust) ។ ទិវានៃការចងចាំនេះ មានសារសំខាន់ណាស់ព្រោះថា វាមិនត្រឹមតែផ្តល់កិត្តិយសដល់ជនរងគ្រោះនៅអឺរ៉ុបតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានក្រើនរំឭក និងបង្កើនការយកចិត្តទុកដាក់ពីសហគមន៍អន្តរជាតិក្នុងការប្តេជ្ញាចិត្តថា អំពើព្រៃផ្សៃប្រហាក់ប្រហែលគ្នានេះនឹងមិនអាចបំភ្លេចបានជារៀងរហូត ។

ទោះជាសហគមន៍អន្តរជាតិមានការតាំងចិត្តបែបនេះក្តី យើងគួរមានមនសិការគិតត្រង់ចំណុចថា ការទទួលស្គាល់ដែលមានរយៈពេលតែមួយថ្ងៃបែបនេះ មិនស្មើទៅនឹងការផ្តល់សេចក្តីគោរពពេញមួយជីវិតទេ ហើយសេចក្តីស្មោះត្រង់តាមរយៈកាយវិការមិនអាចយកមកជំនួសនូវសកម្មភាពជាក់ស្តែងបានឡើយ ។ យើងត្រូវប្រាកដថា សេចក្តីចង់បាននៃគោលការណ៍មនុស្សធម៌របស់យើងអាចបកស្រាយថាជាសេចក្តីមេត្តាករុណាដ៏ស្មោះត្រង់សម្រាប់មនុស្សជាតិគ្រប់រូប ។ សេចក្តីតាំងចិត្តរបស់យើងក្នុងការចងចាំរឿងរ៉ាវពីអតីតកាលត្រូវបានវាស់វែងមិនមែនតាមរយៈការទទួលស្គាល់ដ៏សោកគ្រោះបែបនេះឡើយ ប៉ុន្តែតាមរយៈការពេញចិត្តរបស់យើងចំពោះរឿងរ៉ាវរបស់មនុស្សគ្រប់រូប ។

ក្នុងស្មារតីនេះ នាឱកាសទិវាប្រវត្តិសាស្ត្រនេះ ខ្ញុំសូមលើករឿងមួយមកនិយាយ ដែលជារឿងផ្ទាល់ខ្លួនរបស់ក្រុមគ្រួសារខ្ញុំ ប៉ុន្តែរឿងរ៉ាវនេះតំណាងឲ្យការតស៊ូមួយដែលប្រជាជនកម្ពុជាជាច្រើនកំពុងប្រឈមមុខនាពេលបច្ចុប្បន្ន ។

នាសប្តាហ៍មុន បងស្រីរបស់ខ្ញុំឈ្មោះ កែវ កុលធីតា ឯកស័ក បានទទួលមរណភាពក្រោយពីបានព្យាយាមជម្នះនឹងជំងឺមហារីកអស់រយៈពេលជាច្រើនឆ្នាំ ។ បងស្រីខ្ញុំកើតក្នុងឆ្នាំ១៩៥៩ នៅទីក្រុងភ្នំពេញ ។ ម្តាយរបស់ខ្ញុំឈ្មោះ កែវ ណាន មានអាយុ៨៦ឆ្នាំ ។ បងស្រីរបស់ខ្ញុំ គឺជាមនុស្សគថ្លង់ពីកំណើត ។ គាត់ជាកូនស្រីពៅគេបង្អស់ក្នុងចំណោមបងស្រីប្រាំនាក់ ។ គាត់មានអាយុខុសគ្នាជាមួយខ្ញុំតែពីរឆ្នាំប៉ុណ្ណោះ ហេតុដូច្នេះ គាត់ និងខ្ញុំហាក់បីដូចជាមិត្តជិតស្និទ្ធនឹងគ្នា ។ ដោយសារតែគាត់មិនអាចទំនាក់ទំនងជាមួយមនុស្សទូទៅបាន លើកលែងតែមនុស្សមួយចំនួនតូចដែលចេះភាសាកាយវិការមនុស្សគ គាត់តែងតែធ្វើកិច្ចការអ្វីៗដោយខ្លួនឯង ហើយមានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះដែលមានការអត់ធ្មត់ ចង់ស្គាល់ និងស្វែងយល់ពីអារម្មណ៍របស់គាត់ ។ ប៉ុន្តែ ទោះបីជាគាត់ស្ថិតក្នុងកាលៈទេសៈបែបនេះក្តី គាត់ជាមនុស្សម្នាក់ដែលមានស្មារតី និងបុគ្គលិកលក្ខណៈរឹងមាំដែលផ្តល់ជាពន្លឺដ៏ថ្លៃថ្លានៅក្នុងគ្រួសារ ។

នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចក្នុងឆ្នាំ១៩៧៥ បងស្រីខ្ញុំ ហើយនិងខ្ញុំក៏ព្រាត់ប្រាស់គ្នា ហើយមិនដែលបានជួបមុខគ្នាទេ ។ យើងជួបជុំគ្នាឡើងវិញក្រោយរបបខ្មែរក្រហម ប៉ុន្តែយើងទាំងពីរនាក់បានភ្លេចភាសាកាយវិការដែលយើងធ្លាប់ប្រើសម្រាប់ទំនាក់ទំនងគ្នាកាលពីក្មេង ។ អស់រយៈពេលជាច្រើនឆ្នាំក្រោយមក យើងក៏មិនសូវមានទំនាក់ទំនងជាមួយគ្នាច្រើនដែរ ។ ទើបតែឆ្នាំចុងក្រោយនេះដែលខ្ញុំបានចំណាយពេលវេលាជាច្រើននៅជាមួយគាត់ ។ នៅពេលដែលយើងទាំងពីរនៅជាមួយគ្នា យើងសន្ទនាគ្នាអំពីការស្លាប់និងការបាត់ខ្លួនសមាជិកគ្រួសារជាទីស្រឡាញ់របស់យើង ហើយគាត់បានរៀបរាប់ពីជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហម និងក្រោយរបបនេះ ដែលគាត់ជាអ្នកគំនូរម្នាក់ ។ គាត់គូររូបផ្សេងៗឲ្យក្មេងៗសិស្សសាលា ។ ក្មេងទាំងអស់នោះ តែងបរិច្ចាគប្រាក់បន្តិចបន្តួចមកគាត់ដែលគាត់បានសន្សំម្តងបន្តិចៗ ហើយទិញបានក្រវិលមួយគូ ដែលក្រោយមក ក្រវិលមួយចំហៀងរបស់គាត់ត្រូវបានអ្នកជិតខាងលួចយកទៅ ។

ដូចប្រជាជនកម្ពុជាជាច្រើននាក់ផ្សេងទៀតក្នុងអំឡុងរបបខ្មែរក្រហមដែរ គាត់ត្រូវកម្មាភិបាលខ្មែរក្រហមចាត់តាំងឲ្យធ្វើស្រែដាំបន្លែ និងកាប់ឆ្ការព្រៃ ។ បងស្រីខ្ញុំខិតខំត្រដររស់ដោយវេទនាតាមរយៈស្មារតីសម្បជញ្ញៈរបស់គាត់ជាមនុស្សគ ។ នៅពេលដែលគាត់ឃ្លានខ្លាំង គាត់បានដើររើសស្លឹកឈើ និងសត្វល្អិតនានាហូបជាអាហារ ។ បទពិសោធន៍របស់គាត់ធ្វើឲ្យខ្ញុំស្ងើចសរសើរ ហើយនឹក

ស្មានមិនដល់ ។ ជាមួយគ្នានោះដែរ នៅពេលដែលខ្ញុំដឹងពីបទពិសោធន៍រឿងរ៉ាវជីវិតរបស់គាត់ ខ្ញុំមានអារម្មណ៍ក្តុកក្តួល រំជួលចិត្តយ៉ាងខ្លាំងដោយសារ ស្មារតីរបស់គាត់លើសពីអ្វីដែលអាចពិពណ៌នាបាន និងប្រាជ្ញា ស្មារតីរបស់គាត់ក្នុងភាពជាមនុស្សគប្ចង់តស៊ូសុិតស្វាញ ដើម្បីជីវិតរស់ពីរបបឃោរឃៅខ្មែរក្រហម ។

ពេល វេលា ដែល ខ្ញុំ នៅជាមួយ គាត់ នាដំណាក់កាលចុងក្រោយនៃជីវិតរបស់គាត់ មានន័យយ៉ាងខ្លាំងចំពោះខ្ញុំ ។ នាថ្ងៃចុងក្រោយនៃជីវិតរបស់គាត់ ខ្ញុំបែរបន់គ្រប់យ៉ាងសូមឲ្យមានអព្ភូតហេតុកើតឡើងដើម្បីឲ្យសុខភាពរបស់គាត់បានប្រសើរឡើង ។

ប៉ុន្តែ ដូចប្រជាជនកម្ពុជាផ្សេងទៀតដែរដែលទទួលរងនូវបញ្ហាសុខភាពធ្ងន់ធ្ងរ បងស្រីខ្ញុំបានពើបប្រទះនូវការព្យាបាលសុខភាពពីប្រព័ន្ធសុខាភិបាលដែលទន់ខ្សោយ ដែលខ្វះការអនុវត្តឲ្យមានប្រសិទ្ធភាព និងភាពខ្វះក្រមសីលធម៌ វិជ្ជាជីវៈ បច្ចេកទេស និងវិធីសាស្ត្រដែលមានភាពចាស់គំរិល ។ ខ្ញុំបានចំណាយពេលជាច្រើនយប់ ច្រើនថ្ងៃដើម្បីតាមសង្កេត និងត្រួតពិនិត្យមើលការព្យាបាលរបស់បងស្រីខ្ញុំ ។ ពេលខ្លះ ខ្ញុំបានដាស់បុគ្គលិកមន្ទីរពេទ្យជាច្រើនសារនៅពេលយប់ដើម្បីធានាថា បងស្រីខ្ញុំត្រូវមានការថែទាំដិតដល់ ។ ដោយខ្វះខាតនូវការលើកទឹកចិត្ត ចំពោះការងារ និងកង្វះនូវការទទួលខុសត្រូវរបស់ខ្លួនក្នុងការថែរក្សាអ្នកជំងឺ បុគ្គលិកពេទ្យតែងតែព្រងើយកន្តើយចំពោះភារកិច្ចរបស់ខ្លួន ជាពិសេស ចំពោះអ្នកជំងឺណាដែលក្រីក្រខ្វះខាត ។ នៅប្រទេសដែលមានប្រព័ន្ធសុខាភិបាលទំនើប សុខុមាលភាពរបស់អ្នកជំងឺត្រូវបានយកចិត្តទុកដាក់ជាខ្លាំង ។ ចំណែកឯនៅប្រទេសកម្ពុជាវិញ ប្រសិនជាគ្មានការផ្តល់លុយកាក់ និងការផ្តល់ប្រាក់បន្ថែមនោះទេ នឹងមិនអាចធានាអំពីគុណភាពនៃការព្យាបាលបានឡើយ ។ ប្រព័ន្ធសុខាភិបាលបែបនេះធ្វើឲ្យអ្នកក្រកាន់តែដុនដាបទៅៗ ហើយជះឥទ្ធិពលអាក្រក់ដល់មនុស្សមួយជំនាន់ដែលធ្លាប់ទទួលរងនូវការឈឺចាប់យ៉ាងក្រៃលែងដើម្បីស្តារប្រទេសជាតិឡើងវិញក្រោយរបបខ្មែរក្រហម ។

បងស្រីរបស់ខ្ញុំទទួលមរណភាពចុងក្រោយ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ វេលាម៉ោង៨ៈ៤០នាទីយប់ ប៉ុន្តែគាត់មិន



កែវ កុលធីតា ឯកសារ ថតនៅទសវត្សរ៍ឆ្នាំ៨០

បានលាចាកលោក ដោយមិនបានមានៈនឹងសេចក្ដីស្លាប់នោះទេ ។ មុននេះមួយអាទិត្យ គឺនៅថ្ងៃទី១៣ ខែមករា វេលាម៉ោង៨ៈ៤០ នាទីព្រឹក គាត់ត្រូវបានវេជ្ជបណ្ឌិតប្រកាសថាស្លាប់ហើយ ។ សញ្ញាណដែលអាចបញ្ជាក់ថាអាចមានជីវិតឈប់ដំណើរការហើយ ហើយគាត់គ្មានជីវិតរស់ទៀតទេ ។ វេជ្ជបណ្ឌិតជាច្រើននាក់បានប្រាប់ខ្ញុំថា បងស្រីខ្ញុំស្លាប់ហើយ ។ ប្រសិនជាយើងគ្មានគំនិតផ្ទុយពីវេជ្ជបណ្ឌិតទេនោះ បងស្រីរបស់ខ្ញុំប្រាកដជានឹងត្រូវបានបូជាទាំងមានជីវិតរស់នៅឡើយ ។ ដោយសារវេជ្ជបណ្ឌិតប្រាប់ដូច្នេះ គ្រួសារយើងបានយកបងស្រីខ្ញុំទាំងក្ដីសោកសង្រេងទៅកាន់វត្តលង្កា ។ គ្រួសារយើងទាំងអស់គ្នាមិនបានបូជាបងស្រីខ្ញុំទេ ប៉ុន្តែយើងសុំឲ្យព្រះសង្ឃជាច្រើនអង្គសូត្រធម៌ជូនគាត់ ។ យើងបែរបន់ហើយបែរបន់ទៀត ។ ព្រះសង្ឃបានសូត្រធម៌ និងដុតធូប ។ យើងទាំងអស់គ្នាបែរបន់នៅក្បែរសាកសពបងស្រីខ្ញុំអស់រយៈពេលជាច្រើនម៉ោង ។ រំពេចមួយនោះ ព្រះសង្ឃនាម ផាន់ ចាន់តារា បានសង្កេតឃើញទឹកភ្នែកស្រក់នៅលើថ្ពាល់ខាងស្ដាំរបស់បងស្រីខ្ញុំ ។ បងស្រីខ្ញុំចាប់ផ្ដើមកម្រើកដៃទាំងពីររបស់គាត់ ហើយចាប់ផ្ដើមបើកភ្នែក ។ ពេលនោះ ខ្ញុំចាប់ផ្ដើមបង្ហាញគំនូរអំពីជីវិតរបស់គាត់ ដែលគាត់បានគូរសម្រាប់អ្នកស្រាវជ្រាវជនជាតិអាមេរិកាំងគង់ថ្ងម្នាក់ឈ្មោះ អេរីន ម៉ូរីយ៉ាទី ហារ៉េលសាន់ ។ បើសិនជាមានអព្ភូតហេតុពិតមែននោះ ថ្ងៃនោះគឺជាអព្ភូតហេតុជាក់ស្ដែងតែម្ដង ។ ព្រះអង្គ សម្ដេចព្រះមហាអរិយវង្សសៅរ៍ ចន្ទថុល្ល ក៏គង់នៅទីនោះដែរ ។

បងស្រីខ្ញុំបន្តមានជីវិតបានមួយសប្ដាហ៍ទៀត ។ ក្រោយពីគាត់ដឹងខ្លួនវិញ គាត់បានប្រាប់យើងពីមនុស្សដែលគាត់បានជួបនៅក្នុងក្ដីស្រមៃដែលគាត់បានស្គាល់ពីអតីតកាល ហើយអ្នកទាំងនោះបានស្លាប់កាលពីរបបខ្មែរក្រហម ។ គាត់បានជួបឪពុករបស់ខ្ញុំ បងស្រីខ្ញុំ និងអ្នកជិតខាងខ្ញុំដែលអ្នកទាំងអស់នោះបានស្លាប់កាលពីរបបខ្មែរក្រហមអស់ទៅហើយ ។

បងស្រីខ្ញុំមានជីវិតឡើងវិញ និងមានសុខភាពប្រសើរបានមួយសប្ដាហ៍ទៀត តែអកុសលបេះដូងរបស់គាត់ចាប់ផ្ដើមគាំង ហើយទទួលមរណភាពនៅថ្ងៃទី១៩ ខែមករា ។

ខ្ញុំគួរតែធ្វើអ្វីៗច្រើនជាងនេះដើម្បីជួយបងស្រីខ្ញុំឲ្យធូរស្រាលដូចគ្នាទៅនឹងកិច្ចការជាច្រើនទៀតដែលខ្ញុំគួរតែធ្វើដើម្បីបុព្វហេតុសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម ។ រហូតមកដល់ថ្ងៃនេះ កម្ពុជានៅបន្តប្រឹងប្រែងតស៊ូជាមួយនឹងរបបនេះនៅឡើយ ។ ខណៈពេលដែលយើងកំពុងលើកកម្ពស់ និងចាត់ទុកបញ្ហានយោបាយ ការអប់រំ និងសាសនា ជាវិស័យចម្បងដែលត្រូវដោះស្រាយក្រោយពីវិស័យទាំងនេះទទួលរងនូវផលប៉ះពាល់យ៉ាងខ្លាំងពីរបបខ្មែរក្រហម យើងក៏គួរយកចិត្តទុកដាក់ដល់ប្រព័ន្ធសុខាភិបាលដែរ ដែលទទួលស្លាកស្នាមកេរដំណែលពីរបបខ្មែរក្រហមដូចគ្នា ។

ខណៈពេលដែលសង្គមយើងទាំងអស់គ្នា កំពុងខិតខំលើកកម្ពស់ប្រព័ន្ធសុខាភិបាលរបស់ខ្លួននោះ ខ្ញុំមិនចាត់ទុកថា កាលៈទេសៈ និងរឿងរ៉ាវរបស់បងស្រីខ្ញុំជារឿងខុសគេ និងពិសេសនោះទេ ។ បើសិនជាយើងមិនបានជួយ និងគាំទ្រគាត់ដែលអង្វរចង់បានការថែទាំ និងការយកចិត្តទុកដាក់មកលើសុខភាពរបស់គាត់ ព្រមទាំងជម្រើសផ្សេងក្នុងការផ្ដល់ការព្យាបាលបន្ថែមចំពោះលក្ខខណ្ឌរបស់គាត់ ខ្ញុំចោទជាសំណួរថា តើគាត់អាចរស់បានរយៈពេលប៉ុណ្ណាទៀត? ហើយសំណួរមួយទៀតគឺ តើប្រជាជនក្រីក្រប៉ុន្មានពាន់នាក់ដែលត្រូវបានវេជ្ជបណ្ឌិតប្រកាសថា ស្លាប់ហើយយកទៅបូជាដែលអាចនៅមានជីវិតនៅឡើយ? ការមិនយកចិត្តទុកដាក់ ឬការព្រងើយកន្តើយដោយគំរោះគំរើយចំពោះជនក្រីក្រ ឬការប្រកាន់បក្សពួកដោយផ្ដល់ការព្យាបាលតាមរយៈការទាមទារឲ្យបង់ប្រាក់ បានបង្កឲ្យមានភាពឈឺចាប់ និងវេទនារម្មណ៍ជ្រាលជ្រៅជាងភាពរំខាន ភាពអសមត្ថភាព ឬភាពខ្ជិលច្រអូសទៅទៀត ។ ស្នាមដាននៃរបបឃោរឃៅខ្មែរក្រហមតែងតែដក់ជាប់នៅក្នុងការយល់ដឹង សម្មានចិត្ត និងក្ដីបារម្ភរបស់យើង ដែលយើងមានចំពោះមនុស្សជាតិរបស់យើងទាំងពេលទំនាក់ទំនងជាមួយគ្នាធម្មតា និងសេវាកម្មផ្សេងៗ ដែលយើងបានផ្ដល់ចំពោះមនុស្សជាតិ ។ ចំពោះបញ្ហានេះ កម្ពុជានៅមានកិច្ចការច្រើនទៀតដែលត្រូវបំពេញ ។

ដោយហេតុនេះ ការទទួលស្គាល់ជនរងគ្រោះមិនមែនចាប់ផ្ដើម និងបញ្ចប់ទៅវិញក្នុងមួយថ្ងៃនោះទេ ។ តែយើងត្រូវកំណត់ទិវានេះជាកាយវិការនិមិត្តរូបមួយដែលបង្ហាញថា ការទទួលខុសត្រូវរបស់យើងនឹងមិនត្រូវបានបំភ្លេចចោលទេ ហើយជាមួយគ្នានោះដែរ យើងត្រូវធ្វើកិច្ចការបន្ថែមទៀត ។

**ឆាំង យុ**

# ចម្លើយសារភាព ទី ស្រិន ហៅ មុត ពិធីការក្រសួងការបរទេស របបកម្ពុជាប្រជាធិបតេយ្យ

ទី ស្រិន ហៅ មុត កើតនៅភូមិកន្ទែងចក ឃុំមៀន ស្រុកអូររាំងឪ តំបន់២២ ។ ឪពុករបស់ មុត ឈ្មោះ អ៊ី ទី និងម្តាយឈ្មោះ មុច ។ មុត បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៥៧ ។ នៅឆ្នាំ១៩៦១ មុត បានផ្លាស់ទៅចូលរួមជាមួយខ្មែរសេរី ដែលមានភារកិច្ចកសាងកម្លាំងបង្កប់ និងឃោសនានៅតំបន់២២ ដើម្បីវាយប្រហារខ្មែរក្រហម ។ ចាប់ពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៥ មុត បានក្តាប់យោធាតំបន់២២ ដោយបានបំផុសយុទ្ធជនឲ្យរត់ចោលសមរភូមិ បង្ខំប្រជាជនឲ្យធ្វើការងារធ្ងន់ ព្រមទាំងបង្អត់អាហារប្រជាជនក្នុងគោលបំណងធ្វើឲ្យខូចនយោបាយរបស់ខ្មែរក្រហម ។ នៅខែកក្កដា ឆ្នាំ១៩៧៥ មុត បានសហការជាមួយ ភឹម ដើម្បីរៀបចំផែនការរដ្ឋប្រហារនៅតំបន់២២ ដោយធ្វើការបំផ្លិចបំផ្លាញសេដ្ឋកិច្ចរបស់ខ្មែរក្រហម ដូចជា ស្រូវ អង្ករ និងសម្ភារផ្សេងៗជាដើម ។ នៅឆ្នាំ១៩៧៧ មុត បានផ្លាស់ទៅធ្វើជាពិធីការនៅក្នុងក្រសួងការបរទេស ហើយនៅឆ្នាំដដែល មុត ត្រូវបានអង្គការខ្មែរក្រហមចាប់ខ្លួននៅអាយុ៣៦ឆ្នាំ ។

មុត ត្រូវបានឈ្មោះ អុន និង លី ជាអ្នកសួរចម្លើយ ។ អុន និង លី បានធ្វើការសង្កេតទៅលើចម្លើយសារភាពរបស់ មុត ដោយបញ្ជាក់ថា មុត ពុំបាននិយាយរៀបរាប់អស់ពីសកម្មភាពក្បត់បដិវត្តន៍របស់ខ្លួននៅឡើយទេ ។ មុត មិនបានបញ្ជាក់អំពីខ្សែទាក់ទងរបស់ខ្លួននៅក្រៅតំបន់របស់ខ្លួននោះទេ ។ ជាងនេះទៅទៀត



ឧបករណ៍ធ្វើទារុណកម្មអ្នកទោស ដែលត្រូវបានប្រើប្រាស់ដោយឆ្មាំគុកនៃមន្ទីរស-២១ ឬគុកទួលស្លែង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

នៅក្នុងចម្លើយសារភាពរបស់ មុត សំដីរបស់ មុត បានឆ្លើយខុសពីសម្តីរបស់អ្នកទោសផ្សេងទៀតដែលអង្គការចាប់ខ្លួន និងសួរចម្លើយ ។ ជាក់ស្តែង អុន និង លី បានលើកឡើងនៅក្នុងការសង្កេតរបស់ខ្លួនទៅលើចម្លើយសារភាពរបស់ មុត ថា មុត បានលាក់ និងមិនឯកភាពជាមួយចម្លើយសារភាពរបស់អ្នកទោសដទៃ អំពីសមាសភាពចូលរួមប្រជុំចាត់តាំងគណៈតំបន់២២ថ្មីនៅខែមិថុនា ឆ្នាំ១៩៧៥ ។ មុត មិនបានឯកភាពជាមួយនឹងចម្លើយរបស់ ផុន និង សំបុក ទៅលើសមាសភាពចូលរួមប្រជុំ និងខ្លឹមសារប្រជុំអំពីផែនការធ្វើរដ្ឋប្រហារនៅស្រុកមុខកំពូលទេ ។ មិនតែប៉ុណ្ណោះ ចម្លើយរបស់ មុត ផ្ទុយនឹងការលើកឡើងរបស់ ផុន ដែលថា មុត បានចាត់តាំងឲ្យ សយ ទាក់ទងជាមួយគាត់ (ផុន) និង ថោង ខឿន ដោយផ្ទាល់ ។

ខាងក្រោមគឺជាសកម្មភាពដែល មុត បានរៀបរាប់នៅក្នុងចម្លើយសារភាពរបស់ខ្លួន សួរដោយ អុន និង លី ដែលបានចារថា "សម្ងាត់បំផុត" ៖

## សកម្មភាពរបស់ មុត មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

នៅឆ្នាំ១៩៥៧ មុត បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមតាមរយៈ ស៊ាង ហ៊ី ។ នៅឆ្នាំ១៩៦០ មុត បានទៅទាក់ទង និងធ្វើការជាមួយ កុល ដែលជាសេនាធិការភូមិភាគ បន្ទាប់ពី ស៊ាង ហ៊ី ស្ថិតនៅក្រោមការតាមដាន ។ ដំបូង កុល បានអប់រំ មុត អំពីរឿងបដិវត្តន៍ ។ ប៉ុន្តែមិនយូរប៉ុន្មាន នៅឆ្នាំ១៩៦១ កុល បានអូសទាញ មុត ដោយសម្ងាត់ឲ្យចូលបម្រើចលនាខ្មែរសេរីវិញ ។ កុល បានប្រាប់ មុត ថា នៅថ្ងៃអនាគតរបបលោកសេរីនឹងយកឈ្នះលើរបបកុម្មុយនីស្ត ។ បន្ទាប់ពីសម្រេចចិត្តបម្រើចលនាសេរី កុល បានចាត់តាំងឲ្យ មុត ឃោសនាប្រឆាំងនឹងឥទ្ធិពលបដិវត្តន៍ ដោយចំហរ និងដោយសម្ងាត់ ព្រមទាំងណែនាំ មុត ឲ្យខិតខំកសាងកម្លាំងបង្កប់ក្នុងជួរបដិវត្តន៍ និងធ្វើជានីរសារបស់គាត់ (កុល) ។ ចាប់តាំងពីឆ្នាំ១៩៦១ ដល់ឆ្នាំ១៩៦៨ មុត កសាងកម្លាំងបាន៣នាក់ រួមមាន សេន ហៅ ចៅ សឿង (លេខាស្រុកអូររាំងឪ) ,លឹម (នៅសហករណ៍ភូមិបឹងកាន ឃុំប្រធាតុ ស្រុកអូររាំងឪ) និង សៀន (ទទួលខុសត្រូវផ្នែកយោធាពិការតំបន់២២) ។

នៅឆ្នាំ១៩៦៤ កុល បានខទ្ទសនាម មុត ឲ្យទាក់ទងជាមួយ ចាន់ ដែលជាអនុភាគ និងលេខាតំបន់២១ នៅពេលដែល កុល ត្រូវបានផ្លាស់ទៅតំបន់២០ ។ នៅឆ្នាំ១៩៦៦ កុល បានផ្លាស់មកតំបន់២២វិញ នៅពេលនោះ កុល បានណែនាំ មុត ឲ្យស្គាល់ និងធ្វើការជាមួយ ទុំ ។ នៅចុងឆ្នាំ ១៩៦៦ ទុំ បានបញ្ចូល មុត ឲ្យចូលបម្រើ សេ.អ៊ី.អា ។ នៅចន្លោះឆ្នាំ១៩៦៦ ដល់ឆ្នាំ១៩៧០ មុត កសាងបានកម្លាំង សេ.អ៊ី.អា ថ្មីចំនួនពីររូប រួមមាន សៅ សាម៉ន (សន្តិសុខតំបន់២២) និង អ៊ិន គណៈវរសេនាធំ១២៤ (តំបន់២២) ។ នៅក្នុងអំឡុងពេលនោះ មុត មាននាទីជាកងទ័ពបដិវត្តន៍តំបន់២២ ដោយធ្វើការផ្ទាល់ជាមួយ ទុំ ដែល ទុំ បានចាត់តាំងឲ្យ មុត ទាក់ទងជាមួយ ឌឹម (កងពល១៦៤), ផុន (នៅមុខកំពូល), ពេជ នៅក្នុងកងវរៈសេនាធំ១២៤ (តំបន់២២), ជន ហៅ លី (ស្លាប់), ជៃ (នៅកោះសូទិន), ធិន អតីតលេខាស្រុកអូររាំងឪ (ស្លាប់), សាយ (មកពីសង្គមកិច្ចតំបន់២២) ។

នៅក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧២ មុត មាននាទីជាលេខាស្រុកកោះសូទិន ក្រោមការចាត់តាំងរបស់ ទុំ ។ បន្ទាប់មក មុត បានអូសទាញ យោន ឲ្យមកធ្វើការជាជំនួយការស្រុកកោះសូទិន ។ នៅចន្លោះឆ្នាំ១៩៧០ និងឆ្នាំ១៩៧២ មុត សម្រេចបានសកម្មភាពមួយចំនួនដូចជា ៖ បើកដៃឲ្យប្រជាជនចេញចូលទាក់ទងតំបន់របស់ខ្មាំង, ផ្លាស់ប្តូរសេដ្ឋកិច្ចជាមួយខ្មាំងដើម្បីបង្កឲ្យមានភាពច្របូកច្របល់, ផ្សព្វផ្សាយឥទ្ធិពលនៅក្នុងតំបន់រំដោះ, បំភិតបំភ័យប្រជាជន, ធ្វើឲ្យប្រជាជនបាត់បង់ភាពជឿជាក់ទៅលើបដិវត្តន៍តាមរយៈការគាបសង្កត់ប្រជាជន, ព្រមទាំងអូសទាញបានកម្លាំងថ្មីចំនួនពីររូបបន្ថែម រួមមាន ឈន់ (សមាជិកស្រុកកោះសូទិន) និង ឈាន (ទូតនៅប្រទេសវៀតណាម) ។ ជាសរុប នៅចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧២ សមាសភាព សេ.អ៊ី.អា នៅស្រុកកោះសូទិនមានចំនួន៦នាក់ រួមមាន មុត (ក្តាប់រួម), ជៃ (ក្តាប់ខាងសេដ្ឋកិច្ច), ឈាន (ក្តាប់ខាងឃោសនាអប់រំ), ឈន់ (ក្តាប់ផ្ទាល់តាមមូលដ្ឋាន), ចៅ សឿង (ក្តាប់ខាងយោធា), យោន (ក្តាប់ខាងឃោសនាអប់រំតាមមូលដ្ឋាន) ។

នៅចុងឆ្នាំ១៩៧២ មុត ត្រូវបាន ទុំ ផ្លាស់ពីស្រុកកោះសូទិន ឲ្យមកក្តាប់យោធាតំបន់២២វិញ ក្នុងគោលបំណងអូសទាញកម្លាំង

នៅក្នុងយោធាតំបន់២២ ដើម្បីអនុវត្តសកម្មភាពបំផ្លាញបដិវត្តន៍ នៅតាមសមរភូមិ និងសម្ភារសឹករបស់បដិវត្តន៍ ។ នៅចន្លោះពីចុងឆ្នាំ១៩៧២ ដល់ដើមឆ្នាំ១៩៧៥ មុត បានអនុវត្តសកម្មភាពមួយចំនួនដូចតទៅ៖

នៅសមរភូមិ មុត មិនបានអប់រំណែនាំយោធានោះទេ ។ មុត បានបណ្តែតបណ្តោយឲ្យយោធាបាញ់ប្រោះដោយសេរី ។ នៅពេលដែលវាយឈ្នះតាមសមរភូមិ មុត ហាមយោធារបស់ខ្លួនមិនឲ្យប្រមូលគ្រាប់រំសេវមកទុក ដោយយកលេសថា អង្គការមិនខ្វះគ្រឿងសព្វាវុធនោះទេ ។ ជាងនេះទៅទៀត មុត មិនបានយកចិត្តទុកដាក់ថែរក្សាអាវុធសម្រាប់ប្រយុទ្ធឡើយ ។ មិនតែប៉ុណ្ណោះ មុត បានចូលរួមបំផ្លាញផែនការរបស់បក្សក្នុងការវាយប្រហារនៅសមរភូមិព្រែកតាមាក់ និងព្រែកហ្លួងទៀត ។ ជាក់ស្តែង មុត បានឃោសនាឲ្យកងទ័ពដែលនៅក្រោមបង្គាប់របស់ខ្លួនបង្វែរដៃឲ្យខ្ពាំង និងណែនាំ សាគី ឲ្យបាញ់កាំភ្លើងធំខុសគោលដៅក្នុងគោលបំណងបំផ្លាញគ្រាប់របស់អង្គការ ។ ដើម្បីអូសបន្លាយការធ្វើសង្គ្រាម មុត បានបំបាក់ស្មារតីរបស់យុទ្ធជនដោយលើកឡើងអំពីការស្លាប់ ការរបួស ពិការភាព ការអត់ឃ្លាននៅតាមសមរភូមិ ។ ជាលទ្ធផល យុទ្ធជនមួយចំនួនបានរត់ថយក្រោយ ជាពិសេសនៅឆ្នាំ១៩៧៤ នៅពេលដែលសង្គ្រាមកំពុងតែឆាបឆេះកាន់តែខ្លាំង ។

នៅខែមករា ឆ្នាំ១៩៧៥ មុត ត្រូវបានផ្លាស់ទៅសមរភូមិក្រោយ ដែលនៅទីនោះ មុត បានបំផុសប្រជាជនឲ្យច្របូកច្របល់ដោយបានលើកឡើងថា បដិវត្តន៍នឹងមិនអាចឈ្នះនោះទេ កម្លាំងខ្មែរសខ្លាំង ព្រមទាំងបានបំផុសឲ្យមានជម្លោះរវាងស្រុកនឹងស្រុកទៀត ។ នៅខែមេសា ឆ្នាំ១៩៧៥ មុត បានអនុវត្តជួយនឹងបញ្ជារបស់អង្គការដោយបានជ្រើសរើសជនដែលមានប្រវត្តិពាក់ព័ន្ធនឹងខ្មាំងមកបម្រើបដិវត្តន៍ រួមមាន ស្រាន់ (មកក្តាប់ខាងវប្បធម៌ តំបន់២២), នារី សារ៉ាត ជានារីមូលដ្ឋាន (ស្រុកអូររាំងឪ), ដាវ ជាលេខាសង្កាត់ឫស្សីជ្រោយ ស្រុកមុខកំពូល (តំបន់២២), បួន (នៅមូលដ្ឋានស្រុកល្វាឯម) ។

**សកម្មភាពរបស់ មុត ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ រហូតដល់ការចាប់ខ្លួននៅឆ្នាំ១៩៧៧**

បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មុត និង ទុំ បានបន្តសកម្មភាពបំផុសបំផុលនៅតាមស្រុកភូមិនានា ។ ជាក់ស្តែង នៅស្រុកខ្សាច់កណ្តាល មុត ណែនាំឲ្យ សួន និង ដាន់ បង្កភាពច្របូលច្របល់ដូចជាការបែងចែកស្បៀងដល់ប្រជាជនមិនស្មើគ្នា មិនបើកថ្នាំឲ្យប្រជាជនដែលមានជំងឺ ។ គោលគឺធ្វើឲ្យប្រជាជនយល់ឃើញថាអង្គការមិនបានអើពើនឹងបញ្ហារបស់ប្រជាជននោះទេ ។ មុត ក៏បានណែនាំ យោន, សែ នៅស្រុកល្វាឯម និង ផុន, ជាង, ដាន់ នៅស្រុកមុខកំពូល បង្កសកម្មភាពដូចនៅស្រុកខ្សាច់កណ្តាល ។

នៅខែមិថុនា ឆ្នាំ១៩៧៥ នៅពេលប្រជុំចាត់តាំងគណៈតំបន់២២ថ្មីនៅស្រុកអូររាំងឪ មុត ត្រូវបានចាត់តាំងជាលេខាតំបន់២២ និង សំបុក ជាអនុលេខា ។ ចំណែកឯ ម៉ិត, យោន, សាយ និង ឆន ត្រូវបានចាត់តាំងជាសមាជិក ។ រឹង ដៃ និង ធិន ត្រូវបានចាត់តាំងជាសមាជិកត្រៀម ។

មួយថ្ងៃបន្ទាប់ពីការប្រជុំខាងលើ មុត ត្រូវបានភឹម ហៅទៅប្រជុំនៅស្រុកអូររាំងឪ ជាមួយសមាជិកដទៃទៀតរួមមាន យោន, ចៅ សឿង, ម៉ិត និង ឆន ។ កិច្ចប្រជុំនោះបានលើកឡើងអំពីការបន្តបំផុសទំនាស់ និងបង្កកំហឹងនៅក្នុងកម្លាំងប្រជាជនអំពីការធ្វើការធ្ងន់ ភាពតឹងតែងរបស់អង្គការ ព្រមទាំងបន្តពង្រឹង និងអូសទាញកម្លាំងប្រឆាំងនឹងបដិវត្តន៍បន្ថែមដើម្បីដណ្តើមអំណាចពីបដិវត្តន៍ ។

នៅខែកក្កដា ឆ្នាំ១៩៧៥ មុត បានណែនាំ ម៉ិត, ដាន់, ដួច, ជឿន, ចៅ សឿង, ឆន, សឿន, យោន ឲ្យបង្អត់អាហារប្រជាជន ។ នៅខែសីហា ឆ្នាំដដែល ម៉ុន បានហៅ មុត ទៅព្រៃវែង ដើម្បីរៀបចំធ្វើរដ្ឋប្រហារនៅស្រុកមុខកំពូល ។ មុត បានរៀបចំប្រជុំមួយជាមួយបក្ខពួករបស់ខ្លួននៅមន្ទីរព្រែកតាមាក់ បន្ទាប់ពីទទួលបញ្ជាពីម៉ុន ។ សមាជិកនៅក្នុងអង្គប្រជុំនោះមានដូចជា ទុំ, ផុន, ម៉ិត, យោន, ដួច, ឆន ។ ទុំ គឺជាប្រធានអង្គប្រជុំនៅពេលនោះ ។ ខ្លឹមសារនៅក្នុងអង្គប្រជុំរួមមាន ការពិនិត្យមើលសភាពការណ៍ទៅលើកម្លាំងរបស់បក្ស និងកម្លាំងក្បត់ ។ ទុំ បានលើកឡើងថា បច្ចុប្បន្ន អង្គការក្តាប់រដ្ឋអំណាចមិនគ្រប់ជ្រុងជ្រោយនោះទេ ។ បើចង់ធ្វើរដ្ឋប្រហារត្រូវតែប្រញាប់ បើពុំនោះទេ អង្គការអាចនឹង

ក្តាប់ជាប់ និងដោះស្រាយជីវភាពជូនប្រជាជន ។ បើដូច្នេះមែន ប្រជាជននឹងមិនចុះចូលជាមួយកម្លាំងរបស់ខ្លួនឡើយ ។ ទន្ទឹមនឹងនោះដែរ ទុំ បានពិនិត្យមើលអំពីកម្លាំងក្បត់របស់ខ្លួននៅតាមស្រុកតំបន់ និងនៅក្នុងជួរកងទ័ព ដើម្បីត្រៀមធ្វើរដ្ឋប្រហារនៅខែកញ្ញា ឬខែតុលាខាងមុខនេះ ។ បន្ទាប់ពីបិទអង្គប្រជុំ មុត បានណែនាំ ផុន, ជាង, មិត, ឆន ឲ្យដើរបំផុសកម្លាំងបន្ថែម និងបង្កចលាចលនៅក្នុងភូមិ ។ ប៉ុន្តែ ផែនការធ្វើរដ្ឋប្រហារនៅខែតុលា ឆ្នាំ១៩៧៥ មិនត្រូវបានអនុវត្តនោះទេ ដោយសារតែ មុត ត្រូវបានអង្គការហៅមករៀននៅស្តាតអូឡាំពិក នៅទីក្រុងភ្នំពេញ ។

នៅខែតុលា ឆ្នាំ១៩៧៥ ចាន់ បានមកមន្ទីរព្រែកតាមាក់ និងបានចាត់តាំងឲ្យ មុត កោះហៅបក្ខពួកមកប្រជុំរួមមាន ទុំ, ផុន, មិត, យោន, ដួច, ដៃ, ឆន, ពេជ និង ស៊ឹម ដើម្បីពិនិត្យមើលអំពីជីវភាពខ្វះខាតរបស់ប្រជាជននៅតំបន់២២ ស្រុកមុខកំពូល ស្រុកខ្សាច់កណ្តាល និងស្រុកល្វាឯម ព្រមទាំងរៀបចំផែនការរដ្ឋប្រហារម្តងទៀតនៅយប់ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ដែលទាមទារឲ្យអង្គការដោះស្រាយបញ្ហាកង្វះស្បៀង ។ រដ្ឋប្រហារនៅពេលនោះ ទុំ ជាប្រធាន, ផុន ជាអនុប្រធាន, មុត ជាអ្នកអនុវត្តផ្ទាល់ ។ មិនតែប៉ុណ្ណោះ មុត បានចាត់តាំង សយ ឲ្យទាក់ទងជាមួយ កុល សារឿន និង កែ ឈាង ចូលរួមសហការ ។ ប៉ុន្តែ រដ្ឋប្រហារ ឬបាតុកម្មនេះត្រូវបានរំលាយវិញនៅយប់ថ្ងៃទី២៣ ខែវិច្ឆិកា ដោយសារតែកម្លាំងមិនគ្រប់គ្រាន់ ។ នៅថ្ងៃទី២៤ ទុំ បានធ្វើដំណើរទៅតំបន់២២ ដើម្បីរៀបចំកងទ័ព ។ នៅថ្ងៃទី២៥ ទុំ បានប្រជុំជាមួយ មុត, ផុន, តាំង ដើម្បីពិនិត្យទៅលើផែនការរដ្ឋប្រហារ និងការផ្លាស់ប្តូរកម្លាំងមួយចំនួនដែលត្រូវបានអង្គការចាប់ ។ នៅថ្ងៃទី២៦ ចាន់ បានមកចូលរួមប្រជុំជាមួយ ម៉ុន, មុត, ទុំ នៅព្រែកតាមាក់ ដើម្បីរៀបចំក្រុមកាំភ្លើង កាំបិត ពូថៅ និងក្រុមដៃទទេ ដែលមាន កុល សារឿន និង កែ ឈាង ជាអ្នកដឹកនាំ ដើម្បីដោះស្រាយជាមួយអង្គការ និងប្រជាជន ។ មិនតែប៉ុណ្ណោះ ចាន់ បានណែនាំឲ្យសមាជិកខ្លួនបន្តលាក់សមាសភាពរបស់ខ្លួន ជៀសវាងអង្គការស៊ើបដឹង ។ នៅថ្ងៃទី៣០ មុត បានហៅសមាជិករបស់ខ្លួនរួមមានផុន, មិត, យោន, ដួច, ដៃ, ឆន, ចៅ សឿង, ពេជ, សាម៉ន, សំបុក មកប្រជុំរៀបចំ និងពង្រឹងកម្លាំងបន្ថែមនៅតាមស្រុក និងបញ្ជាឲ្យដកកម្លាំងរបស់អង្គការទៅធ្វើការនៅសហករណ៍វិញ ។ នៅក្នុងនោះដែរ មុត កសាងកម្លាំងបានបីនាក់បន្ថែម រួមមាន ផាន លេខាអនុសេនាធំខាងជនពិការ (តំបន់២២), ធី លេខាអនុសេនាធំខាងឡពាង (តំបន់២២), ឆេង ហាង លេខាអនុសេនាធំនៃវរៈសេនាធំ១២៤ (តំបន់២២) ។ អ្នកទាំងបីត្រូវបានចាត់តាំងឲ្យកសាងកម្លាំងបន្ថែមនៅក្នុងកងអនុសេនាធំ ដោយរាយការណ៍ទៅឲ្យ ចៅ សៀន ។

នៅឆ្នាំ១៩៧៦ មុត មិនបានដោះស្រាយបញ្ហាជីវភាពរបស់ប្រជាជននោះទេ ។ មិនតែ ប៉ុណ្ណោះ ដើម្បីប្រឆាំងនឹងអង្គការ មុត បានបញ្ជាឲ្យធ្វើសកម្មភាពបំផ្លាញស្រូវ ចាត់តាំងប្រជាជនធ្វើការច្រើនម៉ោង ។ ពោលគឺ ធ្វើយ៉ាងណាឲ្យប្រជាជនស្អប់អង្គការ ។ នៅខែមិថុនា ឆ្នាំ១៩៧៦ ឈាន ត្រូវបានចាត់តាំងជាលេខាតំបន់២២, មុត ជាអនុប្រធានទីមួយ និង សំបុក ជាអនុប្រធានទីពីរ ។ មុត ត្រូវបាន ចាន់ ណែនាំឲ្យធ្វើការជាមួយ ឈាន ដែលជាលេខាតំបន់ថ្មី ។ មុត បានណែនាំ ឈាន ឲ្យស្គាល់កម្លាំងសេ.អ៊ី.អា នៅតំបន់២២ ដើម្បីងាយស្រួលអនុវត្តផែនការរបស់ខ្លួន ។ នៅខែសីហា ឆ្នាំ១៩៧៦ មុត បានហៅលេខាស្រុកមកប្រជុំនៅព្រែកពោធិ៍ រួមមាន ឈាន, យោន, ផុន, មិត, សំបុក, ដួច, ដៃ, ចៅ សឿង, ឆន, ពេជ និង សាម៉ន អំពីការកសាងកម្លាំង សេ.អ៊ី.អា បន្ថែម និងបន្តបំផុសទំនាស់ពីស្រុកមួយទៅស្រុកមួយទៀត ។ មុត បានចាត់តាំង យុត, ជឹម, សេង ឲ្យចុះធ្វើការតាមមូលដ្ឋាន ដើម្បីធ្វើឲ្យប្រជាជនយល់ថា អង្គការតឹងតែង និងមិនបានដោះស្រាយបញ្ហាជីវភាពជូនប្រជាជន ដូចជា ធ្វើការលើសម៉ោង និងអាហារពុំគ្រប់គ្រាន់ ។ នៅខែធ្នូ ឆ្នាំ១៩៧៦ ឈាន បានណែនាំ មុត ឲ្យចាត់កម្លាំង សេ.អ៊ី.អា របស់ខ្លួនបំផ្លាញដំណាំ ម៉ាស៊ីនបូមទឹក បញ្ចេញគោក្របីមកឲ្យ ខឹម នៅតំបន់២០ជាដើម ។

នៅខែមករា ឆ្នាំ១៩៧៧ ឈាន បានបញ្ជូន មុត ទៅធ្វើជាពិធីការនៅក្នុងក្រសួងការបរទេស និងណែនាំឲ្យ មុត បន្តកសាងកម្លាំងបន្ថែម ។ នៅពេលដែល មុត មកនៅក្រសួងការបរទេស មុត បានដាច់ការទាក់ទងជាមួយតំបន់២២ រហូតដល់ថ្ងៃអង្គការចាប់ខ្លួន ។

**ម៉ែន ពិចិត្រ**

# ត្រូវវាយសម្រុក ខ្លាំងក្លាបំផុត និងជាប់ជានិច្ចដោយល្បឿន មហាលោតផ្លោះ មហាអស្ចារ្យ!

*ដកស្រង់ចេញពីទស្សនាវដ្តីទង់បដិវត្តន៍លេខ២ ចេញផ្សាយ ខែកុម្ភៈ ឆ្នាំ១៩៧៦*

ថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលកងទ័ពបដិវត្តន៍កម្ពុជា និងប្រជាជនកម្ពុជាក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាដ៏រុងរឿង ដណ្តើមបានមហាជោគជ័យទាំងស្រុង និងជាស្ថាពរ លើចក្រពត្តិអាមេរិកឈ្លានពាន និងពួកអាក្បត់ លន់ នល់ ដែលជាបរិវាររបស់វា ។ ចាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥នេះមក បក្សបានកំណត់ថា យើងបានបញ្ចប់បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ដោយជោគជ័យទាំងស្រុង និងជាស្ថាពរហើយ ។ ចាប់ពីថ្ងៃ១៧ មេសា ១៩៧៥នេះមក ប្រជាជាតិប្រជាជន និងយុវជន-យុវនារីកម្ពុជាយើង ត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជាជាបន្តទៀត ដើម្បីការពារប្រទេស ការពារផលនៃបដិវត្តន៍ឲ្យបានគង់វង្សស្ថិតស្ថេរ និងដើម្បីស្តារសេដ្ឋកិច្ច កសាងប្រទេសឲ្យខ្លាំងពូកែ រីកចម្រើនលូតលាស់ និងថ្កុំថ្កើនរុងរឿងមហាលោតផ្លោះ មហាអស្ចារ្យ ។

តាមទិសបក្សកំណត់ គឺយើងត្រូវកសាងប្រទេសពីកសិកម្ម



កម្មករបដិវត្តន៍ផលិត ឥដ្ឋ ក្បឿង នៅតាខ្មៅ (រូបថត ៖ ខែមីនា ឆ្នាំ១៩៧៨)

អន់ថយឲ្យទៅជាកសិកម្មសម័យ ក្នុងរយៈពី១០ ទៅ១៥ឆ្នាំ ។ នេះជាភារកិច្ចរុងរឿងខ្ពង់ខ្ពស់ឧត្តមបំផុតចំពោះយុវជន-យុវនារីយើងជំនាន់នេះ ។ តែក៏ជាភារកិច្ចធ្ងន់ធ្ងរដែរ ដែលយុវជន-យុវនារីបដិវត្តន៍យើងត្រូវឃើញ ត្រូវចាប់អារម្មណ៍ឲ្យខ្ពស់ ត្រូវប្រឹងវត់ឲ្យលឿនទើបសម្រេចបានជោគជ័យ ។

ក្នុងការបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជាជាបន្តទៀត ដើម្បីការពារប្រទេស និងកសាងប្រទេសឲ្យឈានទៅកាន់កសិកម្មសម័យនេះ និយាយរួម យើងមានទុនច្រើនដែរហើយ ។ គឺយើងមានរដ្ឋអំណាចបដិវត្តន៍នៅក្នុងដៃ ដែលអាចចាត់ចែងការងារទៅតាមទិស និងសំណូមពរបដិវត្តន៍យើង ។ យើងគ្រប់គ្រងរដ្ឋអំណាចទូទាំងប្រទេសហើយ ។ យើងមានកម្លាំងប្រជាជនដ៏មហិមា ។ ប្រជាជនយើងជាប្រជាជនធ្លាប់មានប្រពៃណីអង់អាចក្លាហាន វាយឈ្នះចក្រពត្តិអាមេរិក និងបរិវារ និងជាប្រជាជនខុស្សាហ៍ព្យាយាម មានៈស៊ិតស្មាញ ទ្រាំទ្រការលំបាកវេទនា ពុះពារគ្រប់ឧបសគ្គបានទាំងអស់ ។ យើងមានកងទ័ពរឹងប៉ឹង ខ្លាំងពូកែ និងអង់អាចក្លាហាន ហ៊ានប្រយុទ្ធពុះពារគ្រប់ឧបសគ្គ វាយកម្ទេចខ្មាំងសត្រូវគ្រប់ប្រភេទ ។ យើងមានមធ្យោបាយផលិតកម្មសំខាន់ៗដូចជាដីធ្លី ស្រែចម្ការគ្រប់ប្រភេទដែលមានជីជាតិល្អ ។ យើងមានប្រភពទឹកជាទន្លេ ស្ទឹង អូរ ត្រពាំង បឹងបួរ នៅពាសពេញគ្រប់ទីកន្លែង ។ ក្រៅពីនេះ យើងនៅមានរោងចក្រធំ តូចមួយចំនួនច្រើនដែរហើយ យើងមានរោងសិប្បកម្ម រោងជាងនៅតាមគ្រប់តំបន់ស្រុក-ឃុំ-ភូមិសហករណ៍ យើងមានឧបករណ៍បង្កបង្កើនផលនៅក្នុងកណ្តាប់ដៃប្រជាជន កម្មករ-កសិករ និងក្នុងកណ្តាប់ដៃរដ្ឋអំណាចបដិវត្តន៍យើង ។ ទាំងអស់នេះជាទុនមួយយ៉ាងធំ និងជាមូលដ្ឋានសម្រាប់ឲ្យយើងដំណើរការកសាងប្រទេស និងការពារប្រទេសឲ្យបានខ្លាំងពូកែ សម្បូរសប្បាយ និងថ្កុំថ្កើនរុងរឿងយ៉ាងឆាប់រហ័សបាន ។ តែទុនដែលសំខាន់ជាងនេះទៅទៀត និងជាកត្តាកំណត់ក្នុងការបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជាយើងនាបច្ចុប្បន្ន ក៏ដូចតទៅអនាគតទៀត គឺយើងមានទុនខាងបដិវត្តន៍ ។ ពោលគឺប្រជាជន កម្មករ-កសិករយើង កងទ័ពបដិវត្តន៍កម្ពុជាយើង និងយុវជន-យុវនារីបដិវត្តន៍យើង មានទស្សនៈគោលជំហរសតិអារម្មណ៍បដិវត្តន៍រឹងប៉ឹង ហើយស្ថិតនៅក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាដ៏រុងរឿងថែមទៀត ។ ទុនបដិវត្តន៍នេះហើយដែលជាគ្រឹះយ៉ាងរឹងមាំក្នុងការបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជាយើងនាបច្ចុប្បន្ននិងតទៅអនាគតទៀត ។

តែទន្ទឹមនឹងទុនជាមូលដ្ឋាន ដែលយើងមានខាងលើនេះ បើប្រៀបធៀបនឹងទំហំ និងទម្ងន់នៃភារកិច្ចកសាងប្រទេសពីកសិកម្មអន់ថយនៅកសិកម្មសម័យ ក្នុងរយៈពី១០ ទៅ១៥ឆ្នាំខាងមុខនេះ ឃើញថា ទុនយើងក៏តិចដែរ ពិសេសខាងសម្ភារ ។ ក្រៅពីនេះទៀត យើងខ្វះទុនខាងបច្ចេកទេសសព្វមុខទៀត ។ នេះជាការលំបាកខាងផ្នែកអត្តនោម័តិយើង ។

ទន្ទឹមនឹងការលំបាកខាងផ្នែកអត្តនោម័តិនេះ ខាងផ្នែកសត្យានុមតិក៏មានការស្មុគស្មាញច្រើនដែរ ។ នៅលើសកលលោកសព្វថ្ងៃម៉្យាងចលនាតស៊ូបដិវត្តន៍ និងចលនាសេរីការបស់ប្រជាជនដែលត្រូវគេជិះជាន់សង្កត់សង្កិន ក៏មានសន្ទុះផុលផុសខ្លាំងក្លាណាស់ដែរ ។ តែម៉្យាងទៀត មហាអំណាចធំៗក៏កំពុងធ្វើសកម្មភាពមមាញឹកដណ្តើមឥទ្ធិពល និងដណ្តើមគ្នាត្រួតត្រាលើសកលលោក ដែលនៅក្នុងនេះ ក៏មានប្រទេសកម្ពុជាយើងដែរ ។ បើពិនិត្យមើលសភាពការណ៍កម្ពុជាយើងផ្ទាល់តែម្តង ក៏ឃើញថា សព្វថ្ងៃនេះ ចក្រពត្តិអាមេរិកកំពុងខំធ្វើសកម្មភាពទាំងចំហ ទាំងសម្ងាត់ ទាំងនយោបាយទាំងការទូត ទាំងចារកម្ម ស៊ីរូងបំផ្លិចបំផ្លាញផ្ទៃក្នុងយើងយ៉ាងមមាញឹកដើម្បីដណ្តើមប្រទេសកម្ពុជា យកទៅធ្វើជាខ្ញុំកញ្ជះវាវិញ ។ សកម្មភាពរបស់ចក្រពត្តិអាមេរិក និងបរិវារនេះ បានបន្តធ្វើជាបន្តបន្ទាប់ និងជាប់រហូតបច្ចុប្បន្ន ក៏ដូចតទៅអនាគតទៀតដែរ ។ ប៉ុន្តែដោយគោលជំហរប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជានិច្ច ដោយគោលជំហរទទួលខុសត្រូវខ្ពស់ចំពោះប្រទេសជាតិ ចំពោះប្រជាជន និងបដិវត្តន៍កម្ពុជាយើង និងដោយគោលជំហរតស៊ូយូរអង្វែង ទ្រាំទ្រលំបាកវេទនាកម្រិតខ្ពស់ជាបន្តទៀត គោលជំហរវាយសម្រុកជាប់ជានិច្ច និងប្រយុទ្ធដាច់ខាតរបស់កងទ័ពបដិវត្តន៍កម្ពុជា ប្រជាជនកម្មករ-កសិករយើងទាំងអស់ និងរបស់យុវជន-យុវនារីកម្ពុជាយើងទាំងមូល ក្រោមការដឹកនាំដ៏ឈ្លាសវៃនៃបក្សកុម្មុយនីស្តកម្ពុជា សកម្មភាព និងឧបាយកលរបស់ចក្រពត្តិអាមេរិក និងបរិវារទាំងអស់ខាងលើនេះ ក៏ត្រូវវាយកម្ទេចជាបន្តបន្ទាប់ដែរ ។

ទន្ទឹមនឹងសកម្មភាពរបស់ចក្រពត្តិអាមេរិកខាងលើនេះ យុវជន-យុវនារីបដិវត្តន៍យើង ក៏ត្រូវចាប់អារម្មណ៍យកចិត្តទុកដាក់តាមដាន និងប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់បំផុតចំពោះសកម្មភាព និងឧបាយកលស៊ីរូងបំផ្លិចបំផ្លាញយើង ក៏ដូចសកម្មភាព និងឧបាយកលវាយប្រហារយើង ខាងយោធា នយោបាយរបស់ប្រទេសជិតខាងដែលជាបរិវារចក្រពត្តិគ្រប់ប្រភេទ ដែលជាគូទំនាស់ជាមួយបដិវត្តន៍យើងតាំងពីដើមរៀងមកឲ្យជាប់ជានិច្ច ។ ខ្មាំងសត្រូវរបស់យើងគ្រប់ប្រភេទនេះ ក៏កំពុងមានឧបាយកល និងសកម្មភាពមមាញឹកជាបន្តបន្ទាប់ជាប់ជានិច្ច និងជាយុទ្ធសាស្ត្រយូរអង្វែងដើម្បីវាយយើង ស៊ីរូងផ្ទៃក្នុងបំផ្លិចបំផ្លាញបដិវត្តន៍យើង និងរារាំងកិច្ចដំណើរការកសាងប្រទេស កសាងសង្គមនិយមនៅកម្ពុជាយើងកុំឲ្យលឿនទៅមុខបាន ។ ដូច្នេះ ក្នុងការបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជាយើង ក៏ដូចការកសាងប្រទេសពីកសិកម្មអន់ថយ ទៅកសិកម្មសម័យ ក្នុងរយៈពីដប់ទៅដប់ប្រាំឆ្នាំខាងមុខនេះ យើងត្រូវឃើញទាំងចំណុចខ្លាំងដែលជាទុនជាមូលដ្ឋានរបស់យើង ឲ្យឃើញការលំបាករបស់យើង ទាំងផ្នែកអត្តនោម័តិទាំងផ្នែកសត្យានុម័តិឲ្យច្បាស់លាស់ និងត្រឹមត្រូវដើម្បីជៀសវាងនូវអត្តនោម័តិនិយម ។ បើអត្តនោម័តិ ជួនកាលនាំឲ្យយើងទុទិដ្ឋិនិយមខ្មៅងងឹត បាត់ស្មារតី មិនហ៊ានប្រយុទ្ធជាមួយខ្មាំងសត្រូវគ្រប់ប្រភេទ ក៏ដូចប្រយុទ្ធពុះពារឧបសគ្គ និងការលំបាកគ្រប់បែបយ៉ាងដែលនៅរាំងផ្លូវយើង ។ ជួនកាល សុទិដ្ឋិនិយមហួសហេតុ ដែលនាំឲ្យធ្លាក់ទៅក្នុងសន្តិភាពនិយម កសាងនិយម ភ្លើតភ្លើនតែនឹងជ័យជម្នះ ភ្លេចប្រុងប្រយ័ត្នបដិវត្តន៍ មើលមិនឃើញការប្រយុទ្ធវណ្ណៈ ទាំងខាងផ្នែកប្រជាជាតិ ទាំងខាងផ្នែកប្រជាធិបតេយ្យ ដែលកំពុងតែតឹងតែងស្មុគស្មាញ ហើយចោទចំពោះយើងជាប្រចាំ និងជាយុទ្ធសាស្ត្រជាប់ជានិច្ច ។ បើអត្តនោម័តិយ៉ាងនេះ យើងប្រាកដជាជួបគ្រោះថ្នាក់ពុំខានឡើយ ហើយយើងពុំអាចកសាងប្រទេស ឬកសាងសង្គមនិយមនៅកម្ពុជាបានជោគជ័យឡើយ ។

ដូច្នេះ យុវជន-យុវនារីបដិវត្តន៍យើង ត្រូវឃើញឲ្យច្បាស់នូវការលំបាករបស់យើងបច្ចុប្បន្ន និងតទៅអនាគតទៀត ទាំងខាងផ្នែកអត្តនោម័តិ ទាំងខាងផ្នែកសត្យានុម័តិ ដើម្បីប៉ាន់ប្រមាណ និងមានទស្សនៈឲ្យត្រឹមត្រូវចំពោះទំហំ និងទម្ងន់នៃភារកិច្ចការពារប្រទេស និងកសាងប្រទេសរបស់យើងបច្ចុប្បន្ននេះ ។ ភារកិច្ចការពារប្រទេស និងកសាងប្រទេសទាំងពីរនេះ វាជាប់គ្នាបេះមិនដាច់ឡើយ ។ បើការពារប្រទេសមិនបានល្អ យើងក៏ពុំអាចកសាងប្រទេសបានលឿនដែរ ។ តែបើកសាងប្រទេសមិនបានលឿន ក៏យើងគ្មានទុនគ្រប់គ្រាន់នឹងការពារប្រទេសបានគត់មត់រឹងប៉ឹងល្អដែរ ។ ឃើញទំហំ និងទម្ងន់នៃភារកិច្ចការពារប្រទេស និងកសាងប្រទេសបច្ចុប្បន្ន



យុទ្ធជនកងទ័ពបដិវត្តន៍ និងយុទ្ធនារីកងចល័ត នៅស្រុកទឹកជ្រៅកំពុងវាយសម្រុកច្រូតស្រូវ

និងតទៅអនាគតយ៉ាងនេះ យើងត្រូវរត់ឲ្យលឿនបំផុត ទើបដណ្តើមបានជ័យជម្នះ ។ បើយើងដើរ ឬរត់តាមល្បឿនធម្មតាទេ នោះយើងប្រាកដជាពុំអាចសម្រេចភារកិច្ចការពារប្រទេស និងកសាងប្រទេសក្នុងសភាពតឹងតែង ស្មុគស្មាញនៅលើសកលលោកសព្វថ្ងៃ ក៏ដូចក្នុងសភាពលំបាកខ្វះខាតខាងផ្នែកអត្តនោម័តិយើងដូចពោលខាងលើបានជោគជ័យឡើយ ។

ពាក្យស្លោករបស់យើងក្នុងការបន្តធ្វើបដិវត្តន៍សង្គមនិយម ការកសាងសង្គមនិយមនៅកម្ពុជា ដើម្បីការពារប្រទេស និងកសាងប្រទេសបច្ចុប្បន្ន និងទៅអនាគតទៀត គឺ

***"វាយសម្រុកខ្លាំងក្លាបំផុត និងជាប់ជានិច្ច ដោយល្បឿនមហាលោតផ្លោះ មហាអស្ចារ្យ" ។***

***តើពាក្យស្លោកនេះមានន័យយ៉ាងណា?***



(រូបថត ៖ ខែមីនា ឆ្នាំ១៩៧៨)

◆ វាយសម្រុកខ្លាំងក្លាបំផុត និងជាប់ជានិច្ច មានន័យថា នៅតាមគ្រប់ក្រសួង តាមគ្រប់មន្ទីរ តាមគ្រប់ការដ្ឋាន គ្រប់កសិដ្ឋាន និងនៅតាមគ្រប់ភូមិសហករណ៍ ប្រជាជនកម្មករ កសិករទាំងអស់នៅតាមគ្រប់រោងចក្រ តាមគ្រប់ការដ្ឋាន និងនៅតាមគ្រប់សហករណ៍ត្រូវវាយសម្រុកឲ្យខ្លាំងក្លាបំផុត សម្រេចភារកិច្ចតូចធំគ្រប់បែបយ៉ាង ដែលជាភារកិច្ចប្រចាំថ្ងៃរៀងៗខ្លួន ឲ្យបានល្អច្រើនឆាប់រហ័សតែសន្សំសំចៃខ្ពស់បំផុត ។ ការវាយសម្រុកធ្វើការងារតូចធំគ្រប់បែបយ៉ាង ដែលជាភារកិច្ចប្រចាំថ្ងៃរបស់យើងរៀងៗខ្លួននេះ ត្រូវវាយសម្រុកជាប់ជានិច្ច មិនថាយប់ឬថ្ងៃ មិនថា ក្តៅឬរងារឡើយ ។ វាយសម្រុកធ្វើការងារ ដោយមិនគិតគូរពីម៉ោងពេល មិនគិតគូរពីការហត់នឿយ ឈប់សម្រាកឡើយ ។ ពោលគឺវាយសម្រុកជាប់ជានិច្ច រាល់ថ្ងៃ រាល់ម៉ោង ហើយលៃច្នៃយ៉ាងណាបង្កើនម៉ោងធ្វើការឲ្យបានច្រើនថែមទៀត ។ នេះហើយជាន័យវាយសម្រុកខ្លាំងក្លាបំផុត និងជាប់ជានិច្ច ។

ន័យវាយសម្រុកខ្លាំងក្លាបំផុត និងជាប់ជានិច្ច ម្យ៉ាងទៀតគឺ វាយសម្រុកធ្វើការងារគ្រប់បែបយ៉ាងទាំងអស់ ដោយគោលជំហរឯករាជ្យ-ម្ចាស់ការ ខ្លួនទីពឹងខ្លួន កម្រិតខ្ពស់បំផុត ដោយគោលជំហរច្នៃប្រឌិតកសាងរស់រវើក មិនធ្វើការស្តាប់ក្រឡាត្រង់ស្លូកទៅតាមតែទម្លាប់ចាស់ ដែលអន់ថយយឺតយ៉ាវ មិនចម្រើនជឿនលឿន ។ ដោយគោលជំហរសន្សំសំចៃខ្ពស់បំផុត មិនធ្វើការឲ្យខាងតែបាន ឲ្យខាងតែលឿន មិនខ្ជះខ្ជាយ ខូចខាតអន្តរាយពាក់កណ្តាលនោះឡើយ ។ គោលជំហរសន្សំសំចៃនេះ គឺសមស្របទៅតាមពាក្យស្លោកដែលថា "ធ្វើការច្រើន បានផលច្រើន តែចំណាយទុនតិចបំផុត" ។ ដោយគោលជំហរទទួលខុសត្រូវចំពោះបក្សបដិវត្តន៍ ប្រជាជាតិ និងប្រជាជនខ្ពស់បំផុត ពោលគឺមិនធ្វើការឲ្យរួចតែពីដៃ តាមរបៀបខ្ញុំគេ ឬស៊ីឈ្នួលគេ ដូចកាលនៅសង្គមចាស់ឡើយ ។ នេះហើយជាន័យពេញលេញនៃពាក្យស្លោក "វាយសម្រុកឲ្យខ្លាំងក្លាបំផុត និងជាប់ជានិច្ច" ។

◆ ដោយល្បឿនមហាលោតផ្លោះ គឺលឿនគ្រប់ផ្នែកការងារទាំងអស់ ហើយលឿនឲ្យហួសផែនការកំណត់ទៅទៀត ។ ឧបមា ៖ បើថាផែនការឆ្នាំ៧៦ នេះ ធ្វើស្រែឲ្យបានផលស្រូវបីតោនក្នុងមួយហិកតាជាមធ្យម និងជាទូទៅ បើធ្វើការតាមពាក្យស្លោកវាយសម្រុកខ្លាំងក្លាបំផុត ដោយល្បឿន មហាលោតផ្លោះ គឺយើងត្រូវប្រយុទ្ធកែប្រែបច្ចេកទេសដាំដុះ គ្រប់សព្វបែបយ៉ាង តាំងពីភ្ជួរ ប្រឡាយ ទំនប់ ទឹកដី ពូជ ភ្ជួររាស់ ធ្វើស្មៅ ។ ធ្វើយ៉ាងណាបង្កើនផលស្រូវយើង មិនមែនឲ្យបានត្រឹមតែមួយហិកតាបីតោនប៉ុណ្ណោះទេ តែត្រូវឲ្យបាន ៤, ៥, ៦, ៧, ៨តោនក្នុងមួយហិកតាទៅទៀត ។ ធ្វើយ៉ាងនេះទើបហៅថា វាយសម្រុកដោយល្បឿនមហាលោតផ្លោះ ។

◆ មហាអស្ចារ្យ មានន័យថា ធ្វើឲ្យបានល្អផង ហើយធ្វើឲ្យបាន

ត្រឹមត្រូវតាមមាគ៌ារបស់បក្សផង ។ ពោលគឺមហាអស្ចារ្យ ត្រង់ដែលធ្វើបានល្អ បានលឿន បានច្រើន ហើយមិនខុស ។ មិនខុសនេះ ទាំងក្នុងន័យមាគ៌ានយោបាយរបស់បក្ស ក៏ដូចក្នុងន័យបច្ចេកទេសការងារ ។ ឧបមា ៈ បើលើកភ្លឺ ជីកប្រឡាយ គឺធ្វើបានច្រើនគ្រប់ស្រែផង អាចទប់ទឹក បង្ហូរទឹកបញ្ចេញបញ្ចូលស្រែបានគ្រប់រដូវផង ធ្វើបានហើយឆាប់រហ័សផង ហើយប្រើប្រាស់កម្លាំងពលកម្មតែល្មម មិនច្រើនមិរកកស្រទាប់នៅតែមួយកន្លែងៗទៀត ។ តែបើយើងវាយសម្រុកលើកភ្លឺ ជីកប្រឡាយទាំងយប់ទាំងថ្ងៃដែរ តែធ្វើបានតែមួយកន្លែងបុពីរកន្លែង ឬធ្វើបានច្រើនដែរ តែគ្មានទឹក ឬក៏មានទឹកច្រើនហួស លិចរលួយសំណាប សន្ទូងអស់នោះក៏មិនហៅថា មហាអស្ចារ្យដែរ ។

ន័យមហាអស្ចារ្យម៉្យាងទៀត គឺដោយប្រៀបធៀបនឹងទុនដែលយើងមានតិចតួច តែយើងអាចវាយសម្រុកការពារប្រទេស និងកសាងប្រទេសបានល្អ រឹងប៉ឹង ត្រឹមត្រូវយ៉ាងឆាប់រហ័សបំផុត ។ សរុបមកវិញ ន័យទាំងប៉ុន្មានខាងលើនេះហើយ ដែលជាន័យពិតប្រាកដត្រឹមត្រូវ និងពេញលេញរបស់ពាក្យ "វាយសម្រុកឲ្យខ្លាំងក្លាបំផុត និងជាប់ជានិច្ច ដោយល្បឿនមហាលោតផ្លោះ មហាអស្ចារ្យ" ដែលយុវជន-យុវនារីយើងគ្រប់រូបត្រូវជ្រួតជ្រាប ក្ដាប់ឲ្យជាប់គ្រប់ពេលវេលា ហើយប្រែក្លាយឲ្យទៅជាកម្លាំងប្រយុទ្ធជាក់ស្ដែង ខ្លាំងក្លាបំផុត ក្នុងគ្រប់ភារកិច្ចបដិវត្តន៍តូច- ធំ ធ្ងន់- ស្រាល ដែលយើងធ្វើរាល់ថ្ងៃ និងនៅគ្រប់ទិសទីទាំងអស់ ។

ទាល់តែយើងវាយសម្រុកការពារ និងកសាងប្រទេសយើងឲ្យខ្លាំងក្លាបំផុតជាប់ជានិច្ច ដោយល្បឿនមហាលោតផ្លោះ មហាអស្ចារ្យ ឲ្យស្មើដៃគ្នា គ្រប់ក្រសួង គ្រប់មន្ទីរ គ្រប់ការដ្ឋាន គ្រប់រោងចក្រ និងគ្រប់សហករណ៍យ៉ាងនេះ ទើបយើងអាចស្កាត់ទប់នូវបាតដៃឧក្រិដ្ឋរបស់ខ្មាំងសត្រូវ យើងគ្រប់ប្រភេទ ទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស ទាំងនៅជិត ទាំងនៅឆ្ងាយ មិនឲ្យវាមានលទ្ធភាព និងមានឱកាសលូកដៃមកកកូររារាំង ឬស៊ីរូងបំផ្លិចបំផ្លាញផ្ទៃក្នុងបដិវត្តន៍យើងបាន បំផ្លិចបំផ្លាញប្រទេសជាតិ ប្រជាជន និងការកសាងសង្គមនិយម នៅក្នុងប្រទេសយើងបានដាច់ខាត ។

ដូច្នេះបញ្ហាចោទគឺ យុទ្ធជន យុទ្ធនារី កម្មាភិបាលបដិវត្តន៍ ប្រជាជន កម្មករ កសិករ និងយុវជន យុវនារីកម្ពុជាយើងទាំងអស់ត្រូវជម្រះសតិអារម្មណ៍ឲ្យជ្រះស្រឡះ មើលឃើញទម្ងន់នៃភារកិច្ចយើងឲ្យច្បាស់ ហើយកុំគិតគូរទៅបញ្ហាបុគ្គលសួនតួអ្វី ទៅរឿងរ៉ាវកំប៉ិកកំប៉ុកអ្វី ក្រៅពីភារកិច្ចដ៏ធ្ងន់ធ្ងររបស់យើងនេះឲ្យសោះ ដែលនាំឲ្យស្មុគស្មាញក្នុងសតិអារម្មណ៍ មិនជ្រះថ្លាក្នុងការវាយសម្រុក ដូចពោលខាងលើ នាំឲ្យយឺតយ៉ាវដល់កិច្ចដំណើរការវាយសម្រុកការពារប្រទេស និងកសាងប្រទេសរបស់យើង ។ បើសតិអារម្មណ៍យើងជ្រះស្រឡះភ្លឺថ្លា ប្រមូលផ្ដុំផ្ដោះតម្រង់តែទៅលើភារកិច្ចវាយសម្រុកការពារប្រទេស និងកសាងប្រទេស ដូចពោលខាងលើហើយ នោះយើងប្រាកដជាសម្រេចពាក្យស្លោក "វាយសម្រុកឲ្យខ្លាំងក្លាបំផុត និងជាប់ជានិច្ច ដោយល្បឿនមហាលោតផ្លោះ មហាអស្ចារ្យ" ដោយជោគជ័យពុំខានឡើយ ។ យើងប្រាកដជាសម្រេចភារកិច្ចការពារប្រទេស កសាងប្រទេស ឲ្យលឿនមហាលោតផ្លោះ មហាអស្ចារ្យយ៉ាងពិតប្រាកដ ដែលធ្វើឲ្យសកលលោកទាំងមូល គោរពស្ញប់ស្ញែង កោតសរសើរ និងរៀនសូត្រតាមគំរូយើងពុំខានឡើយ ។ ដូច្នេះខ្មាំងសត្រូវទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស ទាំងនៅជិត ទាំងនៅឆ្ងាយ ពុំអាចធ្វើអ្វីយើងបានឡើយ ។ បច្ចុប្បន្ន គឺវាធ្វើអ្វីយើងមិនបាន តទៅអនាគតទៀតដែលប្រទេសជាតិយើងកាន់តែរីកចម្រើនលូតលាស់លើគ្រប់វិស័យ និងកាន់តែរឹងប៉ឹងថែមទៀត នោះខ្មាំងរឹតតែធ្វើអ្វីយើងលែងកើតទៀតហើយ ។

ដូច្នេះ យុវជន យុវនារីបដិវត្តន៍យើងទាំងអស់ ត្រូវតែវាយសម្រុកការពារប្រទេស និងកសាងប្រទេសទៅតាមភារកិច្ចរៀងៗខ្លួនឲ្យខ្លាំងក្លាបំផុត និងជាប់ជានិច្ច ដោយល្បឿនមហាលោតផ្លោះ មហាអស្ចារ្យ ។ **ឆេង ម៉េង**

## អានទស្សនាវដ្ដីតាមគេហទំព័រ

ទស្សនាវដ្ដីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# ចម្លើយសារភាពរបស់ អ៊ឹម ខន ប្រធានរោងចក្រកែវ ក-១០

### *ដកស្រង់ចេញពីឯកសារចម្លើយសារភាព D៥៩០១០*

អ៊ឹម ខន ភេទប្រុស អាយុ២៦ឆ្នាំ កើតនៅភូមិត្រពាំងពោធិ៍ ឃុំភ្នំបាត ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។ ខន មានតួនាទីជាប្រធានរោងចក្រកែវក-១០ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រពន្ធឈ្មោះ ខឹម ជុន ធ្វើការនៅរោងចក្រតម្បាញត-៦ ។ ខន ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ពីបទធ្វើសកម្មភាពប្រឆាំងអង្គការ ។ ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបចេញពីចម្លើយសារភាពរបស់ ខន៖

កាលនៅតូច ខន រស់នៅជាមួយឪពុកម្ដាយ រកស៊ីធ្វើស្រែ និងឡើងត្នោត ។ ពេលដែលស្រុកទេសកើតភាពវឹកវរស្ទើរគ្រប់ទីកន្លែងនៅទូទាំងប្រទេស ខន ក៏បានស្ម័គ្រចិត្តចូលបម្រើក្នុងចលនាបដិវត្តន៍នៅខែឧសភា ឆ្នាំ១៩៧០ តាមរយៈប្រធានឈ្លបឃុំភ្នំបាត ឈ្មោះ បាន ស្លាប់ឆ្នាំ១៩៧៦ (មុនស្លាប់ជាយុទ្ធជននៅមន្ទីរឃុំភ្នំបាត) ។ ពេលនោះ ខន មាននាទីជាយុទ្ធជនឈ្លបឃុំ មានភារកិច្ចវាយខ្មាំងនៅភ្នំតដួរស្បូ ភ្នំបាត និងនៅខ្សាច់កណ្ដាល ។ ចូលបដិវត្តន៍បានបីខែ ឈ្មោះ បាន បានអប់រំឲ្យចូលក្នុងចលនា សេ.អ៊ី.អា ហើយបានណែនាំឲ្យស្គាល់សមាជិកមួយចំនួននៅក្នុងខ្សែរយៈមាន



ជនរងគ្រោះនៅមន្ទីរស-២១ ដែលអង្គការចាប់ខ្លួនដោយចោទថា ក្បត់ ។ ជនរងគ្រោះទាំងនេះត្រូវបានឆ្មាំគុកសួរចម្លើយ និងធ្វើទារុណកម្ម មុននឹងយកទៅសម្លាប់

ឈ្មោះ ឡូញ ប្រធានភូមិត្រពាំងពុទ្រា ឃុំភ្នំបាត, ព្រីង ហៅ វុន ប្រធានភូមិថ្មកត្របែកឃុំភ្នំបាត, សេង យុទ្ធជនឈ្លបឃុំភ្នំបាត, កែម យុទ្ធជនឈ្លបឃុំ, សុន យុទ្ធជនឈ្លបឃុំ, នឹម ប្រធានភូមិស្រែរាំង ឃុំភ្នំបាត, ថែម ប្រធានភូមិក្រោលខ្សៀវ ឃុំភ្នំ បាត ។ ក្រោយមក បាន បាននាំសមាជិកទៅប្រជុំនៅមាត់ត្រពាំងកងជ័រខាងត្បូងភូមិអំពិលរូង ។ ការប្រជុំនេះមានគោលបំណងសំខាន់ទី១ខទ្ទេសនាមឲ្យសមាជិកខ្មែរយៈ សេ.អ៊ី.អា ទាំងអស់បានស្គាល់គ្នាទៅវិញទៅមក ។ ទី២ ធ្វើសកម្មភាពទាក់ទងទាហាននៅបន្ទាយភ្នំបាត ដើម្បីឲ្យទាហានឡើងមកធ្វើទុក្ខបុកម្នេញ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ប្រជាជន ធ្វើឲ្យប្រជាជនបាត់ជំនឿលើការដឹកនាំរបស់អង្គការបដិវត្តន៍ ។ ទី៣ ឃោសនាក្នុងជួរប្រជាជន យុទ្ធជន ឲ្យមើលឃើញកម្លាំងទាហានរបស់ខ្មាំងខ្លាំងក្លា រីឯមាំជាងកម្លាំងរបស់បដិវត្តន៍ បំផុសប្រជាជនឲ្យរារាំងកូនចៅរបស់ខ្លួនកុំឲ្យចូលបម្រើក្នុងជួរបដិវត្តន៍ ។ និងទី៤ កសាងកម្លាំងសេ.អ៊ី.អា ឲ្យបានច្រើន ។ ក្រោយមក ខន និងបក្សពួកបានអនុវត្តតាមផែនការដូចបានរៀបរាប់ខាងលើជាប្រចាំ ។ ជាក់ស្តែង ខន បានទាក់ទងជាមួយឈ្មោះ ចោម ទាហានពាក់ស័ក្តិ១ នៅបន្ទាយភ្នំបាតចំនួន៨លើក ដើម្បីឲ្យទាហានទាំងនោះឡើងមកធ្វើទុក្ខបុកម្នេញដល់ប្រជាជន ធ្វើបាបនារីភេទ បំផ្លាញទ្រព្យសម្បត្តិប្រជាជនដុតផ្ទះ បាញ់គោ ក្របី ចាប់មាន់ទា របស់ប្រជាជនជាដើម ។ មិនតែប៉ុណ្ណោះ ខន និងបក្សពួកបានចាប់ប្រជាជននៅតាមភូមិយកទៅឃុំទុកមួយថ្ងៃឬពីរថ្ងៃ ជាហេតុធ្វើឲ្យប្រជាជនមានការខឹងសម្បារថ្នាំងថ្នាក់ជាមួយនឹងអង្គការជាបន្តបន្ទាប់ ។

ដើមឆ្នាំ១៩៧១ ឈ្មោះ ហាន បានចាត់តាំង ខន និង សេង ឲ្យទៅធ្វើការនៅកងក្នុងតំបន់១៥ និងបានផ្ញើលិខិតមួយច្បាប់តាមអ្នកទាំងពីរយកទៅប្រគល់ឲ្យឈ្មោះ ម៉ាច ប្រធានយោធាតំបន់១៥ និងឈ្មោះ ឆេន អនុប្រធានកងតំបន់១៥ ដែលអត្ថន័យនៅក្នុងលិខិតនោះគឺសុំឲ្យឈ្មោះ ម៉ាច និង ឆេន ទទួលយកអ្នកទាំងពីរចូលជាខ្មែរយៈ សេ.អ៊ី.អា របស់ខ្លួនដើម្បីធ្វើសកម្មភាពប្រឆាំងអង្គការបន្តទៀត ។ មួយរយៈពេលក្រោយមក ខន និង សេង បានធ្វើសកម្មភាពបំផុសយុទ្ធជនឲ្យរត់ចោលសមរភូមិ ធ្វើឲ្យបែកការណ៍នៅក្នុងសមរភូមិ ខ្មាំងដឹងបានបាញ់រះមកលើកម្លាំងបដិវត្តន៍ធ្វើឲ្យគ្រោះថ្នាក់ដល់កម្លាំងបដិវត្តន៍ ។ ពេលសត្រូវវាយបុកខ្លាំងនៅសមរភូមិ ខន និងបក្ខពួកបានរត់ចោលគ្នីគ្នាជាដើម ។ ក្រោយពីបានទទួល ខន និង សេង ឲ្យចូលជាសមាជិកក្នុងក្រុមតាមការផ្តាំផ្ញើរបស់ ហាន មក, ម៉ាច និង ឆេន បានណែនាំអ្នកទាំងពីរឲ្យស្គាល់ខ្មែរយៈក្នុងក្រុមមានឈ្មោះ ធួន ប្រធានកងតូចនៅវរសេនាតូច ១១៨ ក្នុងកងពលលេខ១៤ (បច្ចុប្បន្នក្តាប់មិនបាន), ឈ្មោះ វ៉ា ប្រធានក្រុមកងតំបន់១៥ ឆ្នាំ១៩៧៤ នៅខាងសេដ្ឋកិច្ចយោធាភូមិភាគពិសេស (បច្ចុប្បន្នក្តាប់មិនបាន), ឈ្មោះ រីត ប្រធានក្រុម (បច្ចុប្បន្នក្តាប់មិនបាន), និងឈ្មោះ ឃន យុទ្ធជនកងតំបន់១៥ (បច្ចុប្បន្នក្តាប់មិនបាន) ។ ក្រោយពីបានស្គាល់ខ្មែរយៈ ហើយ ខន និង សេង រួមជាមួយបក្ខពួកផ្សេងៗទៀតបានដើរបំផុសយុទ្ធជនឲ្យខ្លាចខ្មាំងរត់ចោលសមរភូមិជាបន្តបន្ទាប់ ពេលនៅសមរភូមិធ្វើឲ្យបែកការណ៍ឮដល់ខ្មាំងៗបានបាញ់មកលើកម្លាំងបដិវត្តន៍ធ្វើឲ្យពលី



អតីតមន្ទីរសន្តិសុខស-២១ ក្រោមការគ្រប់គ្រងរបស់ ឌុច ត្រូវប្រែឈ្មោះទៅជាសារមន្ទីរ

និងរបួសមួយចំនួន ។

ខែមិថុនា ឆ្នាំ១៩៧១ ម៉ាច បានចាត់តាំង ខន ឲ្យធ្វើជាអនុក្រុមកងតំបន់១៥ និងបានឧទ្ទេសនាម ខន ឲ្យស្គាល់សមាជិក សេ.អ៊ី.អា មួយចំនួនក្នុងក្រុមរបស់ខ្លួន ដើម្បីជាការងាយស្រួលក្នុងការទាក់ទងគ្នាធ្វើសកម្មភាព ។ សមាជិកទាំងនោះរួមមានឈ្មោះ រ៉ុម ប្រធានកងតូចកងតំបន់១៥ (ស្លាប់), បឿន អនុកងតូច កងតំបន់១៥ ឆ្នាំ១៩៧៤ ធ្វើជាប្រធានកងតូចកងវរៈ១១៨ (បច្ចុប្បន្នក្តាប់មិនបាន), បូ ហៅ សាវ៉ាត ប្រធានក្រុមកងតំបន់១៥ បច្ចុប្បន្នប្រធានផ្នែកធ្វើគ្រាប់រំសេវនៅមន្ទីរក-៦៥ ចម្ការដូង ។

ឆ្នាំ១៩៧២ ខន និង ធួន កសាងកម្លាំង សេ.អ៊ី.អា បានចំនួន ៣នាក់ទៀតមានឈ្មោះ ភាព ប្រធាន (កងតូចនៅវរសេនាតូច ១១៨របស់ភាគពិសេស (បច្ចុប្បន្នក្តាប់មិនបាន), ឈ្មោះ ជួន ប្រធានក្រុមកងធំ កងពិសេសរបស់កងពល១៤ (បច្ចុប្បន្នក្តាប់មិនបាន), និងឈ្មោះ ប្រុញ ប្រធានកងធំនៅវរៈ១១៨ បច្ចុប្បន្ននៅខាងជួសជុលយន្តហោះនៅពោធិ៍ចិនតុង ។ ខែ៦ឆ្នាំដដែល ឈ្មោះ ម៉ាច បានរៀបចំកងតំបន់១៥មួយកងធំឲ្យចូលមកវរសេនាតូច ១១៨ របស់ភាគពិសេសដែលមានឈ្មោះ ឌី ជាប្រធានកងធំ និងបានចាត់តាំង ខន ឲ្យចូលមកភាគពិសេសនេះដែរ ។ មុនពេលចេញមកភាគពិសេស ម៉ាច បានណែនាំ ខន, ក៉ា, បឿន, រីត, ឌី ឲ្យបានស្គាល់គ្នា ហើយឲ្យធ្វើការទាក់ទងជាមួយឈ្មោះ ជន លេខាវរសេនាតូច ១១៨ ប្រធានក្រុមកងធំកងពិសេសរបស់កងពល១៤ (បច្ចុប្បន្នស្លាប់), ឈ្មោះ ទាប អនុវរសេនាតូច១១៨ ជាអនុលេខាស្រុកឧដុង្គ (បច្ចុប្បន្នក្តាប់មិនបាន), និងឈ្មោះ ម៉ៅ សមាជិកកងវរសេនាតូច១១៨ កងពល១៤ និងជាប្រធានការដ្ឋានវ៉ៃថ្មធ្វើផ្លូវរទេះភ្លើងនៅភ្នំបាសិតក្នុងឆ្នាំ១៩៧៦ (បច្ចុប្បន្នក្តាប់មិនបាន) ។ បន្ទាប់មក ឌី បានដឹកនាំកងធំរបស់ខ្លួនចូលទៅក្នុងវរៈ១១៨ របស់ភាគពិសេស ដែលបោះទ័ពនៅព្រៃខាងលិចផ្សារបាត់ដឹង ក្នុងឃុំត្រាចទង ស្រុកឧដុង្គ ។



ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩

នៅចុងឆ្នាំ១៩៧២ កងវរសេនាតូច១១៨ មានភារកិច្ចវាយខ្មាំងនៅសមរភូមិបន្ទាយ ពោធិ៍កោង ផ្សារដែក ត្រពាំងផុង ត្រពាំងត្នោត និងភ្នំបាសិត ។ ពេលវាយនៅសមរភូមិខាងលើនេះ ខន និងបក្ខពួកបានធ្វើសកម្មភាពបំផុសយុទ្ធជនឲ្យរត់ចោលសមរភូមិជាបន្តបន្ទាប់ ពេលចូលសមរភូមិម្តងៗរត់ចោលគ្នាធ្វើឲ្យខ្មាំងវាយបុកបាក់ខ្សែត្រៀម ពេលឃើញយុទ្ធជនពលី និងរបួស ខន និងបក្ខពួកមិនបានយកចិត្តទុកដាក់បញ្ជូនអ្នកទាំងអស់នោះមកសមរភូមិក្រោយទេ បែរជានាំគ្នារត់ចោលធ្វើឲ្យយុទ្ធជនពលីអស់មួយចំនួន ។

ខែ៤ ឆ្នាំ១៩៧៣ ឌី បានបើកការប្រជុំមួយដែលអ្នកចូលរួមមានឈ្មោះ ខន, បឿន, ធួន, ប្រុញ, ក៉ា, រីត, រ៉ុម, បូ ហៅ សាវ៉ាត, ជួន និង ភាព ។ ក្នុងអង្គប្រជុំ ឌី បានណែនាំឲ្យសមាជិកទាំងអស់ធ្វើសកម្មភាពតាមផែនការសេ.អ៊ី.អាចាស់ ជាពិសេសខិតខំកសាងកម្លាំងឲ្យកាន់តែខ្លាំងក្លាថែមទៀត បំផ្លាញអាវុធ គ្រាប់រំសេវ និងបំផ្លាញកម្លាំងបដិវត្តន៍តាមការណែនាំរបស់ឈ្មោះ ជន, ម៉ៅ និង ទាប ។ បន្ទាប់មក ខន រួមជាមួយ ជួន, សាវ៉ាត និង ភាព កសាងសមាជិក សេ.អ៊ី.អាបានចំនួន៦នាក់ មានឈ្មោះ ស៊ុម អនុក្រុម (បច្ចុប្បន្ននៅ

កងពល៨០១) , ឈ្មោះ ប៉ុល ប្រធានក្រុម (ស្លាប់ចុងឆ្នាំ១៩៧៣) , ឈ្មោះ នល់ ប្រធានពួកនៅកងតូចរបស់ខន, ឈ្មោះ វណ្ណៈ យុទ្ធជនកងតូចរបស់ ខន, ឈ្មោះ វ៉េត យុទ្ធជនកងតូចរបស់ខនឆ្នាំ១៩៧៣ រត់ទៅផ្ទះត្រូវអង្គការចាប់ខ្លួនបញ្ជូនទៅដាក់នៅសន្តិសុខរបស់ភាគពិសេស (បច្ចុប្បន្នក្តាប់មិនបាន) និងឈ្មោះ ងីន អនុកងតូចរបស់ ខន ចុងឆ្នាំ១៩៧៣ រត់ទៅផ្ទះ (បច្ចុប្បន្នក្តាប់មិនបាន) ។ កម្លាំងដែលកសាងបាន ខន បានចាត់តាំងឲ្យធ្វើសកម្មភាពជាមួយកម្លាំងចាស់ផ្សេងៗទៀត ដើរបំផុសយុទ្ធជនឲ្យរត់ចោលសមរភូមិ និងបាញ់បំផ្លាញគ្រាប់រំសេវពេលចូលសមរភូមិជាដើម ។

ដើមឆ្នាំ១៩៧៤ កងវរៈ១១៨ បានទទួលមុខសញ្ញាវាយខ្មាំងនៅបន្ទាយភ្នំបាសិត កប់ស្រូវ ត្រពាំងផុង និងត្រពាំងត្នោត ។ ពេលនោះ ខន រួមជាមួយបក្ខពួក បានធ្វើសកម្មភាពបំផុសយុទ្ធជនឲ្យរត់ចោលសមរភូមិអស់២២នាក់ ដកទ័ពចោលគ្នានៅសមរភូមិបណ្តាលឲ្យខ្មាំងវាយបុកបាក់ខ្សែត្រៀមចំនួន៧លើកធ្វើឲ្យយុទ្ធជនពលីអស់៩នាក់ និងរងរបួសមួយចំនួន ។ ក្នុងអំឡុងខែ៨ឆ្នាំដដែល ខន ត្រូវរបួសពេលវាយខ្មាំងនៅបន្ទាយវត្តចេតិយថ្មី ហើយបានទៅសម្រាកព្យាបាលរបួសនៅមន្ទីរពេទ្យ២៧ ភូមិចង្វាររាលខាងលិចខុដុង្គអស់រយៈពេលមួយខែកន្លះ ។ ក្រោយពេលចេញពីពេទ្យ ខន បានទៅធ្វើការនៅសេដ្ឋកិច្ចវរៈ១១៨ ពេលនោះ ឌី ក៏បានចាត់តាំង ខនឲ្យមកនៅមន្ទីរពិការរបស់ភាគពិសេសនៅភូមិចង្វាររាល ។ នៅមន្ទីរពិការ ខន បានធ្វើការទាក់ទងជាមួយខ្សែរយៈដែលមានឈ្មោះ ដែក ប្រធានមន្ទីរពិការតាមការណែនាំរបស់ ឌី ។ បន្ទាប់មក ដែក បានចាត់តាំង ខន ឲ្យធ្វើជាប្រធានក្រុមខាងស្លថ្នាំពេទ្យនៅភូមិថ្មីខាងត្បូងភូមិចង្វាររាល និងបានណែនាំឲ្យស្គាល់ខ្សែរយៈមួយចំនួនទៀតមានឈ្មោះ រំ ប្រធានកងធំនៅមន្ទីរពិការរបស់ភាគពិសេស ឈ្មោះ ឆាយ អនុប្រធានកងពិការនៅមន្ទីរពិការរបស់ភាគពិសេស បច្ចុប្បន្នប្រធានចិញ្ចឹមជ្រូករបស់ក្រសួងខស្សរាហកម្មរដ្ឋព្រែកឯង, ឈ្មោះ មីន ប្រធានកងកុមារនៅមន្ទីរពិការ បច្ចុប្បន្នប្រធានរោងចក្រអារឈើរបស់ក្រសួងខស្សរាហកម្មរដ្ឋនៅខាងកើតកំពង់សោម, ឈ្មោះ សារូ ប្រធានកងតូចនៅមន្ទីរពិការរបស់ភាគពិសេស បច្ចុប្បន្នអង្គការដក (មុនអង្គការដកជាប្រធានរោងចក្រប្រេងកន្ទុកនៅភ្នំពេញ) , ឈ្មោះ រ៉េន អនុកងហាររបស់ សារូ បច្ចុប្បន្នជាប្រធានរោងចក្រធ្វើបារីនៅខាងត្បូងក្បាលថ្នល់ ។

បន្ទាប់មក ខន បានអប់រំកម្លាំង សេ.អ៊ី.អា បានបីនាក់ថែមទៀតមានឈ្មោះ នីល មេពួកស្លថ្នាំពេទ្យ បច្ចុប្បន្ននៅខាងសេដ្ឋកិច្ចដាំស្លរបស់រោងចក្រខ្យល់អុកស៊ីហ្សែនភ្នំពេញ, ឈ្មោះ ឈាង យុទ្ធជនស្លថ្នាំពេទ្យ បច្ចុប្បន្នប្រធានក្រុមនៅរោងចក្រខ្យល់អុកស៊ីហ្សែនភ្នំពេញ, និងឈ្មោះ សាង យុទ្ធជនពេទ្យនៅក្រុមស្លថ្នាំពេទ្យ បច្ចុប្បន្នក្តាប់មិនបាន ។ ខន បានចាត់តាំងអ្នកទាំងបីឲ្យធ្វើសកម្មភាពដើរលួចទ្រូដែលប្រជាជនដាក់យកត្រីនៅតាមវាលស្រែ លួច ដូង ចេកគាស់ដំឡូងជ្វា ដំឡូងមីរបស់ប្រជាជនជាបន្តបន្ទាប់ធ្វើឲ្យប្រជាជនមានការថ្នាំងថ្នាក់ជាមួយអង្គការបដិវត្តន៍ ។ នៅកន្លែងស្លថ្នាំ ខន បានចាត់តាំងកម្លាំងពីរឬបីនាក់ប៉ុណ្ណោះឲ្យដើររកបេះរុក្ខជាតិផ្សេងៗយកមកផ្សំស្លធ្វើជាថ្នាំ ។ ការប្រើកម្លាំងតិចតួចនេះ ធ្វើឲ្យប៉ះពាល់ដល់ដំណើរការផលិត ថ្នាំ ព្រោះកម្លាំងតិចដើររកថ្នាំមិនបានច្រើនហើយមិនបានគ្រប់មុខតាមតម្រូវការទៀតដែលជាហេតុធ្វើឲ្យមានការរាំងស្ទះដល់ការផលិតថ្នាំ ។

ដើមឆ្នាំ១៩៧៥ ដែក បានមកជួប ខន នៅភូមិថ្មី ។ ខន បានរាយការណ៍ប្រាប់ ដែក ពីសកម្មភាពដែលខ្លួន និងបក្សពួកបានអនុវត្តកន្លងមក ។ ដែក ក៏បានណែនាំ ខន និងបក្ខពួកខំប្រឹងបន្តទៀតក្នុងការកសាងសមាជិក សេ.អ៊ី.អា ឲ្យបានកាន់តែច្រើន និងធ្វើសកម្មភាពផ្សេងៗដែលធ្វើឲ្យរាំងស្ទះដល់ការផលិតថ្នាំពេទ្យជាដើម ។

ក្រោយរំដោះ ខែមេសា ឆ្នាំ១៩៧៥ ដែក បានដកក្រុមរបស់ ខន ឲ្យទៅនៅមន្ទីរពិការឯភ្នំទង់ ក្នុងស្រុកថ្ពងជាងមួយខែ ។ នៅទីនោះ ខន បានក្តាប់ក្រុមដើររកថ្នាំ ហើយបានធ្វើសកម្មភាពដូចខាងលើដើម្បីរាំងដល់ការផលិតថ្នាំរបស់អង្គការ ។ ខែ៦ឆ្នាំដដែល អង្គការបានដកអង្គភាពពិការឲ្យមកនៅខាងជើងស្តាតអូឡាំពិក២ថ្ងៃ ។ រំលងបានមួយថ្ងៃក្រោយមក ខន ត្រូវបានអង្គការឲ្យចូលធ្វើការនៅក្នុងរោងចក្រតម្បាញគ-៦ ចាក់អង្រែក្រោម ខាងត្បូងភ្នំពេញ ។ ពេលនោះ ខន មាននាទីជាសមាជិកក្រុមយាមការពាររោងចក្រ ។ ខែ៨ ខន បានជួបឈ្មោះ មីន ប្រធានរោងចក្រជ-៤ ពេលចេញទៅចាប់ជ្រូកយកមកកាប់ធ្វើម្ហូបនៅរោងចក្រ ។ ពេលនោះ មីន បានណែនាំ ខន ឲ្យខំកសាងកម្លាំងសេ.អ៊ី.អាឲ្យកាន់តែច្រើនថែមទៀតនៅក្នុងរោងចក្រគ-៦ ដើម្បីងាយស្រួលចាត់តាំងកម្លាំងទាំងអស់

នេះឲ្យអនុវត្តតាមផែនការផ្សេងៗ ដើម្បីប្រឆាំងនិងបដិវត្តន៍ ។ បន្ទាប់មក ខន បានកសាងឈ្មោះ យ៉ង់ ប្រធានផ្នែកនៅរោងចក្រត-៦ និងឈ្មោះ ភឿង អនុប្រធានផ្នែកនៅរោងចក្រត-៦ (បច្ចុប្បន្នក្តាប់មិនបាន) ឲ្យចូលក្នុងកម្លាំង សេ.អ៊ី.អា ។ ក្រោយពីបានចូលជាសមាជិក សេ.អ៊ី.អា ហើយ យ៉ង់ និង ភឿង បានធ្វើសកម្មភាពបំផ្លាញខ្មៅខ្វង់ម៉ាស៊ីននៅក្នុងរោងចក្រខូចមួយចំនួន ហើយបានដើរលួចបេះដូង ខ្ទរនៅកន្លែងផ្សេងៗ នៅក្បែររោងចក្រ និងធ្វើឲ្យកើតមានទំនាស់ពីរោងចក្រមួយទៅរោងចក្រមួយទៀត ។

ឆ្នាំ១៩៧៦ ឈ្មោះ អន ប្រធានខស្សរាហកម្មរដ្ឋ បានចាត់តាំង ខន ចូលជាសមាជិកក្នុងគណៈរោងចក្រត-៦ មានឈ្មោះ ដោក ជាប្រធានរោងចក្រត-៦ និងឈ្មោះ ខ្វីង ជាអនុប្រធានរោងចក្រ ។ កន្លះខែក្រោយមក អន បានហៅបក្សពួកមកប្រជុំមានឈ្មោះ អន, មីន, ដោក, ខ្វីង, ឆាយ ប្រធានរោងចក្រកង់ឡានក-៣, រ៉េន ប្រធានរោងចក្រធ្វើទឹកត្រី, សារូ, សៅ ប្រធានរោងចក្រទឹកដោះគោ, ញឹល ប្រធានរោងចក្រដ-៤ (បច្ចុប្បន្នអង្គការដក), ហ៊ាន ប្រធានរោងចក្រត-១ (បច្ចុប្បន្នអង្គការដក), យុម ប្រធានរោងចក្រត-៥ (បច្ចុប្បន្នអង្គការដក), សន ប្រធានរោងចក្រដ-៧ ឆ្នាំ១៩៧៨ (អង្គការដក), ណយ ប្រធានរោងចក្រដ-៦ ឆ្នាំ១៩៧៨ (អង្គការដក), បាន់ ប្រធានរោងចក្រអំបោះអ-១ ឆ្នាំ១៩៧៧ (អង្គការដក), ខន និង វីន ប្រធានរោងចក្រកង់ឡានក-១ ឆ្នាំ១៩៧៨ (អង្គការដក) ។ គោលបំណងសំខាន់នៃការប្រជុំនេះគឺឲ្យខ្សែរយៈ សេ.អ៊ី.អា ទាំងអស់បានស្គាល់គ្នាទៅវិញទៅមក និងដាក់ផែនការឲ្យសមាជិកទាំងអស់អនុវត្តតាមមុខសញ្ញានីមួយៗផង ។ ផែនការដែល អនដាក់ចុះនោះរួមមាន៖ ទី១ ត្រូវខិតខំធ្វើយ៉ាងណាកសាងកម្លាំង សេ.អ៊ី.អា នៅតាមរោងចក្រនីមួយៗឲ្យបានច្រើន ដើម្បីធ្វើសកម្មភាពនៅក្នុងរោងចក្រ និងត្រៀមកម្លាំងរង់ចាំអនុវត្តតាមផែនការដាក់ចុះពីថ្នាក់លើ ទី២ ត្រូវប្រមូលផលស្រូវ អង្ករ និងកាំភ្លើងដែលនៅសល់តាមផ្ទះក្បែររោងចក្រ និងប្រមូលជ្រូក មាន់ ទា ដើម្បីត្រៀមទុកសម្រាប់ផែនការយូរអង្វែង និងទី៣ ត្រូវបំផ្លាញគ្រឿងចក្រ និងសម្ភារដែលផលិតបាននៅតាមរោងចក្រនីមួយៗ ដើម្បីឲ្យបដិវត្តន៍ហិនហោចជាបណ្តើរៗ ហើយត្រូវថែរក្សាការសម្ងាត់ទាំងការនិយាយស្តី ទាំងការអនុវត្តសកម្មភាពផ្សេងៗ គឺត្រូវប្រុងប្រយ័ត្នកុំឲ្យបែកការណ៍ឲ្យសោះ ។

ខែកុម្ភៈ ឆ្នាំ១៩៧៦ ដោក, ខ្វីង និង ខន បានចាត់តាំងកម្លាំងកម្មករក្នុងរោងចក្រឲ្យដើរប្រមូលអង្ករ ស្រូវ អំបិល ប្រហុក និងសម្ភារផ្សេងៗមួយចំនួនទៀត យកមកលាក់ទុកនៅក្នុងផ្ទះឈើមួយក្រោយរោងចក្រត-៦ ។ ខែមីនា ឆ្នាំដដែល អន បានហៅបក្ខពួកប្រជុំម្តងទៀតនៅសាលាបើកវគ្គរៀនសូត្រនយោបាយរបស់ក្រសួងខស្សរាហកម្មរដ្ឋដែលមានសមាជិកចំនួន២៣នាក់ចូលរួម ។ ខ្លឹមសារនៃអង្គប្រជុំគឺបានណែនាំជំរុញឲ្យសមាជិក សេ.អ៊ី.អា ទាំងអស់អនុវត្តការងារតាមផែនការចាស់ និងទទួលផែនការថ្មីមួយទៀត គឺត្រៀមធ្វើរដ្ឋប្រហារវាយរំលំអង្គការបដិវត្តន៍ ។ ដូចនេះសមាជិក សេ.អ៊ី.អា ទាំងអស់ត្រូវត្រៀមខ្លួនរៀបចំកម្លាំងរង់ចាំអនុវត្តផែនការថ្មីនេះឲ្យបានជោគជ័យ ។

ចុងខែមេសា ឆ្នាំ១៩៧៦ ដោក បានទៅប្រជុំនៅសាលានយោបាយរបស់ក្រសួងខស្សរាហកម្ម ពេលត្រឡប់មកវិញបានរាយការណ៍ប្រាប់ ខន អំពីផែនការធ្វើរដ្ឋប្រហារនៅខែមេសា ឆ្នាំ១៩៧៦នេះត្រូវផ្អាកធ្វើសកម្មភាពវិញ ហេតុនេះសូមឲ្យសមាជិកទាំងអស់រក្សាការសម្ងាត់នេះឲ្យជិត កុំឲ្យបែកការណ៍ឲ្យសោះ ហើយត្រូវនាំគ្នាធ្វើសកម្មភាពតាមផែនការចាស់ជាបន្តទៀត ចំណែកស្បៀងដែលរៀបចំទុកត្រៀមបម្រុងធ្វើនោះគួរយកទៅប្រើប្រាស់តាមអង្គភាពវិញចុះ ។ ក្រោយមកទៀត ខន និងបក្សពួកនៅរោងចក្រត-៦ បានរួមគ្នាធ្វើសកម្មភាព បំផ្លាញអំបោះសម្រាប់ត្បាញខូចអស់មួយចំនួន លួចមួលបន្ទរបាឡុងកីតម្បាញធ្វើឲ្យកីតម្បាញឈប់ដំណើរការជាហូរហែតរៀងមក ។

ប្រាំខែបន្ទាប់ពីផែនការធ្វើរដ្ឋប្រហារ ត្រូវបានថ្នាក់លើឲ្យផ្អាកសកម្មភាពមក ដោក បានទៅប្រជុំនៅសាលានយោបាយរបស់ក្រសួងខស្សរាហកម្មរដ្ឋម្តងទៀត ។ ពេលត្រឡប់មកពីប្រជុំវិញ ដោក បានហៅ ខន, ខ្វីង និងបក្ខពួកមករាយការណ៍ពីផែនការដែលខ្លួនបានទទួលពីថ្នាក់លើ គឺឲ្យខ្សែរយៈ សេ.អ៊ី.អា នៅតាមរោងចក្រទាំងអស់ត្រូវខិតខំកសាងកម្លាំងឲ្យបានកាន់តែច្រើនថែមទៀត និងត្រៀមសម្ភារបរិក្ខារផ្សេងៗ ដើម្បីចូលរួមធ្វើរដ្ឋប្រហារនៅខែកញ្ញា ឆ្នាំ១៩៧៦នេះ ។

ពេលកំណត់ធ្វើរដ្ឋប្រហារបានមកដល់ ខន និងបក្ខពួកទាំង

អស់រង់ចាំបញ្ជាពីថ្នាក់លើដើម្បីធ្វើសកម្មភាព តែស្ថានការណ៍បានប្រែប្រួល ។ ដោក បានមកប្រាប់បក្ខពួករបស់ខ្លួនថា ផែនការធ្វើរដ្ឋប្រហារត្រូវផ្អាកវិញ ព្រោះសភាពការណ៍មិនអំណោយផល ដោយសារអង្គការបានចាប់បក្ខពួករបស់យើងអស់មួយចំនួន បើយើងនៅតែជម្នះធ្វើវានាំឲ្យបរាជ័យ និងខូចខាតកម្លាំងរបស់យើងថែមទៀត ។ ចំពោះការងាររបស់យើងតទៅថ្ងៃមុខគឺយើងនៅតែបន្តអនុវត្តផែនការចាស់របស់យើងដដែលដោយខិតខំកសាងកម្លាំងបន្ថែមទៀត ហើយធ្វើសកម្មភាពបំផ្លិចបំផ្លាញសម្ភារនៅក្នុងរោងចក្រតាមលទ្ធភាពដែលអាចធ្វើទៅបាន ការអនុវត្តផែនការផ្សេងៗ ត្រូវប្រុងប្រយ័ត្នគ្រប់ពេលវេលា ត្រូវចេះរក្សាការសម្ងាត់ កុំឲ្យបែកការណ៍ ដើម្បីការពារកម្លាំងរបស់យើងឲ្យបានគង់វង្សយូរអង្វែង ។

ចុងខែមករា ឆ្នាំ១៩៧៧ ដោក បានទៅប្រជុំនៅសាលានយោបាយរបស់ក្រសួងឧស្សាហកម្មរដ្ឋ ពេលល្ងាចទើបត្រឡប់មករោងចក្រត-៦វិញ ហើយបានហៅ ខន និង ខ្វីង មកប្រជុំនៅផ្ទះឈើទល់មុខរោងចក្រត-៦ ។ ដោក បាននិយាយថា «យើងជួបគ្នានេះដើម្បីជម្រាបអំពីផែនការដែល បងអន ដាក់មក គឺផែនការធ្វើរដ្ឋប្រហារនៅខែ៤ ឆ្នាំ១៩៧៧ ខាងមុខនេះ ។ បងអន បានណែនាំថា នៅតាមរោងចក្រនីមួយៗត្រូវត្រៀមកម្លាំងចាំយកអាវុធពីឃ្លាំងរបស់ក្រសួងឧស្សាហកម្ម ។ យើងវាយយកភ្នំពេញតែម្តង គឺវាយតាមមុខសញ្ញារោងចក្រត-៤ ដែលមានកម្លាំងសេ.អ៊ី.អារបស់យើងឈ្មោះ សារ៉ែន ជាប្រធានរោងចក្រចូលរួម ។ ក្រៅពីមុខព្រួញយើង និងរោងចក្រត-៤ ត្រូវសហការជាមួយរោងចក្រកង់ឡានក-១, ក-២ រោងចក្រថ-១, ថ-២ រោងចក្រដ-៤ រោងចក្របារីប-៤ រោងចក្រដ-៥ រោងចក្រម-១ រោងចក្រដ-៨ រោងចក្រត-៥ រោងចក្រក-៣ ដើម្បីរួមគ្នាវាយតាមផ្លូវចាក់អង្រែសំដៅទៅវិមានឯករាជ្យ និងវាយហួសសំដៅទៅវត្តភ្នំ ។ ដូចនេះតាមរោងចក្រនីមួយៗត្រូវត្រៀមស្បៀងដើម្បីឧបត្ថម្ភដល់កម្លាំងរបស់យើងពេលធ្វើរដ្ឋប្រហារនេះ» ។

ក្រោយពីទទួលផែនការពី ដោក រំលងបានមួយថ្ងៃ ខន បានប្រជុំជាមួយសមាជិករបស់ខ្លួននៅរោងចក្រត-៦ មានឈ្មោះ ភឿង, ឡុង, លីម, ដាន, កេន, រុន, យ៉ង់, វុធ, សុង, លុន និង ហេង ហើយបានរាយការណ៍ប្រាប់ទៅសមាជិកក្នុងក្រុមអំពីផែនការធ្វើរដ្ឋប្រហារក្នុងខែ៤ ឆ្នាំ១៩៧៧ ។ ខន និងបក្ខពួកបានត្រៀមខ្លួន និងត្រៀមស្បៀងជាស្រេច រង់ចាំអនុវត្តផែនការធ្វើរដ្ឋប្រហារផ្តួលរំលំអង្គការបដិវត្តន៍ នៅខែ៤ ឆ្នាំ១៩៧៧នេះ ។ ប៉ុន្តែផែនការធ្វើរដ្ឋប្រហារលើកនេះនៅតែមិនបានសម្រេចដាដដែល ព្រោះថ្នាក់លើបានឲ្យផ្អាកធ្វើសកម្មភាពមួយរយៈសិន ។ ចំណែកឯផែនការចាស់គឺនៅបន្តធ្វើសកម្មភាពធម្មតា ។ ស្របពេលនោះដែរ អន បានចាត់តាំង ខន ឲ្យធ្វើជាប្រធានរោងចក្រកែវក-១០ នៅខាងលិចបឹងជើងឯក ។ ចំណែក ដោក ធ្វើជាប្រធានរោងចក្រត-៧, រីឯ ខ្វីង ធ្វើជាប្រធានរោងចក្រត-៦ ។ មួយរយៈក្រោយ មក ខន កសាងកម្លាំងសេ.អ៊ី.អាបានពីរនាក់មួយឈ្មោះ សែ ប្រធានក្រុមរំលាយកែវ កាន់ឡមួយគោន និងមួយទៀតឈ្មោះ កុច ប្រធានក្រុមខាងក្រឡឹងពុម្ពកែវ ។

ចុងខែកក្កដា ឆ្នាំ១៩៧៧ អន បានហៅ ខន និងបក្ខពួកប្រជុំនៅផ្ទះថ្មខាងជើងមន្ទីរឧស្សាហកម្មរដ្ឋ ។ អ្នកចូលរួមប្រជុំមានឈ្មោះ អន, ណយ, លន, មីន, វីន, ដោក, យុម, ខ្វីង, វ៉េន, ឆាយ, សៅ, វ៉ុន, សារូ, បាន់, ហ៊ាន, សារ៉ែន, ពត, ដៃ, ផល, ញិល, គាត ប្រធានឃ្លាំងឧស្សាហកម្មរដ្ឋ, ខុន ប្រធានរោងចក្រកង់ឡានក-១ ខែ១ ឆ្នាំ១៩៧៨ (អង្គការដក), សារឿន ប្រធានរោងចក្រដ-៨, និងសមាជិកពីរនាក់ទៀតម្នាក់ជាប្រធានរោងចក្រកង់ឡានក-៤ និងម្នាក់ទៀតជាប្រធានរោងចក្រក្រឡឹងដែក ដ-២ ។ ក្នុងអង្គប្រជុំនោះ អន បាននិយាយថា «ខ្ញុំអញ្ជើញមិត្តទាំងអស់គ្នាមកប្រជុំនេះគឺដើម្បីជំរាបអំពីផែនការដែលត្រូវអនុវត្តមានដូចតទៅ៖ ១-ត្រូវត្រៀមកម្លាំងដែលកសាងបានហើយ ឲ្យម្ចាស់ការជាស្រេចដើម្បីត្រៀមធ្វើរដ្ឋប្រហារនៅខែ៩ ឆ្នាំ១៩៧៧នេះ ។ កម្លាំងដែលចូលរួមធ្វើរដ្ឋប្រហារនេះមានកម្លាំងទ័ពមកពីវៀតណាមចូលរួមផងរួមនឹងកម្លាំងតាមភូមិភាគមួយចំនួនធំ ។ ចំពោះសមាជិកនៅតាមរោងចក្រនានា ត្រូវត្រៀមកម្លាំង និងស្បៀងដើម្បីម្ចាស់ការក្នុងការអនុវត្តផែនការរបស់យើងឲ្យបានសម្រេច ។ ចំពោះអាវុធចាំដល់ពេលអនុវត្តផែនការសឹមចែកគ្នា ធ្វើដូចនេះដើម្បីរក្សាការសម្ងាត់ ចៀសវាងនាំឲ្យបែកការណ៍ដោយប្រការណាមួយ ព្រោះអង្គការអត់ឲ្យមានទុកអាវុធប្រើប្រាស់នៅក្នុងរោងចក្រទេ ។ ឯមុខ

ព្រួញដែលត្រូវវាយ បានបែងចែកជាបីផ្នែក ទី១ វាយតាមផ្លូវចាក់អង្រែបុកចំវិមានឯករាជ្យ និងវាំង ហើយវាយឡើងទៅចាប់ដៃគ្នានៅវត្តភ្នំមុខព្រួញនេះមាន មិត្តសន និង មិត្តមីន ជាអ្នកដឹកនាំ ។ មុខព្រួញទី២ វាយតាមផ្លូវគីឡូម៉ែត្រលេខ៦សំដៅទៅចាប់ដៃគ្នានៅវត្តភ្នំ មុខព្រួញនេះដឹកនាំដោយមិត្តវីន និងមិត្តដោក ។ រីឯមុខព្រួញទី៣ គឺវាយតាមផ្លូវពោធិ៍ចិនតុង និងផ្លូវស្ទឹងមានជ័យ វាយបុកសំដៅទៅចាប់ដៃគ្នានៅវត្តភ្នំដែរ មុខព្រួញទី៣ នេះដឹកនាំដោយ មិត្តណយ មិត្តហ៊ាន និងមិត្តខន» ។ អន បានណែនាំបន្ថែមថា «ពេលវេលាកំណត់ផ្ទុះអាវុធគឺត្រូវចាំស្តាប់បញ្ជាពីថ្នាក់លើបើឲ្យវាយសឹមវាយ» ។ ក្តាប់ផែនការរួចហើយអង្គប្រជុំក៏បានរំសាយ ហើយបំបែកផ្លូវទៅកន្លែងរៀងៗខ្លួន ។ ខន បានយកផែនការខាងលើមករាយការណ៍ប្រាប់សមាជិកក្នុងក្រុមសេ.អ៊ី.អារបស់ខ្លួនឲ្យត្រៀមលក្ខណៈចាំចូលរួមអនុវត្តតាមផែនការខាងលើនេះ ។

ខែធ្នូឆ្នាំ១៩៧៧ ខន បានទៅជួប ណយ នៅក្បាលថ្នល់ហើយបានសួរនាំអំពីផែនការធ្វើរដ្ឋប្រហារ ។ ណយ បាននិយាយថា ចំពោះរឿងនេះថ្នាក់លើនៅមិនទាន់មានយោបល់ថាយ៉ាងម៉េចនៅឡើយទេ យើងនៅតែត្រៀមរង់ចាំអនុវត្តតាមផែនការជានិច្ច ។ ទន្ទឹមនឹងនេះ យើងនៅតែបន្តធ្វើសកម្មភាពតាមផែនការចាស់របស់យើងដដែល» ។

ខែមករា ឆ្នាំ១៩៧៨ ខន បានទៅជួប ណយ ដើម្បីសួរនាំអំពីផែនការធ្វើរដ្ឋប្រហារ ។ ណយ បាននិយាយថា នៅថ្នាក់លើស្ងាត់ឈឹងអត់ទាន់មានមតិយ៉ាងម៉េចទេ ផែនការរបស់យើងប្រហែលជាផ្អាកទៀតហើយ ។ ដូច្នេះយើងទាំងអស់គ្នាត្រូវត្រៀមចាំក្តាប់មតិពីខាងលើឲ្យជាប់ បើមានសភាពការណ៍ប្រែប្រួលយ៉ាងណានោះ យើងនឹងប្រាប់ឲ្យអ្នកទាំងអស់គ្នាបានដឹង ។ ចុងខែមករា ណយ បានហៅសមាជិកមកប្រជុំ ។ ពេលនោះ អន បាននិយាយថា កន្លងមកផែនការធ្វើរដ្ឋប្រហាររបស់យើងមិនបានសម្រេចម្តងណាសោះ ព្រោះសមាជិករបស់យើងមិនទាន់ម្ចាស់ការខ្ពស់ក្នុងការកសាងកម្លាំងឲ្យបានធំធេង និងរឹងមាំនៅឡើយ ។ ម្យ៉ាងទៀតពីងលើកម្លាំងទ័ពវៀតណាមវាយពីខាងក្រៅក៏វាយចូលមិនចុះដែរ ស្ថានភាពមិនសូវអំណោយផលដូច្នេះ ថ្នាក់លើមិនឲ្យយើងធ្វើសកម្មភាពទេ» ។ ពេលថ្មីៗនេះថ្នាក់លើបានលើកផែនការធ្វើរដ្ឋប្រហារផ្តួលរំលំបក្សកុម្មុយនីស្តកម្ពុជាម្តងទៀត ដែលរៀបចំធ្វើនៅថ្ងៃបុណ្យខួប១៧មេសា ឆ្នាំ១៩៧៨ ។ កងទ័ពដែលមានភារកិច្ចវាយភ្នំពេញគឺនៅរក្សាទម្រង់ដូចកាលពីលើកមុនដដែលមិនមានការផ្លាស់ប្តូរទេ និងមានទ័ពមកពីខាងបូព៌ាមួយចំនួនទៀតត្រូវវាយបុកតាមផ្លូវជាតិលេខ១សំដៅមកភ្នំពេញ ។ ផែនការលើកនេះសូមឲ្យមិត្តយើងទាំងអស់គ្នារក្សាការសម្ងាត់ឲ្យបានល្អ ដើម្បីការពារកម្លាំងរបស់យើង និងអនុវត្តឲ្យបានសម្រេចទៅតាមផែនការរបស់ថ្នាក់លើ ។

ខែវិច្ឆិកា ឆ្នាំ១៩៧៨ ខន បានហៅ ឈន និង យ៉េន មកប្រជុំនៅផ្ទះរបស់ខ្លួនផ្ទាល់នៅខាងត្បូងរោងចក្រកែវ ។ ខន បាននិយាយថា ឥឡូវនេះថ្នាក់លើបានផ្តោតការយកចិត្តទុកដាក់លើការប្រុងប្រយ័ត្នរក្សាការសម្ងាត់ឲ្យបានដាច់ខាត និងត្រូវខំពង្រឹងកម្លាំងនៅតាមផ្នែកដែលជាកម្លាំងចាស់ឲ្យចេះរក្សាការសម្ងាត់ឲ្យមែនទែន ព្រោះបើមានការធ្វេសប្រហែសនៅកន្លែងណាមួយ វានាំឲ្យប៉ះពាល់ដល់កម្លាំងរបស់យើងនៅកន្លែងផ្សេងៗទៀត ក៏ដូចជាប៉ះពាល់ដល់ផែនការធ្វើរដ្ឋប្រហាររបស់យើងនៅដើមឆ្នាំ១៩៧៩ ។ ផែនការធ្វើរដ្ឋប្រហារដើមឆ្នាំ១៩៧៩នេះ ជាផែនការផ្តាច់ព្រ័ត្រ ដូច្នេះយើងត្រូវណែនាំកម្លាំងរបស់យើងឲ្យបង្កើនការប្រុងប្រយ័ត្ន រក្សាការសម្ងាត់ឲ្យបានខ្ពស់ដាច់ខាត ។ ចាប់ពីពេលនោះ ខន និង ហ៊ាន មិនឲ្យកម្លាំងរបស់ខ្លួនធ្វើសកម្មភាពអ្វីធំដុំនៅក្នុងរោងចក្រកែវទេ ព្រោះត្រៀមខ្លួនចាំចូលរួមធ្វើរដ្ឋប្រហារតែម្តង ។ ពាក់កណ្តាលខែវិច្ឆិកា ខន បានទៅរកជួប ណយ ដើម្បីសាកសួរពីសភាពការណ៍ផ្សេងៗ និងផែនការរដ្ឋប្រហារនៅរដូវរំហើយឆ្នាំ១៩៧៩នេះ តែ ខន មិនបានជួប ណយ ទេ ។ ក្រោយមក អង្គការបានប្រកាសចាត់តាំងគណៈកម្មការក្រសួងឧស្សាហកម្មថ្មី ពេលនោះគ្មានវត្តមានរបស់ អន ចូលរួមប្រជុំទេ ។

ដោយឡែក ខន ត្រូវអង្គការចាប់ខ្លួនបាននៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ។ ចម្លើយសារភាពរបស់ ខន ត្រូវបានវាយអង្គុលីលេខមានចំនួន៤៥ទំព័រ ធ្វើនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៨ ។ នៅចុងបញ្ចប់នៃចម្លើយសារភាព មានចុះហត្ថលេខា និងស្នាមផ្តិតមេដៃរបស់ ខន និងចុះហត្ថលេខាដោយអ្នកសួរចម្លើយ ឈ្មោះ ជាវ៉េត ចុះកាលបរិច្ឆេទថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៨ ។

**ឆេង ម៉េង**

# មីឆែលស្កុត ឌីដស៍ ភ្នាក់ងារសម្ងាត់ សេ.អ៊ី.អា របស់អាមេរិក ជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខស-២១

*ដកស្រង់ចេញពីចម្លើយសារភាព D០៧១៨៣*

មីឆែលស្កុត ឌីដស៍ ជាជនជាតិអាមេរិក កើតនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៤៩ នៅទីក្រុងឡុងបិច រដ្ឋកាលីហ្វ័រញ៉ា ។ នៅផ្ទះម្តាយរបស់គាត់បាននិយាយអំពីគ្រោះថ្នាក់នៃបក្សកុម្មុយនីស្ត ដែលប្រឆាំងទៅនឹងសាសនាកាតូលិក ព្រោះម្តាយគាត់ជឿទៅលើសាសនាកាតូលិក ហើយគាត់បន្ថែមទៀតថាគ្រោះថ្នាក់ដល់សាសនានេះក៏ដូចជាគ្រោះថ្នាក់ដល់អាមេរិកដែរ ។ មីឆែលស្កុត ឌីដស៍ បានរៀននៅវិទ្យាល័យ វូដ្រូវិលសុន នៅឆ្នាំ១៩៦៤-១៩៦៧ ។ នៅសាលានេះក្នុងមុខវិជ្ជាដែលសិក្សាអំពីបញ្ហាសកលលោក និងភូមិសាស្ត្រ គាត់ត្រូវបានអប់រំឲ្យស្អប់កុម្មុយនីស្តដោយបានលើកហេតុផលគំរាមកំហែងទៅទៅលើសិទ្ធិសេរីភាពនិយាយបញ្ចេញមតិជំនឿសាសនាផ្សេងៗជាច្រើនទៀត ហើយការរស់នៅក៏ផ្ទុយស្រឡះពីសហរដ្ឋអាមេរិក ។ ទាំងការអប់រំនៅសាលា ក៏ដូចជា



នៅផ្ទះ ហើយការនិយាយប្រាប់ពីចាស់ទុំនៅទីកន្លែងផ្សេងៗ បានធ្វើឲ្យគាត់មានការស្អប់កុម្មុយនីស្តកាន់តែខ្លាំង ។ នៅពេលដែលចប់វិទ្យាល័យមានអាយុ១៨ ឆ្នាំគាត់បានចូលក្នុងកងកម្លាំងជំនួយរបស់កងទ័ពជើងទឹក និងបានហ្វឹកហ្វឺនរយៈពេល៦ខែ ។ លុះក្រោយមកគាត់បានជិះយន្តហោះទៅនៅរដ្ឋវើរជីនីញ៉ា ហើយរៀនមើលផែនទី ។ លើសពីនេះទៅទៀត គាត់ត្រូវបានបង្រៀនឲ្យដឹងអំពីគោលបំណងមូលដ្ឋានរបស់ សេ.អ៊ី.អា ថែមទាំងសិក្សាលើលំនឹងកងទ័ពរវាងប្រទេសទាំងឡាយ ហើយនិងការពារតំបន់មួយចំនួន ដែលជាតំបន់យុទ្ធសាស្ត្រមានសារសំខាន់សម្រាប់អាមេរិក រួមទាំងរៀនប្រើអាវុធថែមទៀត ។ បន្ទាប់មកទៀតគាត់បានទៅហ្វឹកហ្វឺនបន្ថែមនៅបន្ទាយ ប៊ុនឌិលគុន នៅរដ្ឋកាលីហ្វ័រញ៉ា ។ នៅទីនោះ គាត់មានការហ្វឹកហ្វឺនគ្រប់ជំនាញក្នុងនោះរួមមាន៖

◆ ការបណ្តែតខ្លួននៅលើទឹកឲ្យបាន ៣ម៉ោង ។



◆ ហែលទឹកឲ្យបាន១៦០០ម៉ែត្រ ។
◆ រៀនបាញ់ឲ្យស្ទាត់ទាំងកាំភ្លើងវែង-ខ្លី ។
◆ ដើរឆ្លងឧបសគ្គដោយកំណត់ពេល ។
◆ រស់នៅក្នុងព្រៃមួយសប្តាហ៍ដោយគ្មានអ្វីទាំងអស់ ។
◆ លូនក្រោមលោតផ្លោះឡើងជញ្ជាំងជាដើម-ល- ។

លុះក្រោយពេលបញ្ចប់ការហ្វឹកហ្វឺនអស់រយៈពេល៨សប្តាហ៍ ក៏មានការធ្វើសេចក្តីថ្លែងការណ៍អំពីភារកិច្ច និងមុខងារដែលត្រូវបំពេញជូន សេ.អ៊ី.អា នៅថ្ងៃក្រោយ ។ បន្ទាប់មក មីឆែល បានទៅរៀននៅសាលាចារកម្ម និងប្រតិបត្តិការនៅវ៉ាស៊ីនតោន ។ គាត់បានរៀនថែមទៀតអំពីមធ្យោបាយរបស់ សេ.អ៊ី.អា ស៊ើបអង្កេតយកការណ៍នៅតំបន់ណាដែលត្រូវដាក់ភ្នាក់ងារបន្កប់មិនឲ្យគេចាប់អារម្មណ៍ ហើយគេចពីការតាមដាន ។ ក្រៅពីនេះ មីឆែល រៀនដំឡើងស្ថានីយ៍តាមដានអង្កេតការណ៍ក្នុងឡាន និងបន្ទប់ ។ ក្រោយមក មីឆែល រៀនពីទ្រឹស្តី រួមទាំងគោលដៅរបស់ សេ.អ៊ី.អា ដែលទាក់ទងទៅនឹងគោលនយោបាយប្រឆាំងទប់ទល់ទៅនឹងកុម្មុយនីស្តទាំងអស់ ជាពិសេសទប់ទល់ទៅនឹងឥទ្ធិពលសូវៀត និងចិន ។ អាមេរិកពេលនោះ ក៏មានការព្រួយបារម្ភទៅលើស្ថានភាពនៅប្រទេសគុយបា ព្រោះបារម្ភថា សូវៀតផ្តល់បរមាណូដល់គុយបាសាជាថ្មី ។

បន្ទាប់ពីបានឆ្លងកាត់ការហ្វឹកហ្វឺនហើយ និងបេសកម្មជាបន្តបន្ទាប់ជាច្រើនរួចមក មីឆែល បានរំពឹងទុកថានឹងបានឡើងស័ក្តិធំជាងមុន ។ ស័ក្តិទាំងនោះមានចាប់ពី អ១ ដល់ អ១១ ដែលមានមុខងារផ្សេងៗគ្នា ។ មីឆែល បានបញ្ជាក់ទៀតថា ឋានៈពី អ៩ ដល់ អ១១ គឺមានការតែងតាំងដោយប្រធានាធិបតីសហរដ្ឋអាមេរិក ។ ដោយសារក្មេងពេកហើយមិនមានបទពិសោធគ្រប់គ្រាន់ផង គាត់មិនត្រូវបានជ្រើសទៅធ្វើប្រតិបត្តិការក្រៅប្រទេសនោះទេ ។

ក្រោយពេលបញ្ចប់វគ្គបណ្តុះបណ្តាល គាត់ក៏ត្រឡប់ទៅរដ្ឋកាលីហ្វ័រញ៉ាវិញ ដោយរង់ចាំក្រសួងហៅទៅ ហើយក្រសួងបានបង់ប្រាក់ឲ្យរៀននៅមហាវិទ្យាល័យនៃទីក្រុងឡុងប៊ិច ដោយផ្តល់ប្រាក់ខែ៣០០ដុល្លារ សម្រាប់ការរស់នៅប្រចាំថ្ងៃ ។ ភារកិច្ចពេលនោះ គឺគាត់ត្រូវតាមដានអង្គការ និស្សិតជឿនលឿនដែលប្រឆាំងគោលនយោបាយរបស់រដ្ឋាភិបាលអាមេរិក ។

លុះក្រោយមក សវយើរ (មេបញ្ជាការម្នាក់) បានហៅ មីផែល ឲ្យទៅជួបដើម្បីពិភាក្សាអំពីបេសកកម្មរបស់ខ្លួន ។ ដំបូង គឺគាត់ទៅយកទូកក្តោងនៅទីក្រុង ម៉ានីល ជាមួយនឹងមិត្តរបស់គាត់ម្នាក់ឈ្មោះ គ្រីស ឌីឡាន់ ។ បេសកម្មរបស់ មីផែល គឺមកស៊ើបការណ៍នៅតាមបណ្តោយព្រំដែនយួន-កម្ពុជា តាមរយៈការថតរូប និងដំឡើងឧបករណ៍ទាក់ទងផ្តល់សញ្ញា តាមរយៈសំឡេងទៅលើគោក និងទៅនាវាដែលបើកបរនៅឈូងសមុទ្រប្រទេសថៃ ។ ការប្រើប្រាស់ទូកក្តោង គឺដោយសារមិនឲ្យមានសំឡេងរំខាន ដែលជាហេតុបណ្តាលឲ្យមានការចាប់អារម្មណ៍ ។

មីផែល បានឲ្យដឹងទៀតថា សេ.អ៊ី.អា បានមករៀបចំបណ្តាញបន្តប់នៅកម្ពុជាដើម្បីស៊ើបការណ៍ស្ថានភាពយោធាចលនារបស់យោធា ព្រមទាំងស្ថានភាពផ្សេងៗដើម្បីវាយចាត់វិធានការណ៍ចំពោះកម្ពុជា ។ ក្រុមប្រតិបត្តិនៅកម្ពុជាលើកនេះ គឺក្រុម អ៧ ដែលជាមជ្ឈមណ្ឌលស៊ើបការណ៍នៅកម្ពុជា ។ ក្តីបារម្ភធំរបស់ជាអាមេរិកគឺខ្លាចតំបន់អាស៊ីអាគ្នេយ៍ត្រូវធ្លាក់ទៅក្នុងដៃរបស់បក្សកុម្មុយនីស្តហើយធ្វើការគំរាមកំហែងដល់នាវាចរណ៍របស់ខ្លួន ។ ជាពិសេសការពារប្រទេសថៃកុំឲ្យមនោគមវិជ្ជាកុម្មុយនីស្តចូលទៅបំផ្លាញលទ្ធិប្រជាធិបតេយ្យនៅទីនោះ ព្រោះថាកម្ពុជាគឺជាគន្លឹះសម្រាប់បក្សកុម្មុនីស្តឈ្លានពានទៅលើប្រទេសផ្សេងទៀត ហើយអាមេរិកក៏មិនត្រូវព្រងើយកន្តើយជាមួយកម្ពុជាយូរពេកដែរ ។ ចំណុចដែលគាត់ត្រូវអង្កេតនៅកម្ពុជា គឺចលនាយោធា ជាពិសេស នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ បើសិនជាចាំបាច់ត្រូវរៀបចំការប្រយុទ្ធធំនៅតំបន់នេះ ។ មួយវិញទៀត គឺឆ្លើយតបទៅនឹងការគំរាមកំហែងនៅតំបន់ជ្រោយម៉ាឡាកា ដែលទាក់ទងទៅនឹងនាវាចរណ៍ដែលត្រូវទាមទារឲ្យ សេ.អ៊ី.អា របស់អាមេរិក ត្រូវតែមានសកម្មភាព និងជ្រៀតជ្រែកអំពីបញ្ហាកម្ពុជា និងយួន ដដែល ដរាបណាការគំរាមកំហែងទាំងនោះត្រូវបានបញ្ចប់ ។

កាលណាកាលៈទេសៈ ឬសភាពការមិនអំណោយផលដល់សហរដ្ឋអាមេរិកក្នុងការវាយមកលើកម្ពុជានៅគ្រប់ពេលដែលគំរាមកំហែងទៅលើជ្រោយម៉ាឡាកា ពេលនោះអាមេរិកនឹងប្រើគ្រប់មធ្យោបាយទាក់ទាញប្រទេសដែលទទួលប្រយោជន៍ពីតំបន់នេះឲ្យជួយបើកយុទ្ធនាការវាយតាមផ្លូវទឹកមកកម្ពុជាដើម្បីកុំឲ្យកម្ពុជារឹងមាំបាន ។ លើសពីនេះទៅទៀត និងត្រៀមវិធានការទប់ទល់ គឺបង្កើតអង្គការមួយតំណាងប្រទេសទាំងអស់ដើម្បីត្រួតពិនិត្យប្រសិនបើមានការគំរាមកំហែងមែននោះ គឺត្រូវបិទពាណិជ្ជកម្មជាមួយកម្ពុជាកុំឲ្យប្រទេសនេះនាំវត្ថុធាតុដើម ឬប្រេងឥន្ធនៈ ដើម្បីទប់ស្កាត់កុំឲ្យរីកចម្រើនផ្នែកយោធា ។ ក្នុងនោះដងដែរ បានបញ្ជាក់ថា សកម្មភាព សេ.អ៊ី.អា អាចបង្កើតជាបញ្ហាទំនាក់ទំនងរវាងសូវៀតនិង ចិន ។

អាមេរិកមិនចង់វាយកម្ពុជាដោយសារតែកម្ពុជាមានទំនាក់ទំនងល្អជាមួយចិន ហើយរវាងអាមេរិក និង ចិន កន្លងមក កំពុងតែមានទំនាក់ទំនងមិនល្អផង នោះនិយាយរួម គឺនៅអំឡុងពេលនោះអាមេរិកមានទំនាក់ទំនងជាមួយចិន ។ អ្វីដែលសំខាន់ជាងនេះទៅទៀត បើសិនជាអាមេរិកវាយកម្ពុជា ហើយបង្កើតរដ្ឋាភិបាលនៅក្រោមឥទ្ធិពលរបស់អាមេរិក នោះសូវៀតនឹងប្រឆាំងយ៉ាងខ្លាំងតបទៅអាមេរិកវិញ ។ បើអាមេរិកធ្វើសកម្មភាពរួមជាមួយបណ្តាប្រទេសដែលខ្លួនគៀងគរ នោះម៉ូស្គូច្បាស់ជាមិនសូវមានប្រតិកម្មនោះទេ ។ ដូចនៅទំនាក់ទំនងរវាង អាមេរិក និង ចិន គឺអាស្រ័យទៅតាមអន្តរាគមន៍របស់អាមេរិកប៉ុណ្ណោះ ។

នៅដើមខែវិច្ឆិកា មេបញ្ជាការឈ្មោះ សវយើរ បានបញ្ជាឲ្យមីផែល ធ្វើប្រតិបត្តិការមកប្រទេសកម្ពុជា និងបានរៀបចំសម្ភារដាក់ទូកក្តោង ។ ពេលកំណត់ក៏មកដល់ថ្ងៃទី១៨ វិច្ឆិកា ១៩៧៨ គាត់ក៏ចេញដំណើរទៅដល់ទីក្រុងបាងកក ។ ពេលបើកជិតដល់កម្ពុជាគាត់បានបើកតាមបណ្តោយឈូងសមុទ្រថៃប៉ែកខាងស្តាំ ។ ការបើកទូក គឺបើកទាំងយប់ទាំងថ្ងៃ ហើយត្រូវប្តូរវេនគ្នាបើក ។ លុះដល់ព្រឹកថ្ងៃទី២៤ វិច្ឆិកា ឆ្នាំ១៩៧៨ គឺជាវេនដែល មីផែល បើក ។ គាត់រង់ចាំដល់ គ្រីស ឌីឡាន់ ដេកលក់ទើបតម្រង់ទិសទៅកម្ពុជា ។ នៅពេលនោះ គាត់អង្កេតឃើញដីមួយដុំទម្រង់ដូចកោះ ប៉ុន្តែនោះគឺជានាវារបស់កម្ពុជាដែលបើកល្បាត ។ គាត់ក៏ខំប្រឹងបើកគេចចេញពីនាវា ដែលប្រដាប់ដោយកាំភ្លើងធំ នាវានោះក៏បានប្តូរទិសតាមដែរ ។ នៅពេលនាវាទាហានជើងទឹកបើកចូលមកជិត គាត់ក៏ដាស់ គ្រីស ឌីឡាន់ ឲ្យក្រោកហើយគាត់ទាំងពីរនាក់ក៏ត្រូវបានចាប់ខ្លួននៅក្នុងពេលនោះ ។

**ឌុំ ម៉ាប់**

# មន្ទីរសន្តិសុខខ្នុរចាស់

មន្ទីរសន្តិសុខខ្នុរចាស់ត្រូវបានបង្កើតដោយខ្មែរក្រហមនៅដើមឆ្នាំ១៩៧៦ ។ មន្ទីរសន្តិសុខខ្នុរចាស់ ស្ថិតក្នុងតំបន់២១ នៅភូមិខ្នុរចាស់ ឃុំនាងទើត ស្រុកតំបែរ ខេត្តត្បូងឃ្មុំ (អតីតខេត្តកំពង់ចាម) ។ យោងតាមរបាយការណ៍របស់គម្រោងគូរផែនទីរណ្តៅសាកសពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្ហាញថាមន្ទីរសន្តិសុខខ្នុរចាស់មិនត្រឹមតែជាមន្ទីរសន្តិសុខមួយក្នុងចំណោមមន្ទីរសន្តិសុខទាំង១៩៦ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ប៉ុន្តែ វាក៏ជាកន្លែងកាប់សម្លាប់មួយក្នុងចំណោមកន្លែងកទាំង៧នៅក្នុងស្រុកតំបែរ ។ នៅមុនរបបខ្មែរក្រហមមកដល់ មានប្រជាជនប្រហែល១០គ្រួសារដែលបានរស់នៅកន្លែងមន្ទីរសន្តិសុខនេះ ប៉ុន្តែនៅពេលដែលខ្មែរក្រហមគ្រប់គ្រងអំណាចនៅថ្ងៃ១៧ មេសា ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនឲ្យទៅរស់កន្លែងផ្សេង ដោយយកផ្ទះប្រជាជនធ្វើជាគុក និងកន្លែងអប់រំ ។ ខ្មែរក្រហមបានយកមន្ទីរសន្តិសុខខ្នុរចាស់សម្រាប់ឃុំឃាំង ធ្វើទារុណកម្មសួរចម្លើយ និងសម្លាប់អ្នកទោសដែលត្រូវបានចាប់បញ្ជូនមក ។ តាមរយៈប្រជាជនដែលជាអ្នកភូមិរស់នៅជិតមន្ទីរសន្តិសុខនោះ បានប្រាប់ថាមានសន្តិសុខខ្មែរក្រហមប្រហែលពី១០-២០នាក់ ដែលត្រូវបានចាត់តាំងឲ្យប្រចាំការនៅមន្ទីរសន្តិសុខខ្នុរចាស់ ដែលមាន យិន សុភី ជាប្រធានមន្ទីសន្តិសុខតំបន់២១ ហើយគាត់ក៏ជាមនុស្សម្នាក់ ដែលគ្រប់គ្រងមន្ទីរសន្តិសុខខ្នុរចាស់នេះដែរ ។ អ្នកទោសដែលត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខខ្នុរចាស់ ភាគច្រើនជាប្រជាជនថ្មីដែលត្រូវបានខ្មែរក្រហមជម្លៀសមកពីតំបន់ផ្សេងៗ ហើយមួយចំនួនគឺជាប្រជាជនមូលដ្ឋានដែលត្រូវបានអង្គការចាប់ និងបញ្ជូនពីភូមិឃុំជិតៗដែលស្ថិតនៅក្នុងស្រុកតំបែរ ។ ខ្មែរក្រហមបានអនុវត្តផែនការសម្លាប់ដូចខាងក្រោម ៖


អតីតមន្ទីរសន្តិសុខខ្នុរចាស់ បច្ចុប្បន្នត្រូវបានបោះបង់ចោល និងគ្រប់ដណ្តប់ដោយស្មៅ និងគុម្ពោតព្រៃ

◆ ដំណាក់កាលទី១ ៖ សម្លាប់អ្នកដែលជាប់ទាក់ទងជាមួយនឹងនិន្នាការនយោបាយរបបមុន

◆ ដំណាក់កាលទី២ ៖ សម្លាប់ប្រជាជនជម្លៀស (ប្រជាជនថ្មី) ដែលភាគច្រើនត្រូវបានអង្គការចោទថា ភ្នាក់ងារ សេ.អ៊ី.អា (CIA), កា.ហ្សេ.បេ (KGB) ឬជនក្បត់នឹងអង្គការ

◆ ដំណាក់កាលទី៣ ៖ សម្លាប់ប្រជាជនមូលដ្ឋាន (ប្រជាជនចាស់) ដែលត្រូវបានចោទថា មិនមានភាពស្មោះត្រង់ជាមួយនឹងអង្គការ ឬក៏មិនពេញចិត្តនូវអ្វីដែលអង្គការបានចាត់តាំង ។

◆ ដំណាក់កាលទី៤ ៖ ចាប់ និងសម្លាប់អ្នកដែលជាមន្ត្រីខ្មែរក្រហម និងទាហានខ្មែរក្រហមដែលមានឋានៈ ចាប់ពីប្រធានក្រុមដែលគ្រប់គ្រងទាហានចាប់ពី១០ នាក់ឡើងទៅ ។

អ្នកទោសដែលជាប់ឃុំទាំងអស់ ត្រូវបានបង្អត់អាហារ ដូច្នេះហើយបានជាអ្នកទោសជាច្រើនគ្មានកម្លាំងគ្រប់គ្រាន់សូម្បីតែឈរ ហើយខ្លះក៏បានស្លាប់ ខណៈពេលខ្មែរក្រហមបានបង្ខំឲ្យធ្វើការហួសកម្លាំង ។ ទោះបីជាដឹងថា ខ្មែរក្រហមធ្វើបានប្រព្រឹត្តបែបនេះក៏ដោយ ក៏គ្មាននរណាម្នាក់ហ៊ានប្រកែកនូវអ្វីដែលអង្គការបានចាត់តាំងដែរ ។

ខ្មែរក្រហមមិនអនុញ្ញាតឲ្យប្រជាជនចូលក្នុងមន្ទីរសន្តិសុខខ្នុរចាស់ទេ ហើយបើសិនជាមាននរណាម្នាក់ល្មើសនឹងបម្រាម អ្នកនោះនឹងត្រូវចាប់ខ្លួន និងសម្លាប់ចោលជាមិនខាន ។ នៅយប់មួយកងឈ្លបបានចាប់ និងបណ្តើរមនុស្សចំនួនចាប់ពី៧ទៅ៨នាក់ ដែលត្រូវបានចងរុំភ្នែក និងចងដៃទាំងពីរទៅក្រោយ យកទៅកាន់មន្ទីរសន្តិសុខខ្នុរចាស់នេះ ។ ចាប់តាំងពីពេលនោះមក មនុស្សដែលត្រូវបានកងឈ្លបបណ្តើរទៅនោះមិនដែលត្រឡប់មកភូមិវិញទេ ។ តាមរយៈ អ៊ុំ សឹប ដែលជាប្រជាជនមូលដ្ឋានរស់នៅភូមិចំបក់ (ប្រជាជនចាស់) នៅជំនាន់ខ្មែរក្រហម សព្វថ្ងៃជាអ្នកភូមិរស់នៅភូមិចំបក់ ឃុំនាងទើត ស្រុកតំបែរ ខេត្តត្បូងឃ្មុំ បានឲ្យដឹងថា នៅជំនាន់ខ្មែរក្រហម ពិតជាមានការចាប់ និងការបញ្ជូនមនុស្សទៅមន្ទីរសន្តិសុខខ្នុរចាស់នេះមែន ហើយអ្នកទាំងអស់នោះប្រាកដជាត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខខ្នុរចាស់នេះតែម្តង ។

នៅដើមឆ្នាំ១៩៧៦ ខ្មែរក្រហមបានអនុវត្តនូវផែនការសម្លាប់មួយចំនួនធំដែលភាគច្រើនគឺជាប្រជាជនជម្លៀស ។ មុនពេលសម្លាប់ម្តងៗ ខ្មែរក្រហមតែងតែឲ្យអ្នកទោសជីករណ្តៅ ។ ដោយមិនហ៊ានសួរ ឬក៏ប្រកែកនូវអ្វីដែលអង្គការបានចាត់តាំងនោះ អ្នកទោសនាំគ្នាធ្វើអ្វីទៅតាមខ្មែរក្រហមបញ្ជា ។ បន្ទាប់ពីបានជីករណ្តៅមួយហើយ អ្នកទោសក៏ត្រូវបានខ្មែរក្រហម ចងដៃ និងជើង ហើយខ្មែរក្រហមក៏បានឲ្យអ្នកទោសអង្គុយជាជួរនៅមុខ




ស្តូបរំឭកវិញ្ញាណក្ខន្ធខ្នុរចាស់ ដែលត្រូវបានសាងសង់ឡើង នៅឆ្នាំ២០០២ ស្ថិតនៅក្នុងឃុំន


...ងទើត ស្រុកតំបែរ ខេត្តត្បូងឃ្មុំ

រណ្តៅ ។ បន្ទាប់មកខ្មែរក្រហម ក៏បានវាយសម្លាប់អ្នកទោសទាំងនោះជាមួយនឹងដំបងឈើ ឬ ក៏ពូថៅ ។ ខ្មែរក្រហមបានទម្លាក់សាកសពដែលទើបតែសម្លាប់ថ្មីៗទាំងនោះចូលទៅក្នុងរណ្តៅរួចហើយឲ្យអ្នកទោសផ្សេងទៀតមកកប់រណ្តៅនោះ ។ ខ្មែរក្រហមនៅតែបន្តឲ្យអ្នកទោសជីករណ្តៅដើម្បីកប់ខ្លួនឯងរហូតដល់ចុងឆ្នាំ១៩៧៨ ។ មានរណ្តៅសាកសពជាច្រើនដែលនៅជុំវិញវាលពិឃាតនេះ ហើយក៏មានរណ្តៅតូចធំជាច្រើនដែលអាស្រ័យទៅតាមចំនួនជនរងគ្រោះដែលត្រូវបានសម្លាប់ដោយខ្មែរក្រហម ។ រណ្តៅតូចគឺមានជនរងគ្រោះពី១០ទៅ២០នាក់ ចំណែករណ្តៅធំមានជនរងគ្រោះពី៥០ទៅ១០០នាក់ ។

បន្ទាប់ពីការដួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ សន្តិសុខនៅមន្ទីរសន្តិសុខខ្នុរចាស់នេះត្រូវបានប្រជាជនសម្លាប់ ខណៈពេលដែលមួយចំនួនបានរត់ចូលក្នុងព្រៃ ។ បន្ទាប់មក ប្រជាជនក៏បានរុះរើមន្ទីរសន្តិសុខនេះដើម្បីយកឈើទៅសាងសង់ផ្ទះ ចំណែកអ្នកខ្លះទៀតបានយកទៅធ្វើជាខសសម្រាប់ដុត ។

សព្វថ្ងៃ នៅមន្ទីរសន្តិសុខខ្នុរចាស់មិនមានអ្វីដែលនៅសេសសល់ទេ សូម្បីតែឆ្អឹង-លលាដ៏ក្បាលជនរងគ្រោះ ឬក៏ភ័ស្តុតាងផ្សេងទៀតទាក់ទងនឹងការកាប់សម្លាប់របស់ខ្មែរក្រហម ពីព្រោះពេលវេលាបានកប់នូវអ្វីៗដែលនៅសេសសល់ដោយសារតែកង្វះខាតនៃការថែរក្សា និងការការពារ ។

នៅឆ្នាំ២០០២ ស្តូបរំឭកវិញ្ញាណក្ខន្ធខ្នុរចាស់ត្រូវបានសាងសង់ឡើងដោយរាជរដ្ឋាភិបាលកម្ពុជាដើម្បីឲ្យក្មេងៗជំនាន់ក្រោយចងចាំនូវការរងទុក្ខរបស់ជនរងគ្រោះដែលបានរួចផុតជីវិតពីរបបខ្មែរក្រហម និងដើម្បីឲ្យវិញ្ញាណក្ខន្ធជនរងគ្រោះដែលបានស្លាប់ឲ្យទៅកាន់សុខគតិភព ។ ទោះបីជាប្រជាជនកម្ពុជាបានរស់រានមានជីវិតឡើងវិញ និងបានជួបជុំក្រុមគ្រួសាររបស់ខ្លួនក៏ដោយ ក៏ប៉ុន្តែមានជនរងគ្រោះជាច្រើនត្រូវបានសម្លាប់ដោយមិនមានកំហុស ។ ហេតុដូច្នេះហើយ អំពើឃោរឃៅយង់ឃ្នងដែលខ្មែរក្រហមបានប្រព្រឹត្តក្នុងរយៈពេល៣ឆ្នាំ៨ខែ២០ថ្ងៃ ពិតជាមិនបានទៅណាឆ្ងាយពីអារម្មណ៍របស់ប្រជាជនកម្ពុជាសូម្បីតែមួយវិនាទី ។

**ស៊ាង ចិន្តា**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយ នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយ ដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិ ដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ truthpechet@dccam.org ។

**◆ទីកន្លែង ៖ អគារ “ក” ជាន់លើ ◆ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

*“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។*

*តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។*

*ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthphalla.c@dccam.org ។*





















# អដ្ឋិធាតុនៅមានព្រលឹង

ប្រទេសកម្ពុជាជួបប្រទះសង្គ្រាមស៊ីវិលរ៉ាំរ៉ៃអស់ជាច្រើនឆ្នាំ គិតចាប់ផ្ដើមពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនៅអំឡុងទសវត្សឆ្នាំ៦០ ព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ សង្គ្រាមស៊ីវិល និងការកាន់កាប់របស់ខ្មែរក្រហមនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ។ សង្គ្រាមបានធ្វើឲ្យប្រជាជនកម្ពុជាព្រាត់ប្រាស់ក្រុមគ្រួសារ និងស្លាប់អស់ជាច្រើន ហើយអដ្ឋិធាតុរបស់ក្រុមគ្រួសារអ្នកទាំងនោះមិនបានថែរក្សាត្រឹមត្រូវនោះទេ ។

ប្រជាជនខ្មែរមានការគោរព និងស្រឡាញ់សាច់ញាតិរបស់ខ្លួនជាខ្លាំង ទោះបីជាសាច់ញាតិរបស់ខ្លួនបាត់បង់ជីវិតក្ដី ដោយនៅតែចាត់ទុកថា អ្នកស្លាប់ទាំងនោះនៅតែជាសមាជិកគ្រួសាររបស់ខ្លួនដដែល ។ តាមប្រពៃណី ប្រជាជនខ្មែរតែងតែធ្វើពិធីបុណ្យឧទ្ទិសដល់សព ដែលមានដូចជា ពិធីបុណ្យ៧ថ្ងៃ និង១០០ថ្ងៃ ទៅតាមធនធានដែលមាន ។

រាល់ពិធីបុណ្យទាំងនេះ ធ្វើឡើងដើម្បីរំលឹកដល់អ្នកស្លាប់ព្រមជាមួយនឹងជំនឿដែលថា អ្នកដែលស្លាប់ទៅនោះគឺគ្រាន់តែជារូបកាយប៉ុណ្ណោះ តែព្រលឹងអ្នកស្លាប់នៅតែវិលវល់មិនដាច់អាល័យនឹងរាងរូបកាយរបស់ខ្លួនក៏ដូចជាសាច់ញាតិ ។ ការគោរពអ្នកស្លាប់និងជំនឿទាក់ទងនឹងការស្លាប់នេះ គឺមានអាយុកាលយូរយារណាស់មកហើយ ដូចដែលយើងឃើញមានភស្តុតាងនៅតាមប្រាសាទបូរាណនានា មានប្រាសាទបាយ័ន និងគំនូរនៅតាមជញ្ជាំងព្រះវិហារ ។ តាមប្រពៃណីខ្មែរ ប្រជាជនភាគច្រើនបូជាសព និងខ្លះទៀតបញ្ចុះសព (កប់សព) ឧទាហរណ៍ នៅទីតាំងខ្លះក្នុងខេត្តសៀមរាប គ្រួសារសពគ្រាន់តែបញ្ចុះសពក្នុងរយៈពេលសមរម្យ ក្រោយមកទើបគាស់យកឆ្អឹងទៅបូជា ។ ប្រជាជនខ្លះទៀត ដែលមានជីវភាពមធ្យម បានសង់ចេតិយសម្រាប់ដាក់ធាតុដែលបានបូជារួចនៅក្នុងបរិវេណវត្តនៅជិតផ្ទះរបស់ខ្លួន ឬដាក់នៅក្នុងវត្តដែលមានសាច់ញាតិ ក្រុមគ្រួសាររបស់ខ្លួននិយមចូលចិត្តតាំងពីដូនតា ឬដាក់នៅក្នុងបរិវេណផ្ទះតែម្ដង ។ ប្រជាជនខ្លះបានយកធាតុដាក់ក្នុងកោដ្ឋ រួចយកទៅដាក់នៅជិតអសនៈព្រះពុទ្ធ ។ ប្រជាជនដែលយកធាតុមកដាក់ផ្ញើនៅវត្ត និងជិតរូបព្រះពុទ្ធ ហើយដែលមានព្រះសង្ឃជាអ្នកជួយថែរក្សា គឺមានជំនឿថា ទីវត្តអារាមគឺជាកន្លែងស័ក្តិសិទ្ធជាពិសេស គឺចង់ឲ្យសាច់ញាតិដែលស្លាប់ទៅភ្ជាប់ខ្លួនទៅនឹងព្រះដែលបានសម្រេចធម៌ និងបានទៅដល់និពាន្ត និងឋានសួគ៌ ។


ឆ្អឹង និង លលាដ៍ក្បាល របស់ជនរងគ្រោះនៃរបបខ្មែរក្រហម

ដោយសារតែប្រទេសកម្ពុជាឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃ ប្រជាជនភាគច្រើនគិតថាវត្តអារាមជាទីសុវត្ថិភាពដែលអាចថែរក្សាទុកធាតុរបស់សមាជិកគ្រួសារ ។ ដាក់ស្ដែង វត្តលង្កា ដែលជាវត្តចំណាស់មួយ ក្នុងចំណោមវត្តបុរាណជាច្រើននៅរាជធានីភ្នំពេញ បានរក្សាទុកអដ្ឋិធាតុរបស់អ្នកស្លាប់ជាច្រើនរហូតមកដល់សព្វថ្ងៃនេះ ។ វត្តនេះត្រូវបានកសាងឡើងតាំងពីសម័យព្រះបរមរាជា

"ពញាយ៉ាត" ដែលទ្រង់មករៀបចំរាជធានីភ្នំពេញ ធ្វើជារាជធានីនៃប្រទេសកម្ពុជានៅសតវត្សទី១៥ ដែលមានទីតាំងដើមនៅទិសត្បូងសាន្តនៃវត្តភ្នំដូនពេញ ។ នៅក្នុងឆ្នាំ១៨៩២ រាជការបានរៀបចំទីក្រុងភ្នំពេញ ហើយវត្តលង្កាក៏ត្រូវបានផ្លាស់មកនៅទីតាំងសព្វថ្ងៃនេះ ។ ទីតាំងវត្តនេះ ធ្លាប់ជាសាលារៀនអនុវត្ត និងជាកន្លែងដែលសិស្ស និស្សិតមកពីតាមបណ្តាខេត្តមកស្នាក់នៅរៀនសូត្រ ។ កាំង ហ្កេកអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរសន្តិសុខស-២១ ក្នុងរបបខ្មែរក្រហម ដែលមានស្រុកកំណើតនៅស្រុកស្ទោង ខេត្តកំពង់ធំ ក៏ធ្លាប់មកស្នាក់នៅវត្តលង្កាដែរ ពេលដែលគាត់មករៀនសូត្រនៅទីក្រុងភ្នំពេញ ។

ជាចៃដន្យ លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឆាំង យុ បានដឹងតាមរយៈការសំណេះសំណាលជាមួយព្រះសង្ឃ ក្នុងថ្ងៃបុណ្យសពបងស្រីរបស់លោកនៅក្នុងវត្តលង្កា ដោយព្រះសង្ឃមានសង្ឃដីកាថា នៅក្រោមបល្ល័ង្កព្រះក្នុងព្រះវិហារចាស់ មានកោដ្ឋជាច្រើនដែលយកមកផ្ញើវត្តតាំងពីយូរយារមក គឺតាំងពីសម័យមុនសង្គ្រាមមកម៉្លេះ តែក៏មានអដ្ឋិធាតុក្រោយសម័យខ្មែរក្រហមដែរ ។ កោដ្ឋខ្លះមានកាលបរិច្ឆេទ មានឈ្មោះ និងកោដ្ឋខ្លះទៀតមិនមានឈ្មោះ ។ មានកោដ្ឋតិចតួចមានរូបថតជាប់ជាមួយ និងចុះឆ្នាំច្បាស់លាស់ដូចជា សរសេរថា នៅឆ្នាំ១៩៧៣ ជាដើម ។ យើងអាចគិតថា មុនពេលដែលប្រជាជនត្រូវខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៥ មានគ្រួសារខ្លះអាចយកកោដ្ឋដែលដាក់ធាតុសមាជិកគ្រួសាររបស់ខ្លួនមកផ្ញើព្រះសង្ឃ មុនពេលចាកចេញពីផ្ទះ ។

តាមសម្តី លោកតា កេង ម៉េងឡុង អតីតព្រះសង្ឃ នៅវត្តលង្កា កាលពីឆ្នាំ១៩៩២ បានឲ្យដឹងថា ពេលដែលស្រុកស្រួលបួលនិងមានសន្តិភាពហើយ មានសមាជិកគ្រួសារជាច្រើន បានមកស្វែងរកអដ្ឋិធាតុសមាជិកគ្រួសាររបស់ខ្លួន ។ ប្រជាជនទាំងនោះ មកទូលសុំព្រះចៅអធិការរកធាតុរបស់ក្រុមគ្រួសារដែលបានផ្ញើទុកនៅវត្ត ទើបព្រះចៅអធិការចាត់ចែងឲ្យរកមើលថា តើធាតុទាំងនោះនៅទីណា ក្រោយទើបដឹងថា អដ្ឋិធាតុទាំងនោះនៅក្រោយបល្ល័ង្កព្រះនៅក្នុងព្រះវិហារចាស់ ដែលជាកន្លែងងងឹត និងអាថ៌កំបាំង ។ ចាប់តាំងពីលោក តា ម៉េងឡុង មកនៅបួសក្នុងវត្តនេះរហូតមកដល់សព្វថ្ងៃ លោកតាបានជួយប្រជាជនដែលមកស្វែងរកអដ្ឋិធាតុសាច់ញាតិបានចំនួនបួនគ្រួសាររួចមកហើយ ។ លោកតាអះអាងថា មានប្រជាជនផ្សេងទៀតមករកអដ្ឋិធាតុ តែមិនបានជួបគាត់ផ្ទាល់ទេ ដោយអ្នកដែលមកជួបគាត់ មានប្រហែលជា៦-៧នាក់ប៉ុណ្ណោះ ។ ប៉ុន្តែនៅពេលថ្មីៗមានគ្រួសារមួយមករកឃើញអដ្ឋិធាតុសមាជិកក្រុមគ្រួសារ ហើយយកទៅវិញនៅក្នុងថ្ងៃបុណ្យភ្ជុំបិណ្ឌឆ្នាំមុននោះ ។

ព្រមជាមួយនោះ ព្រះសង្ឃគង់នៅវត្តលង្កា បានឲ្យដឹងថា មានឧបាសកខ្លះមកម្តងរកមិនឃើញ ព្រោះអដ្ឋិធាតុខ្លះបានបាត់បង់អត្តសញ្ញាណ តែនៅពេលដែលក្រុមគ្រួសារទាំងនោះមកអុជធូបផ្សងសុំឲ្យព្រលឹងអ្នកស្លាប់ប្រាប់ ក្រោយមកអ្នកទាំងនោះក៏រកឃើញអដ្ឋិធាតុមែន ។ ប្រជាជនផ្សេងទៀតទោះបីជាបាត់រូបថត ឬឈ្មោះ តែគេនៅចាំរូបរាងកោដ្ឋ ហើយពេលបើកគម្របក៏ឃើញមានឈ្មោះសាច់ញាតិនៅក្នុងកោដ្ឋនោះមែន ។

លោកតា ម៉េងឡុង បានរំឭកដល់ករណីមួយដែលប្តីប្រពន្ធពីរនាក់មករកកោដ្ឋថា "ខ្ញុំជួយរកឃើញសមាជិកគ្រួសារគាត់នៅក្រោមបល្ល័ង្កព្រះ ខ្ញុំមានចិត្តសប្បាយរីករាយដោយឃើញគ្រួសារនោះរកឃើញសមាជិកគ្រួសារដែលបានស្លាប់ទៅ" ។ គ្រួសារនោះសប្បាយចិត្តរហូតដល់ស្រក់ទឹកភ្នែក ហើយថែមទាំងជូនសគុណដល់គាត់ដែលបានព្យាយាមជួយរកអដ្ឋិធាតុទៀតផង ។

ការរកឃើញធាតុរបស់សមាជិកគ្រួសារដែលជាទីគោរព និងជាទីស្រឡាញ់ក្រោយពេលសង្គ្រាម ជាការផ្សះផ្សាផ្លូវចិត្តមួយរបស់ជនរងគ្រោះ ។ តាមជំនឿប្រជាជនទាំងនោះចង់គោរព និងធ្វើបុណ្យរំឭកដល់សមាជិកគ្រួសារជាទីស្រឡាញ់ទៅតាមប្រពៃណីសាសនា ពេលដែលមិនដឹងថា ធាតុទាំងនោះនៅទីណា ជនរងគ្រោះពិតជាពិបាកនឹងស្ងប់ចិត្តណាស់ ។ ម្យ៉ាងទៀត ធាតុទាំងនោះក៏បានជួបជុំជាមួយគ្រួសារដែរ ព្រលឹងរបស់អ្នកស្លាប់អាចនឹងស្ងប់សុខ និងទៅចាប់កំណើតទៅជាតិថ្មី ។ ហេតុដូចនេះហើយ បានជាមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងរៀបចំថត និងតាំងធាតុទាំងនោះ និងជួយផ្សព្វផ្សាយរកក្រុមគ្រួសារករណីដែលគាត់ចង់នាំយកធាតុទាំងនោះទៅធ្វើបុណ្យតាមប្រពៃណីសាសនា និងក្នុងបំណងជួយថែរក្សាធាតុទាំងនោះផង ។

**ហ៊ុយ សម្ភស្ស**

# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី : អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

*(តពីលេខមុន)*

## *៨) ការរៀបការឆ្លងសាសនារវាងអ្នកកាន់សាសនាព្រះពុទ្ធ និង អ៊ីស្លាម*

*ការរៀបការឆ្លងសាសន៍ គឺជាលទ្ធផលចេញមកពីការប្រាស្រ័យទាក់ទងគ្នារវាងអ្នកកាន់សាសនាព្រះពុទ្ធ និងមូស្លីម ។ ការរៀបការគឺជាខ្សែបន្ទាត់ព្រំដែនរវាងខ្មែរ និងចាម ហើយក៏ជាកន្លែងដែលក្រុមទាំងពីរជួបគ្នាដែរ ។ ការរៀបការជាចំណុចដែលធ្វើឲ្យភាពខុសគ្នារវាងក្រុមទាំងពីររសាត់បាត់ទៅ ហើយក្រុមទាំងពីរ ធ្វើការកែច្នៃរកមធ្យោបាយដែលនាំឲ្យអ្នកទាំងពីរអាចរស់នៅជាមួយគ្នាបានដោយសុខសាន្ត ។ ជាងនេះទៅទៀត ការរៀបការគឺជាចំណុចដែលនាំឲ្យក្រុមទាំងពីរធ្វើការបកស្រាយពីគ្នាទៅវិញទៅមកដោយមិនលម្អៀង មិនប្រកាន់ប្ករើសអើងពីភាពខត្តុងខត្តុមជាង ប្កភាពអន់ថយជាង ដោយសារតែចំណុចសំខាន់នៃអ្នកទាំងពីរ គឺការរស់នៅជាមួយគ្នាដោយមិនបំពានទៅលើសាសនាគ្នាទៅវិញទៅមក ។*

*នៅក្នុងព្រះពុទ្ធសាសនា ការរៀបការឆ្លងសាសន៍គឺអនុញ្ញាតដោយមិនចាំបាច់មានការប្តូរសាសន៍ ។ ប៉ុន្តែ ក្នុងទស្សនៈរបស់អ៊ីស្លាមវិញ អ្នកដែលកើតមកជាមូស្លីម គ្មានការទទួលខុសត្រូវរហូតដល់អាយុ១៥ឆ្នាំ ។ ចាប់ពីអាយុ១៥ឆ្នាំមក បុគ្គលនោះនឹងទទួល*



*ពិធីរៀបអាពាហ៍ពិពាហ៍ឆ្លងសាសន៍រវាងជនជាតិខ្មែរ និងជនជាតិចាម*

ខុសត្រូវចំពោះអំពើបាបដោយខ្លួនឯង ។ អ៊ីស្លាមយល់ថា កុមារដែលមានអាយុក្រោម១៥ឆ្នាំ ដែលកើតនៅក្នុងគ្រួសារមិនមែនមូស្លីម ក៏នៅតែជាមូស្លីមពីកំណើតដែរ ។ ហេតុនេះ ការប្តូរសាសន៍ទៅកាន់សាសនាអ៊ីស្លាមគឺគ្រាន់តែជាការត្រឡប់ទៅរកសាសនាដើមវិញប៉ុណ្ណោះ ។ ក្នុងការពិចារណាទៅលើការរៀបការឆ្លងសាសន៍នេះ បញ្ញវន្តអ៊ីស្លាមម្នាក់បាននិយាយថា "ការរៀបការជាមួយបុគ្គលម្នាក់ទៀតដែលកាន់សាសនាខុសគ្នាមិនមែនមានន័យថា ការរៀបការជាមួយបុគ្គលមិនមែនមូស្លីមនោះទេ តែបុគ្គលនោះមានកំណើតជាមូស្លីម ហេតុនេះ យើងពេញចិត្តនឹងនាំបុគ្គលនោះត្រឡប់ទៅរកសាសនាដើមវិញ" ។

ក្នុងសៀវភៅ Navigating the Rift អ៊ីសា ឧស្មាន់ សិក្សាពីការរៀបការឆ្លងសាសន៍នៅកម្ពុជា រវាងជនជាតិចាម និងខ្មែរ ។ ឧស្មាន់សរសេរថា "អ៊ីស្លាមអនុញ្ញាតឲ្យមូស្លីមរៀបការនឹងអ្នកដែលមិនមែនជាមូស្លីមបាន ប៉ុន្តែក្នុងលក្ខខណ្ឌដែលអ្នកនោះប្តូរសាសន៍ទៅជាមូស្លីម ដើម្បីឲ្យអ្នកនោះត្រឡប់ទៅរកសាសនាដើមវិញ ។ ហេតុនេះ ពេលមូស្លីមចង់រៀបការជាមួយអ្នកមិនមែនមូស្លីម អ្នកនោះត្រូវណែនាំដៃគូរបស់ខ្លួនទៅសាសនាអ៊ីស្លាមមុនពេលរៀបការ" ។ ចំណុចសំខាន់ដែលគួរឲ្យកត់សម្គាល់នោះគឺថា ការប្តូរសាសន៍ធ្វើឡើងមុនពិធីរៀបការ ។ នៅក្នុងពិធីរៀបការដែលខ្ញុំបានចូលរួមនៅភ្នំពេញ កូនកំលោះត្រូវធ្វើពិធីចូលសាសន៍និងពិធីកាត់ស្បែកអង្គជាតិមួយអាទិត្យមុនពិធីរៀបការ ។ ប្រសិនបើកូនកំលោះនោះប្រកែកមិនព្រមចូលសាសន៍ នោះអ៊ីស្លាមចែងថា ព្រះអល់ឡោះហាមប្រាមមូស្លីមមិនឲ្យរៀបការជាមួយនឹងអ្នកមិនមែនមូស្លីម ។ គម្ពីរគួរអានណែនាំយ៉ាងជាក់លាក់លើបញ្ហានេះ៖

កុំរៀបការជាមួយនារីដែលគ្មានជំនឿ រហូតទាល់តែនាងនោះជឿៈ នារីទាសករម្នាក់ដែលមានជំនឿ ប្រសើរជាងនារីធម្មតាម្នាក់ដែលគ្មានជំនឿ ទោះជានាងអូសទាញអ្នកប៉ុណ្ណាក៏ដោយ ។ កុំរៀបការកូនស្រីអ្នក ជាមួយបុរសគ្មានជំនឿរហូតទាល់តែអ្នកនោះជឿៈ បុរសទាសករម្នាក់ដែលមានជំនឿប្រសើរជាងបុរសធម្មតាដែលគ្មានជំនឿ ទោះជាបុរសនោះអូសទាញអ្នកប៉ុណ្ណាក៏ដោយ ។ អ្នកគ្មានជំនឿពិតជាទាញអ្នកឲ្យចូលរណ្តៅភ្លើង ។ ប៉ុន្តែព្រះអល់ឡោះទាញអ្នកទៅកាន់សួនសុខ និងប្រកបដោយភាពអធ្យាស្រ័យ តាមព្រះគុណព្រះអង្គ ។

យើងនឹងឃើញនៅជំពូកបន្ទាប់ថា ពេលស្តេចខ្មែរ រាមាធិបតីទី១ លង់ស្នេហ៍និងមានបំណងរៀបការនឹង នាង វ៉ាស (Neang Vas) ទ្រង់ត្រូវបានតម្រូវឲ្យប្តូរសាសន៍ទៅជាអ៊ីស្លាមមុនពេលយកនាងវ៉ាស ដែលជាមូស្លីមចូលព្រះរាជវាំង ។ ប៉ុន្តែ នៅមានមូលហេតុផ្សេងៗទៀតដែលធ្វើឲ្យស្តេចខ្មែរយល់ព្រមទៅតាមតម្រូវការផ្នែកសាសនានេះ ។ ក្នុងនោះគឺទ្រង់ចង់ឲ្យជនជាតិចាមមានភក្តីភាពចំពោះព្រះអង្គ ហើយការចូលសាសនាអ៊ីស្លាមធ្វើឲ្យព្រះអង្គអាចសុំការអត់ឱនទោសពីអំពើបាបដែលទ្រង់បានសាង ដែលព្រះពុទ្ធសាសនាមិនអាចផ្តល់ឲ្យបាន ។ ព្រះអង្គទ្រង់បានដូរព្រះនាមទៅជាមូស្លីម អ៊ីប្រាហាម ។ ក្នុងពិធីប្តូរសាសន៍ អត្តសញ្ញាណពីរត្រូវបានប្តូរគឺ ការកាត់ស្បែកអង្គជាតិ និងការដាក់ឈ្មោះមូស្លីម ។

នៅក្នុងច្បាប់នៃការប្តូរសាសន៍ប្តី ឬប្រពន្ធឲ្យទៅជាមូស្លីម សាសនាអ៊ីស្លាមហាមប្រាមមូស្លីមមិនឲ្យបង្ខំអ្នកដទៃឲ្យប្តូរសាសនាទៅជាអ៊ីស្លាមនោះទេ ។ ទោះជាយ៉ាងនេះក៏ដោយ អ្នកនិពន្ធបានពុការថ្នាងថ្នាក់ចិត្តពីសំណាក់ជនជាតិខ្មែរកាន់ព្រះពុទ្ធសាសនាអំពីច្បាប់អ៊ីស្លាមចំពោះការរៀបការឆ្លងសាសន៍នេះ ។ ខ្មែរយល់ថា តម្រូវការអ៊ីស្លាមក្នុងការប្តូរសាសន៍មុនពិធីរៀបការមិនយុត្តិធម៌ចំពោះសាសនាផ្សេងឡើយ ។ ជនជាតិខ្មែរខ្លះខ្លាចថា សាសនាអ៊ីស្លាមនឹងរីកសាយភាយនៅកម្ពុជាតាមរយៈការរៀបការនេះ ហើយអាចនឹងគ្របដណ្តប់លើសាសនាព្រះពុទ្ធ ។ ក្នុងទស្សនៈគាត់ ពេលយុវវ័យលង់ស្នេហ៍នឹងមូស្លីម យុវវ័យទាំងនោះច្រើនប្តូរសាសន៍ទៅជាអ៊ីស្លាមជាជាងបន្តប្រតិបត្តិសាសនាដើមរបស់ខ្លួន ។

ក្នុងករណីដែលមូស្លីមជាជនជាតិភាគតិចនៅក្នុងប្រទេសនោះរឹតតែធ្វើឲ្យបញ្ហានេះស្មុគស្មាញទៅទៀត ។ បុរសមូស្លីមត្រូវបានណែនាំឲ្យជៀសវាងកុំរៀបការជាមួយស្ត្រីដែលមិនមែនជាមូស្លីម ព្រោះពេលបុរសមូស្លីមមានកាន់តែតិចទៅស្ត្រីមូស្លីមអាចនឹងត្រូវបង្ខំឲ្យរៀបការជាមួយនឹងបុរសដែលមិនមែនជាមូស្លីម ។ បុរសមូស្លីមក៏ត្រូវបានណែនាំមិនឲ្យរៀបការឆ្លងសាសន៍ ដោយសារតែបុរសទាំងនោះជាអ្នកចាប់ផ្តើម ។ ប៉ុន្តែ កម្ពុជាមិនទាន់ទៅដល់ចំណុចដែលការរៀបការឆ្លងសាសន៍ធ្វើឲ្យមានការផ្លាស់ប្តូរនូវចំនួនប្រជាជនមូស្លីមនៅឡើយ ។ អ្នកប្រាជ្ញមូស្លីមម្នាក់បាននិយាយថា៖

មានស្ត្រីមូស្លីមជាច្រើនដែលដល់អាយុរៀបការហើយរស់

នៅក្នុងប្រទេសមិនកាន់សាសនាអ៊ីស្លាម ។ ក្នុងករណីនោះ កាតព្វកិច្ចរបស់បុរសមូស្លីមគឺត្រូវការពារស្ត្រីទាំងនោះមិនឲ្យរៀបការជាមួយបុរស ដែលមិនកាន់សាសនាអ៊ីស្លាម ដែលបញ្ហានេះត្រូវបានហាមផ្តាច់ដោយសាសនាអ៊ីស្លាម ។ ប្រសិនបើបុរសមូស្លីមមិនបានអនុវត្តតាមច្បាប់ ហើយទៅរៀបការនឹងស្ត្រីកាន់សាសនាគ្រីស្ត ឬជ្វីសនោះ ស្ត្រីមូស្លីមនៅក្នុងប្រទេសមិនកាន់សាសនាអ៊ីស្លាមនឹងត្រូវបង្ខំឲ្យចូលទៅក្នុងស្ថានភាពដែលមិនគាប់ប្រសើរ ហើយបុរសមូស្លីមនឹងទទួលខុសត្រូវមួយចំណែកទៅលើបញ្ហានេះ និងត្រូវទទួលការដាក់ទណ្ឌកម្មពីព្រះអល់ឡោះដែរ ។

ស្ត្រីមានតួនាទីពីរយ៉ាងនៅក្នុងការរៀបការឆ្លងសាសន៍ ។ នៅក្នុងសង្គមដែលគ្របដណ្តប់ដោយបុរស ស្ត្រីមូស្លីមត្រូវបានបង្អាប់មិនឲ្យរៀបការឆ្លងសាសន៍ ដោយសារតែស្ត្រីទាំងអស់នោះមានអំណាចតិចតួចនៅក្នុងគ្រួសារដែលអាចធ្វើឲ្យប្តីមានឥទ្ធិពលផ្នែកសាសនាមកលើខ្លួន និងកូន ។ នៅក្នុងសង្គមដែលស្ត្រីមានអំណាចច្រើនគួរសម ស្ត្រីមូស្លីមត្រូវបានអនុញ្ញាតឲ្យរៀបការឆ្លងសាសន៍ ពីព្រោះស្ត្រីទាំងអស់នោះអាចមានឥទ្ធិពលខ្លាំងទៅលើប្តី និងកូន ។ នៅក្នុងសង្គមកម្ពុជា យើងឃើញមានប្រព័ន្ធពីរ ។ មនុស្សជំនាន់មុនជឿថាម្តាយមានឥទ្ធិពលលើកូនជាងឪពុក ព្រោះតែគាត់ចំណាយពេលវេលាច្រើនលើកូនជាងឪពុក ។

ដោយសារព្រះពុទ្ធសាសនាមានការបើកទូលាយចំពោះការរៀបការឆ្លងសាសន៍ សាសនានេះគ្មានច្បាប់ស្មុគស្មាញទាក់ទងនឹងបញ្ហានេះទេ ។ សាសនាអ៊ីស្លាមក៏មានច្បាប់សម្រាប់ការលែងលះគ្នាដែរ ។ ការប្តូរសាសន៍គឺជាលក្ខខណ្ឌចម្បងសម្រាប់ការរៀបការឆ្លងសាសនា ។ ប្រសិនបើអ្នកប្តូរសាសន៍នោះ ប្តូរចេញពីសាសនាអ៊ីស្លាមវិញ នោះអាពាហ៍ពិពាហ៍នឹងលែងមានសុពលភាពក្នុងច្បាប់អ៊ីស្លាមទៀតហើយ ។ ហេតុនេះ សាសនាអ៊ីស្លាមជាអ្នកកំណត់លើអាពាហ៍ពិពាហ៍ចំពោះអ្នកដែលចូលសាសនាអ៊ីស្លាម និងបញ្ចប់អាពាហ៍ពិពាហ៍នោះវិញ នៅពេលអ្នកនោះត្រឡប់ទៅសាសនាដើមវិញ ។

ទោះបីជាច្បាប់នៃការរៀបការឆ្លងសាសន៍មានភាពតឹងរ៉ឹងយ៉ាងណា ស្ថិតិនៅកម្ពុជាបង្ហាញថា អ្នកអនុវត្តនៅតែមិនទាន់គោរពតាមបានពេញលេញនៅឡើយ ។ ការស្រង់មតិរបស់ ខស្មាន់ លើគូស្រករ ដែលបានរៀបការឆ្លងសាសន៍ចំនួន៥២៦គូ បានបង្ហាញថា ៤៦៣គូប្រតិបត្តិសាសនាអ៊ីស្លាម (៨៨ភាគរយ) ៥៤គូប្រតិបត្តិសាសនាព្រះពុទ្ធ(១០,៣ភាគរយ) និង៩គូទៀតនៅប្រតិបត្តិសាសនាដើមរៀងៗខ្លួន (១,៧ភាគរយ) ។ ហេតុនេះ គូស្វាមីភរិយាមួយគូក្នុងចំណោម១០គូ មិនអនុវត្តតាមច្បាប់អ៊ីស្លាមទេ ។ អ្នកនិពន្ធបានជួបជាមួយប្តីប្រពន្ធមួយគូនៅភូមិជីផាត ខេត្តកោះកុង ។ មាស ផល្លី ជាជនជាតិចាម និងជាមេភូមិជីផាត ។ ក្រោយពីរៀបការជាមួយស្ត្រីខ្មែរម្នាក់ គាត់បានប្តូរឈ្មោះទៅជាខ្មែរ ហើយប្តូរមកគោរពព្រះពុទ្ធសាសនាវិញ ។ គាត់និយាយថា ប្តីប្រពន្ធដែលរៀបការឆ្លងសាសន៍ច្រើនតែប្តូរទៅជាអ៊ីស្លាម តែចំពោះគាត់វិញ គាត់ចាប់យកនូវការរស់នៅបែបខ្មែរ ។

បន្ថែមពីលើនោះទៅទៀត ផ្ទុយទៅនឹងទ្រឹស្តីដែលចែងថាចំនួនបុរសចាមបានថយចុះនៅក្នុងសង្គមជនជាតិភាគតិចអ៊ីស្លាមនោះ ខស្មាន់ បានរកឃើញថា នៅកម្ពុជាស្ត្រីចាមបានរៀបការនឹងដៃគូដែលមិនមែនជនជាតិអ៊ីស្លាមច្រើនជាងបុរស ។ ក្នុងនោះ ៥២៦គូដែលបានរៀបការឆ្លងសាសន៍២៩៦គូគឺស្ត្រីចាម និងបុរសខ្មែរ (៥៦,៣កាយរយ) ហើយ២៣០គូទៀត គឺបុរសចាមជាមួយនឹងស្ត្រីខ្មែរ (៤៣,៧ ភាគរយ) ។



គូស្រករជនជាតិចាម

ការរៀបការឆ្លងសាសន៍នៅកម្ពុជាបណ្តាលមកពីមូលហេតុច្រើនយ៉ាង ។ ទីមួយ ការរៀបការឆ្លងសាសន៍ច្រើនតែកើតឡើងនៅកន្លែងដែលសហគមន៍ខ្មែរ និងចាមរស់នៅជិតដិតនឹងគ្នា ។ ក្នុងស្ថានភាពបែបនេះ ទាំងភាសា និងវប្បធម៌គឺមានការទំនាក់ទំនងគ្នាដែលនាំឲ្យមានការយល់ពីគ្នាទៅវិញទៅមកបានល្អប្រសើរ ។ គូស្រករក្មេងៗច្រើនជួបគ្នានៅតាមទីផ្សារ សាលារៀន និងកន្លែងធ្វើការ ។ ឧទាហរណ៍ នារីជនជាតិចាមក្មេងៗច្រើនជួបបុរសខ្មែរនៅក្នុងរោងចក្រកាត់ដេរ ។ ដូចដែលបានបង្ហាញពីខាងដើម យុវវ័យចាមនៅតំបន់ទីក្រុងអាចនិយាយភាសាខ្មែរច្បាស់ជាងយុវវ័យដែលរស់នៅតំបន់ដែលមានតែជនជាតិចាមសុទ្ធរស់នៅ ហើយខ្មែរខ្លះអាចនិយាយភាសាចាមបានដែរ ។ យុវវ័យចាមនៅទីក្រុងអាចមានលទ្ធភាពក្នុងការប្រើប្រាស់អ៊ីនធឺណែត ដែលអាចឲ្យខ្លួនប្រាស្រ័យទាក់ទងជាមួយយុវវ័យដែលកាន់សាសនាផ្សេងៗ តាមរយៈការចូលទៅប្រើប្រាស់បណ្តាញសង្គម ។

ទីពីរ គោលនយោបាយបំបែករបស់របបខ្មែរក្រហមទៅលើជនជាតិចាម ហើយនឹងគោលបំណងកម្ចាត់អត្តសញ្ញាណសំខាន់របស់ជនជាតិនេះ ធ្វើឲ្យជនជាតិចាមជាច្រើននាក់ទៅរស់នៅចម្រុះជាមួយជនជាតិខ្មែរ ហើយរៀនសម្របខ្លួនទៅនឹងវប្បធម៌ខ្មែរ ។ ទីបី ជនជាតិខ្មែរតិចតួចណាស់ដែលចង់ប្រតិបត្តិសាសនាអ៊ីស្លាម ដែលអ្នកទាំងអស់នោះយល់ថា សាសនាអ៊ីស្លាមមានលក្ខណៈល្អប្រសើរជាងសាសនាព្រះពុទ្ធ ។ ទីបួន ចាប់តាំងពីក្រុមអ៊ុនតាក់ (អាជ្ញាធរអន្តរកាលអង្គការសហប្រជាជាតិនៅកម្ពុជា) ចូលមកកម្ពុជានៅឆ្នាំ១៩៩១ ដែលក្រុមនេះនាំមកជាមួយនូវតម្លៃនៃលទ្ធិប្រជាធិបតេយ្យ និងការអប់រំសិទ្ធិមនុស្ស ធ្វើឲ្យមានការថយចុះការរើសអើងសាសនា និងមានការប្រាស្រ័យទាក់ទងច្រើនជាងមុនរវាងមូស្លីម និងអ្នកកាន់ព្រះពុទ្ធសាសនា ។ ទីប្រាំ ឪពុកម្តាយជនជាតិចាមមានការបើកទូលាយច្រើន ហើយអនុញ្ញាតឲ្យកូនខ្លួនមានសេរីភាពក្នុងការរើសគូស្រករ ។

## សេចក្តីសន្និដ្ឋាន

ជំពូកនេះបង្ហាញពីទិដ្ឋភាពមួយចំនួននៃអត្តសញ្ញាណជនជាតិចាមផ្នែកសាសនា និកាយ សេដ្ឋកិច្ច និងនយោបាយ ។ ជំពូកនេះក៏បង្ហាញពីលទ្ធផលស្ថិតិប្រជាជនដែលអ្នកនិពន្ធបានស្រង់ ដើម្បីបញ្ជាក់ពីចំនួនប្រជាជនចាមនៅក្នុងប្រទេសកម្ពុជា ។ លទ្ធផលស្រង់ស្ថិតិបង្ហាញថា ប្រជាជនចាមសរុបមានចំនួន ២៧២.៣៦០នាក់ នៅឆ្នាំ២០១០ ស្មើនឹង២ភាគរយនៃចំនួនប្រជាជនសរុប ។ ខុសពីការប៉ាន់ស្មានរបស់អ្នកស្រាវជ្រាវមួយចំនួនដែលស្មើថាភាគរយប្រជាជនចាមមានដល់ទៅ១០ភាគរយនៃប្រជាជនសរុប ការស្រង់ស្ថិតិនេះបង្ហាញថា ទោះបីជាជនជាតិចាមជាក្រុមជនជាតិភាគតិចសាសនាធំជាងគេក្នុងប្រទេសកម្ពុជាក៏ដោយ ក៏ក្រុមនេះនៅមានទំហំតូច ។

ក្នុងចំណោមមូស្លីមទាំងអស់ ជនជាតិចាមគឺជាក្រុមជាតិពន្ធុដែលមានចំនួនច្រើនជាងគេ ដែលមានចំនួនប្រមាណជា៨០ភាគរយនៃប្រជាជនមូស្លីមសរុបសល់ពីនោះគឺជាជនជាតិជ្វា ។ ទំហំប្រជាជនមានសារសំខាន់ចំពោះការសិក្សាអត្តសញ្ញាណជនជាតិចាម ជាពិសេស គឺអត្តសញ្ញាណនយោបាយ ។ ដោយសារតែចាមជាជនជាតិភាគតិចដែលមានចំនួនប្រជាជនតិច ជនជាតិចាមគ្មានលទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋាភិបាល ដែនដី ឬស្ថាប័នរដ្ឋាភិបាលក្រៅពីស្ថាប័នដែលបង្កើតឡើងដើម្បីឲ្យខ្លួនគ្រប់គ្រង ។ ជាងនេះទៅទៀត ចំនួនប្រជាជនតិច មានន័យថាខ្លួនត្រូវកំណត់អត្តសញ្ញាណខ្លួនឯងជាមួយនឹងជនជាតិខ្មែរ បើទោះជាមិនតាមរយៈសាសនា ក៏ធ្វើតាមរយៈការរស់នៅក្នុងប្រទេសតែមួយ ហើយនិងការរៀបចំរបៀបរស់នៅឲ្យត្រូវគ្នាទៅនឹងសង្គមខ្មែរ ។

ការស្រង់ចំនួនប្រជាជននេះក៏បង្ហាញឲ្យឃើញពីរបាយការណ៍ប្រជាជនចាមនៅក្នុងប្រទេសកម្ពុជា ។ ខេត្តកំពង់ចាមតែឯង មានប្រជាជនមូស្លីមរហូតដល់ទៅ៤២ភាគរយ ឬក៏ជិត៥០ភាគរយនៃចំនួនប្រជាជនចាមទាំងអស់ ។ ស្រុកដែលមានជនជាតិចាមរស់នៅច្រើនជាងគេនៅកម្ពុជា គឺស្រុកត្បូងឃ្មុំ ដែលមានជនជាតិចាមប្រមាណ៤៣.០៧៥នាក់ ។ តំបន់ដែលស្ថិតនៅកណ្តាលប្រទេសកម្ពុជាខាងកើតទន្លេមេគង្គ គឺជាទីលំនៅរបស់ប្រជាជនចាមប្រមាណ ៦០ភាគរយ ។ ចំនួនទាំងអស់នេះធ្វើឲ្យយើងអាចយល់បានពីជីវិតរបស់ជនជាតិចាមនៅក្នុងប្រវត្តិសាស្ត្រ និងបទពិសោធន៍ជនជាតិចាមនៅក្រោមរបបខ្មែរក្រហម ។

ទីលំនៅរបស់ជនជាតិចាមក៏បង្ហាញពីទិដ្ឋភាពមួយទៀតនៃអត្តសញ្ញាណនយោបាយរបស់ចាម ។ នៅខេត្តដែលមានជនជាតិ

ចាមរស់នៅច្រើនដូចជាខេត្តកំពង់ចាម និងកំពង់ឆ្នាំង ជនជាតិចាមរស់នៅជុំគ្នា និងដាច់ដោយឡែកពីគេ ជាងនៅខេត្តដែលមានប្រជាជនចាមរស់នៅតិច ។ ខេត្តដែលមានជនជាតិចាមរស់នៅច្រើនមានលក្ខណៈសកលជាងខេត្តផ្សេងៗ ដោយសារតែប្រជាជនចាមនៅខេត្តនេះមានទំនាក់ទំនងច្រើនជាមួយប្រជាជនម៉ូស្លីមនៅបរទេស តាមរយៈអង្គការផ្តល់ជំនួយ និងស្ថាប័នម៉ូស្លីមដែលផ្តល់ការឧបត្ថម្ភផ្នែកអប់រំ ការអភិវឌ្ឍន៍សង្គម និងការផ្សព្វផ្សាយសាសនា ។

ខេត្តដែលមានជនជាតិចាមរស់នៅតិច មានការប្រាស្រ័យទាក់ទងជាមួយសហគមន៍ខ្មែរច្រើនជាងខេត្តដែលមានជនជាតិចាមរស់នៅច្រើន ។ ការប្រាស្រ័យទាក់ទងច្រើនជាង មានន័យថា យុវជន និងយុវនារីចាមអាចនិយាយខ្មែរបានស្ទាត់ជាង មានការចាប់អារម្មណ៍លើវប្បធម៌ខ្មែរច្រើនជាង ចូលរួមសកម្មភាពជាមួយខ្មែរ និងចូលចុះទៅក្នុងសង្គមខ្មែរច្រើនជាង ។ ជនជាតិចាមនៅខេត្តទាំងនេះមានលក្ខណៈស្រដៀងគ្នាទៅនឹងខ្មែរច្រើន ដោយសារតែជីវិតចាមទាំងនោះ វិវត្តន៍លាយឡំគ្នាជាមួយនឹងជនជាតិខ្មែរក្នុងសង្គមខ្មែរ ។

អត្តសញ្ញាណស្នូលរបស់ជនជាតិចាមជាម៉ូស្លីម កំណត់អត្តសញ្ញាណសេដ្ឋកិច្ចនៅក្នុងសង្គមកម្ពុជា ។ ក្នុងខណៈដែលមុខរបរជំនួញជនជាតិចិន និងខ្មែរទាក់ទងទៅនឹងសាច់ជ្រូក របររកស៊ីរបស់ជនជាតិចាមទាក់ទងទៅនឹងសាច់គោ និងត្រីដែលប្រការនេះគឺបណ្តាលមកពីអត្តសញ្ញាណអ៊ីស្លាមរបស់ខ្លួន ។ ចាមមិនត្រឹមតែលក់សាច់គោ និងត្រីទៅជនជាតិម៉ូស្លីមប៉ុណ្ណោះទេ ថែមទាំងលក់ទៅឲ្យជនជាតិខ្មែរ និងជនជាតិផ្សេងៗទៀត ។ ជនជាតិចាមធ្វើស្រែចម្ការនៅរដូវវស្សាដូចខ្មែរដែរ ពេលរដូវនេសាទត្រូវបានហាមឃាត់ ។ ជនជាតិចាមតិចតួចណាស់ មានមុខរបរជាអ្នកជំនួញ ដើររកស៊ីពីភូមិចាមមួយទៅភូមិមួយទៀត ។ អ្នកជំនួញមួយចំនួននាំផលិតផលក្នុងស្រុកចេញដូចជា ស្រូវ ត្រី និងផលិតផលធ្វើដោយដៃទៅកាន់រដ្ឋ កេឡាន់តាន់ នៅប្រទេសម៉ាឡេស៊ី ទីតាំងដែលខ្លួនលក់ទំនិញទៅជនជាតិចាមរស់នៅទីនោះ និងនាំចូលមកវិញនូវទំនិញម៉ាឡេមកលក់ឲ្យម៉ូស្លីមនៅប្រទេសកម្ពុជា ។

ជំពូកនេះបានពិនិត្យទៅលើសម្លៀកបំពាក់ចាម ។ សម្លៀកបំពាក់មិនមែនគ្រាន់តែជាគ្រឿងសម្គាល់ និងពង្រឹងអត្តសញ្ញាណនិកាយខុសៗគ្នារបស់ចាមប៉ុណ្ណោះទេ សម្លៀកបំពាក់ក៏ត្រូវបានប្រើប្រាស់ដើម្បីជាមធ្យោបាយក្នុងការពង្រឹងអត្តសញ្ញាណនយោបាយរបស់ខ្លួនដែរ ។ បុរសម៉ូស្លីមគ្មានសម្លៀកបំពាក់ជាក់លាក់ណាឲ្យប្លែកពីបុរសខ្មែរឡើយនៅក្នុងការរស់នៅប្រចាំថ្ងៃ ។ ចាប់តាំងពីរបបខ្មែរក្រហម (ពិភាក្សាក្នុងជំពូកទី៤) មក បុរសចាមស្លៀកពាក់ស្រដៀងទៅនឹងខ្មែរ និងប្រើឈ្មោះខ្មែរ ជាពិសេសចំពោះបុរសចាមដែលធ្វើការលាយឡំនឹងខ្មែរ ។

សម្លៀកបំពាក់សម្រាប់ស្ត្រីចាម បង្ហាញពីអត្តសញ្ញាណសាសនាច្បាស់លាស់ជាងសម្លៀកបំពាក់បុរស ។ សម្លៀកបំពាក់នារីចាមអាចត្រូវបានបែងចែកជា៤ប្រភេទ បង្ហាញពីកម្រិតនៃការប្រតិបត្តិសាសនា ។ ស្ត្រីចាមដែលជឿស៊ប់នឹងសាសនា ពាក់អាវដៃវែងខ្មៅហៅថា ជីលបាប់ (jilbab) ជាមួយនឹង ហែចាប់ (hijab) និងកន្សែងបិទមុខ ។ ស្ត្រីក្រុមនេះរស់នៅភូមិដែលមានឥទ្ធិពល ក្រុមតាប្លីហ្គ ចាមាត់ដូចជា ភូមិទ្រា២ និងព្រែកប្រា ។ ស្ត្រីក្រុមនេះ មានការប្រាស្រ័យតិចតួចជាមួយសហគមន៍ខ្មែរ និងក្រុមដទៃទៀត នៅខាងក្រៅ ។ ហេតុនេះ ក្រុមនេះមិនសូវជាមានលក្ខណៈស៊ីគ្នានឹងម៉ូស្លីម នៅក្នុងស្រុកទេ តែងរកទៅរកសកលភាវូបនីយកម្មច្រើនជាង ដោយសារតែសម្លៀកបំពាក់របៀបនេះ ត្រូវបានប្រើប្រាស់នៅក្នុងសហគមន៍អ៊ីស្លាមដែលប្រតិបត្តិសាសនាតឹងរ៉ឹងនៅលើសកលលោក ។

ក្រុមស្ត្រីម៉ូស្លីមដែលមិនសូវប្រតិបត្តិសាសនាខ្ជាប់ខ្ជួននោះ មានចរិតលក្ខណៈចូលចុះទៅនឹងអ្នកក្នុងស្រុកជាង និងឈានទៅរកលក្ខណៈសកលផង ។ ជាទូទៅ ស្ត្រីក្រុមនេះពាក់តែ ហែចាប់ ទេ តែពាក់ជាប់លាប់ និងត្រឹមត្រូវដោយមិនឲ្យឃើញសក់ឡើយ ។ ស្ត្រីក្រុមនេះប្រាស្រ័យទាក់ទងជាមួយក្រុមជនជាតិផ្សេងៗ នៅកន្លែងការងារ សាលារៀន និងទីសាធារណៈ ។ ក្រុមស្ត្រីចាមដែលស្លៀកពាក់ត្រឹមត្រូវ ប្រកាន់សាសនាកាន់តែមិនសូវខ្ជាប់ខ្ជួនដូចពីរក្រុមទៀត ។ ស្ត្រីក្រុមនេះពាក់ ហែចាប់ និងកន្សែងគ្របក្បាលខាងក្រៅផ្ទះ តែពាក់មិនជាប់លាប់ទេ ។ ស្ត្រីក្រុមនេះមិនសូវបារម្ភថា ពាក់កន្សែងនោះគ្របក្បាលជិតឬអត់នោះទេ ។ ស្ត្រីមកពីក្រុមអ៊ីមាំសាន់ មានទម្លាប់ពាក់ក្រមាស្រដៀងគ្នាទៅនឹងរបៀបនេះដែរ ដោយសារតែស្ត្រីនេះមានការប្រតិបត្តិខុសពីនិកាយផ្សេងៗ យើងមិនអាចកំណត់សម្គាល់ពីកម្រិតនៃការគោរពប្រតិបត្តិសាសនាតាមរយៈកន្សែង

គ្របក្បាលនោះទេ ។ ក្រុមនេះមានលក្ខណៈក្នុងស្រុកជាងក្រុមពីរខាងលើ ។ ស្ត្រីនៅក្នុងក្រុមចុងក្រោយ ក្រុមសេរីមានលក្ខណៈទំនើបជាងគេ និងទទួលឥទ្ធិពលពីការសាសនាអ៊ីស្លាមតិចតួច ។ ស្ត្រីក្រុមនេះមិនពាក់កន្សែងក្បាល ហើយប្រហែលជាមិនចូលរួមក្នុងពិធីបុណ្យសាសនាអ៊ីស្លាមផ្សេងៗទេ ។ ក្រុមនេះចូលគ្នាច្រើនជាមួយនឹងជនជាតិខ្មែរ តែក៏មានលក្ខណៈសកលដែរដោយសារតែទទួលឥទ្ធិពលវប្បធម៌បរទេសច្រើន ។ ស្ត្រីក្រុមនេះច្រើនរស់នៅលាយឡំជាមួយសហគមន៍ផ្សេងៗ ។

ដូចដែលបានបញ្ជាក់នៅក្នុងជំពូកទី១ អ្នកនិពន្ធយល់ថាអត្តសញ្ញាណចាមមូស្លីមជាដែនកំណត់ដែលក្រុមនិកាយនិមួយៗព្យាយាមកំណត់ ។ ការរៀបការឆ្លងសាសន៍គឺជាមធ្យោបាយមួយដែលអាចផ្លាស់ប្តូរអត្តសញ្ញាណស្នូលរបស់ជនជាតិចាមបាន ។ ការរៀបការឆ្លងសាសន៍អាចក្លាយជាព្រំដែនក្នុងទំនាក់ទំនងរវាងចាមនិងខ្មែរ ។ ចាម និងខ្មែររៀបការនឹងគ្នាច្រើនជាងមុន ដោយសារតែការប្រាស្រ័យទាក់ទងរវាងសហគមន៍ទាំងពីរមានការកើនឡើងជាងមុន ទោះបីជាមានជនជាតិចាមមួយចំនួនព្យាយាមកាត់បន្ថយការប្រាស្រ័យទាក់ទងគ្នានេះក៏ដោយ ហើយប្រជាជនចាមក៏មានការកើនឡើង ។ ការរៀបការឆ្លងសាសន៍ច្រើនកើតមាននៅភូមិដែលមានសហគមន៍ចាមនិងខ្មែររស់នៅជិតជិតនឹងគ្នា ។ យុវជនចាម និងខ្មែរជួបគ្នានៅសាលារៀន កន្លែងការងារ ទីសាធារណៈ និងតាមប្រព័ន្ធអ៊ីនធឺណែត ។ ជនជាតិចាមស្វាគមន៍ការរៀបការឆ្លងសាសន៍លុះត្រាតែ ខ្មែរប្តូរសាសន៍ និងគោរពតាមប្រពៃណីអ៊ីស្លាម ។ ជនជាតិខ្មែរហាក់ដូចជាមិនសូវពេញចិត្តនឹងការរៀបការឆ្លងសាសន៍នោះទេ ពីព្រោះតម្រូវឲ្យខ្មែរប្តូរសាសន៍ទៅជាអ៊ីស្លាម ដែលនាំឲ្យខ្មែរផ្លាស់ប្តូរអត្តសញ្ញាណពីពុទ្ធសាសនិកទៅជាមូស្លីម ។ ជនជាតិខ្មែរមួយចំនួន នៅតែចាត់ទុកជនជាតិចាមថា ជាជនជាតិមួយអន់ខ្សោយ ។ ជនជាតិខ្មែរមួយចំនួនបារម្ភថា ចំនួនអ្នកកាន់សាសនាព្រះពុទ្ធនឹងប្រឈមមុខនឹងការធ្លាក់ចុះ នៅពេលរៀបការឆ្លងសាសន៍ ពីព្រោះមានជនជាតិចាមតិចតួចណាស់ដែលប្តូរទៅជាកាន់សាសនាព្រះពុទ្ធក្រោយពីរៀបការរួច ។ គូស្នេហ៍ចាម និងខ្មែរ ពេលខ្លះត្រូវតែបង្ខំចិត្តបែកគ្នា ពីព្រោះគូស្នេហ៍នោះមិនអាចស្វែងរកចំណុចរួមគ្នាបាន ។ មានករណីតិចតួចណាស់ ដែលចាមប្តូរទៅកាន់សាសនាព្រះពុទ្ធក្រោយពីរៀបការរួច ។

អត្តសញ្ញាណនិកាយសាសនារបស់ចាម កំពុងតែឈានទៅរកសកលភាវូបនីយកម្ម ដោយសារជនជាតិចាមបានបោះបង់ចោលជំនឿ និងប្រពៃណីដើមរបស់ខ្លួន ។ បច្ចុប្បន្ននេះ យើងមិនងាយនឹងរកចាមដែលចេះវិជ្ជាវេទមន្តនោះទេ ។ ប្រការនេះធ្វើឲ្យខ្មែរមានភាពងាយស្រួលក្នុងការទំនាក់ទំនងជាងមុន ហើយសម្រួលបានមួយចំណែកដល់ការរស់នៅចុះសម្រុងនឹងគ្នារវាងជនជាតិទាំងពីរ ។

ជនជាតិចាម ចាំបាច់ត្រូវអនុវត្តតាមគោលការណ៍ទាំង៥របស់អ៊ីស្លាម រួមមាន ស្ហាហាដា *(shahada)* សាលាត់ *(salat)* ហ្សាកាត់ *(zakat)* ការបួសបង្អត់អាហារ និងការធ្វើហាជ្ជ និងពិធីសាសនាអ៊ីស្លាមផ្សេងៗទៀតរៀងរាល់ឆ្នាំ ។ ដោយមានឥទ្ធិពលពីសកលភាវូបនីយកម្មនៅកម្ពុជាសព្វថ្ងៃ ជនជាតិចាមប្រារព្ធពិធីសាសនាច្រើនជាងពីទសវត្សរ៍១៩៨០ និងមុននេះទៀត ដោយសារតែមានការណែនាំពីមូស្លីមមកពីប្រទេសក្រៅ និងនិស្សិតចាមដែលទទួលការសិក្សានៅប្រទេសដែលកាន់សាសនាអ៊ីស្លាម ។ ហេតុនេះការអនុវត្តសាសនាអ៊ីស្លាមបានឈានទៅរកសកលភាវូបនីយកម្មជាងពីពេលមុន ។

ជនជាតិចាមចែករំលែកអត្តសញ្ញាណមូស្លីម (អត្តសញ្ញាណស្នូល) រួមគ្នាជាមួយនឹងសហគមន៍អ៊ីស្លាម នៅលើសកលលោកតាមការធ្វើហាជ្ជនៅទីក្រុងម៉ាកាសជារៀងរាល់ឆ្នាំ ។ ជនជាតិចាមនៅកម្ពុជា បានធ្វើដំណើរទៅទីក្រុងម៉ាកាស ចាប់តាំងពីដើមសតវត្សទី២០មកម្ល៉េះ ប៉ុន្តែកាលនោះចំនួនអ្នកទៅចូលរួមមាន ចំនួនតិចតួចបើប្រៀបធៀបនឹងពេលថ្មីៗនេះ ។ សព្វថ្ងៃក្នុងមួយឆ្នាំៗមានចាមរាប់រយនាក់ធ្វើដំណើរទៅទីក្រុងម៉ាកាសដើម្បីបំពេញកាតព្វកិច្ចសាសនាអ៊ីស្លាមនេះ ។ អ្នកទៅចូលរួមនេះ ច្រើនមានការជួយឧបត្ថម្ភពីអ្នកផ្តល់ជំនួយមូស្លីមមកពីបរទេស និងថវិកាផ្ទាល់ខ្លួនរបស់អ្នកទៅធ្វើហាជ្ជ ។ ការធ្វើហាជ្ជទៅម៉ាកាសរឹតតែធ្វើឲ្យសហគមន៍ចាមឈានចូលទៅកៀកសកលលោកកាន់តែខ្លាំង តាមរយៈការប្រាស្រ័យទាក់ទងជាមួយជនជាតិមូស្លីមផ្សេងទៀត ។ ការធ្វើហាជ្ជនេះក៏ជួយជំរុញឲ្យមានភាពស្មើគ្នា បង្កើនការសិក្សាផ្នែកសាសនា និងបង្កើនបណ្តាញពីប្រទេសមួយទៅប្រទេសមួយទៀត ។ **(តទៅលេខក្រោយ)**

**អេង កុកថាយ**

# តើការធ្វើពហិការពុំចូលរួមសវនាការរបស់ក្រុមមេធាវីការពារក្តីខៀវ សំផន ជាកំហុសវិជ្ជាជីវៈ?

បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងចេញសាលក្រមនៅពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ផ្តន្ទាទោសជនជាប់ចោទ នួន ជា និងជនជាប់ចោទ ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិតក្នុងសំណុំរឿង ០០២ ដំណាក់កាលទី១ (០០២/០១) អង្គជំនុំជម្រះសាលាដំបូង ដែលមានសមាសភាពចៅក្រមជំនុំជម្រះក្តីដដែល បានប្រកាសបន្តបើកសវនាការដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង០០២ដំណាក់កាលទី២ (០០២/០២) នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ។ ឆ្លើយតបនឹងសេចក្តីប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទ ខៀវ សំផន បានស្នើសុំអង្គជំនុំជម្រះសាលាដំបូងឲ្យពន្យារពេលការចាប់ផ្តើមសវនាការលើសំណុំរឿង០០២ ដំណាក់កាលទី២ រហូតដល់ពេលបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង០០២ ដំណាក់កាលទី១ ត្រូវបានដាក់រួចរាល់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដោយលើកឡើងថា ការបើកសវនាការលើសំណុំរឿង០០២ ដំណាក់កាលទី២ ក្នុងពេលដំណាលគ្នាជាមួយនឹងការតាក់តែងសារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២ ដំណាក់កាលទី១ មិនអាចឲ្យខ្លួន និងមេធាវីការពារក្តីផ្តង់អារម្មណ៍លើសារណាបណ្តឹងសាទុក្ខបានទេ ។ ដោយយោងលើមូលហេតុនេះ ជនជាប់ចោទ ខៀវ សំផន បានសម្រេចចំណាយពេលទាំងអស់ដើម្បីតាក់តែងសារណាបណ្តឹងសាទុក្ខដែលខ្លួនចាត់ទុកថាមានសារសំខាន់ខ្លាំងដើម្បីប្រឆាំងនឹងការចោទប្រកាន់ទាក់ទងនឹងការ



ជនរងគ្រោះដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម បានរង់ចាំស្តាប់ការប្រកាសសាលក្រមរបស់ នួន ជា និង ខៀវ សំផន នៅសាលាក្តីខ្មែរក្រហម

ទទួលខុសត្រូវព្រហ្មទណ្ឌ និងបានណែនាំដល់មេធាវីការពារក្ដីរបស់ខ្លួនឲ្យធ្វើតាមដូច្នេះដែរ ។ បន្ទាប់ពីមានការណែនាំពីជនជាប់ចោទ ខៀវ សំផន ក្រុមមេធាវីការពារក្ដីរបស់ ខៀវ សំផន បានប្រកាសថា ពួកគេនឹងពុំចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២ ដំណាក់កាលទី២ទេ ដោយសារការចូលរួមនេះ នឹងធ្វើឲ្យប៉ះពាល់ដល់លទ្ធភាពរបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន ក្នុងការបំពេញការងារឲ្យបានពេញលេញលើបណ្ដឹងសារទុក្ខ ទោះបីជាមានដីកាបង្គាប់ពីសំណាក់អង្គជំនុំជម្រះសាលាដំបូងឲ្យក្រុមមេធាវីការពារក្ដី ខៀវ សំផន ត្រូវចូលរួមនៅក្នុងសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២ ដំណាក់កាលទី២ ជាច្រើនលើកច្រើនសាយ៉ាងណាក៏ដោយ ។

ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានអះអាងថា ការសម្រេចចិត្តដូច្នេះ គឺជាជម្រើសយុទ្ធសាស្ត្រមួយរបស់ក្រុមមេធាវីការពារក្ដី និងពុំធ្វើឲ្យខាតពេលវេលា ឬរំខានដល់នីតិវិធីសវនាការឡើយ ។ ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានបន្តថា អង្គជំនុំជម្រះសាលាដំបូងបានដាក់កូនក្ដីរបស់ខ្លួន និងក្រុមខ្លួនក្នុងស្ថានភាពបង្ខំជាន់គ្នាអស់រយៈពេល១ឆ្នាំហើយ និងថា នៅពេលនេះជាពេលដែលក្រុមមេធាវី ត្រូវប្រមូលផ្ដុំការងារលើបណ្ដឹងសាទុក្ខដែលជាមធ្យោបាយតែមួយគត់របស់ ខៀវ សំផន ដើម្បីជំទាស់នឹងសេចក្ដីសម្រេចមួយដែលផ្ដន្ទាទោសដាក់ពន្ធនាគារគាត់អស់មួយជីវិត ។ ជាងនេះទៅទៀត ក្រុមមេធាវី ខៀវ សំផន បានសង្កត់ធ្ងន់ថា ប្រសិនបើខ្លួនមិនយល់ស្របតាមជំហររបស់កូនក្ដីទេនោះ ឬបើយល់ថា វាមិនសមរម្យទេនោះ ក្រុមខ្លួនគួរតែបដិសេធការណែនាំរបស់កូនក្ដី ហើយសុំលាឈប់ពីព្រោះថា ក្នុងសីលធម៌វិជ្ជាជីវៈមេធាវី មេធាវីម្នាក់មិនអាចធ្វើអ្វីផ្ទុយនឹងបំណងរបស់កូនក្ដីខ្លួនបានឡើយ លើកលែងការណែនាំរបស់កូនក្ដីនោះផ្ទុយនឹងសម្បថរបស់ខ្លួនដែលជាមេធាវី ។ ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានលើកឡើងថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យខ្លួនត្រូវតែចូលរួមកិច្ចដំណើរការនីតិវិធីសវនាការដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង០០២ ដំណាក់កាលទី២ គឺមានគោលដៅបង្ខំក្រុមរបស់ខ្លួនឲ្យបំពានលើកាតព្វកិច្ចវិជ្ជាជីវៈ ក្រមសីលធម៌វិជ្ជាជីវៈ និងបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ឯករាជភាពរបស់មេធាវីការពារក្ដីនៅចំពោះមុខតុលាការ ពីព្រោះសេចក្ដីសម្រេចនេះមានបំណងបង្ខំឲ្យក្រុមរបស់ខ្លួនធ្វើអ្វីដែលផ្ទុយពីផលប្រយោជន៍របស់កូនក្ដី ។

ទោះបីជាក្រុមមេធាវីការពារក្ដីរបស់ជនជាប់ចោទ ខៀវ សំផន ព្យាយាមលើកឡើងនូវអំណះអំណាង និងហេតុផលជាច្រើន ដើម្បីធ្វើយុត្តិកម្មចំពោះការធ្វើពហិការពុំចូលរួមក្នុងសវនាការដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង០០២ ដំណាក់កាលទី២ យ៉ាងណាក្ដី នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចចេញដីកាមួយ ដោយបញ្ជូនការប្រព្រឹត្តរបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន ដែលអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថា ជាការប្រព្រឹត្តផ្ទុយពីក្រមសីលធម៌ និងវិជ្ជាជីវៈជាមេធាវី ទៅប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងទៅប្រធានគណៈមេធាវីក្រុងប៉ារីស ដែលជាអង្គភាពមានសមត្ថកិច្ចដើម្បីឲ្យក្រុមប្រឹក្សាវិន័យនៃអង្គភាពទាំងនេះចាត់វិធានការ ។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងពុំបានដាក់ទណ្ឌកម្ម ឬបដិសេធក្នុងការចូលរួមសវនាការរបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន ទេ ទោះបីជាវិធាន៣៨ នៃវិធានផ្ទៃក្នុង បានផ្ដល់អំណាចដល់អង្គជំនុំជម្រះសាលាដំបូងអាចចាត់វិធានការផ្សេងៗ ដោយឯករាជ្យពីគណៈមេធាវីនីមួយៗក៏ដោយ ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចចាត់តាំងមេធាវីប្រចាំការចំនួន២រូប បន្ថែមលើមេធាវីការពារក្ដីរបស់ ខៀវ សំផន នាពេលបច្ចុប្បន្ន ។

នៅក្នុងដីកាបញ្ជូនការប្រព្រឹត្តរបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន ទៅអង្គភាពមានសមត្ថកិច្ចអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការបដិសេធរបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន ក្នុងការមិនចូលរួមសវនាការ គឺជាការរំលោភបំពានដោយផ្ទាល់ទៅលើដីកាបង្គាប់របស់អង្គជំនុំជម្រះ និងបានធ្វើឲ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីយ៉ាងធ្ងន់ធ្ងរ និងដោយមានចេតនាដែលបានធ្វើឲ្យបាត់បង់ការជំនុំជម្រះចំនួន២៥ថ្ងៃ ក្នុងរយៈពេល១០សប្ដាហ៍ ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ការខាតបង់រយៈពេលនៃដំណើរការសវនាការជំនុំជម្រះជាង២ខែ គឺជាពេលវេលាដ៏ច្រើនក្នុងរឿងក្ដីមួយដែលជនជាប់ចោទ សាក្សី ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី សុទ្ធតែមានវ័យកាន់តែចាស់ ។

ទោះបីជា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការប្រព្រឹត្តរបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន ជាកំហុសក្រុម

សីលធម៌ និងវិជ្ជាជីវៈជាមេធាវីយ៉ាងណាក៏ដោយ មានតែគណៈមេធាវីមួយប៉ុណ្ណោះ ដែលមានសិទ្ធិអាចសម្រេចថា តើការប្រព្រឹត្តរបស់ក្រុមមេធាវី ខៀវ សំផន នោះ ជាកំហុសវិជ្ជាជីវៈមែនឬយ៉ាងណា ។ នេះដោយសារតែវិជ្ជាជីវៈមេធាវី គឺជាវិជ្ជាជីវៈមួយឯករាជ្យ និងមិនស្ថិតនៅក្រោមចំណុះស្ថាប័នតុលាការ ។

ប្រសិនបើគណៈមេធាវីរកឃើញថា ក្រុមមេធាវីការពារក្តី ខៀវ សំផនពិតជាបានប្រព្រឹត្តកំហុសវិជ្ជាជីវៈ និងក្រមសីលធម៌ជាមេធាវី ដូចការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងប្រាកដមែន គណៈមេធាវីដែលជាស្ថាប័នមានសមត្ថកិច្ចនឹងសម្រេចដាក់ទណ្ឌកម្មជាបទវិន័យចំពោះមេធាវីទាំងនេះ ។ យោងតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវីរបស់ព្រះរាជាណាចក្រកម្ពុជា ទណ្ឌកម្មជាបទវិន័យដែលដាក់ចំពោះមេធាវីដែលប្រព្រឹត្តខុសនឹងវិជ្ជាជីវៈ និងក្រមសីលធម៌មានដូចជា ៖ ការព្រមាន ការស្តីបន្ទោស ការហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈពេលដែលពុំអាចលើសពី២ឆ្នាំ និងទណ្ឌកម្មដែលមានលក្ខណៈធ្ងន់ធ្ងរជាងគេនោះ គឺត្រូវលុបឈ្មោះចោលពីបញ្ជីនៃគណៈមេធាវី ឬពីបញ្ជីនៃមេធាវីកម្មសិក្សា ឬការហូតងារកិត្តិយស ។


ជនជាតិខ្មែរអ៊ីស្លាម ផ្តល់បទសម្ភាសដល់ទូរទស្សន៍ជាតិ នៅសាលាក្តីខ្មែរក្រហម

ទោះបីជា ការធ្វើពហិការពុំចូលរួមសវនាការរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន នៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី២ ត្រូវបានមើលឃើញយ៉ាងច្បាស់ថា បានបំពានលើដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង និងបានធ្វើឲ្យសវនាការចំនួន២៥ថ្ងៃ ដែលបានគ្រោងទុកត្រូវលុបចោលក៏ដោយ ប៉ុន្តែយុទ្ធសាស្ត្រការពារក្តី និងអំណះអំណាងរបស់ក្រុមមេធាវី ខៀវ សំផន ទំនងជានឹងធ្វើឲ្យក្រុមប្រឹក្សាគណៈមេធាវីពិបាកនឹងសម្រេចថា សកម្មភាពនេះជាការប្រព្រឹត្តកំហុសវិជ្ជាជីវៈ និងក្រមសីលធម៌ជាមេធាវី ។ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានលើកឡើងម្តងហើយម្តងទៀតថា ក្រុមរបស់ខ្លួន មានភារកិច្ចរក្សាភាពស្មោះត្រង់ និងមានភារកិច្ចបម្រើផលប្រយោជន៍ឲ្យល្អប្រសើរដល់កូនក្តីរបស់ខ្លួនដែលសូម្បីតែអង្គជំនុំជម្រះសាលាដំបូងក៏បានទទួលស្គាល់ពីភារកិច្ចទាំងនេះដែរ ។

ម៉្យាងវិញទៀត ទោះបីជាផលប្រយោជន៍នៃយុត្តិធម៌តម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងត្រូវតែចាប់ផ្តើមកិច្ចដំណើរការសំណុំរឿង០០២ ដំណាក់កាលទី២ ឲ្យបានកាន់តែឆាប់រហ័សយ៉ាងណាក៏ដោយ សម្រាប់តុលាការដែលប្រើប្រាស់បទដ្ឋានអន្តរជាតិមួយនេះ ការគោរពសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានពេលវេលាចាំបាច់សម្រាប់រៀបចំសវនាការការពារក្តីរបស់ខ្លួន គឺជារឿងដែលពុំអាចមើលរំលង ។ ដែលនេះទំនងជាហេតុផលមួយទៀត ដែលក្រុមប្រឹក្សាគណៈមេធាវីនឹងត្រូវយកមកថ្លឹងថ្លែងរវាងអំណះអំណាងរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន និងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងដែលស្នើឲ្យចាត់វិធានការចំពោះការប្រព្រឹត្តរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ។

ប្រសិនបើគណៈមេធាវីពុំឆ្លើយតបនឹងដីកាបញ្ជូនការប្រព្រឹត្តរបស់មេធាវីការពារក្តី ខៀវ សំផនរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរយៈពេល២ខែ ចាប់ពីថ្ងៃដែលគណៈមេធាវីទទួលបានដីកាដែលអង្គជំនុំជម្រះបានផ្ញើជូនទេ មានន័យថា បណ្តឹងនេះត្រូវបានបដិសេធ ឬមានន័យម៉្យាងទៀតថា គណៈមេធាវីពុំបានរកឃើញពីការប្រព្រឹត្តកំហុសវិជ្ជាជីវៈរបស់មេធាវីការពារក្តី ខៀវ សំផនដូចការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងទេ ។

**លីម ច័យផ័ត្រ**

# ការផ្តល់វិធានការការពារចំពោះសាក្សីផ្តល់សក្ខីកម្ម អំពីគុកក្រាំងតាចាន់

នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមបានសម្រេចផ្តល់វិធានការការពារចំពោះសាក្សីមួយរូបឈ្មោះ ស្រី ថន ដែលត្រូវបានកោះហៅឲ្យចូលមកផ្តល់សក្ខីកម្មទាក់ទងនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ ជាទីដែលមនុស្សច្រើនជាង១៧.០០០ នាក់ត្រូវបានសម្លាប់ ។ ដើម្បីផ្តល់ការការពារចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់មិនឲ្យមានការផ្សព្វផ្សាយអំពីអាសយដ្ឋាន និងរូបភាពរបស់សាក្សីដល់សាធារណជន រីឯប្រព័ន្ធផ្សព្វផ្សាយនានាក៏ពុំត្រូវបានអនុញ្ញាតឲ្យផ្សព្វផ្សាយអំពីរូបថត ឬរូបភាពរបស់សាក្សីរូបនេះដែរ ទោះបីជារូបថតនោះ ដែលត្រូវបានថតនៅមុនពេលសាក្សីរូបនេះចូលមកផ្តល់សក្ខីកម្មយ៉ាងណាក៏ដោយ ។ វិធានការនេះត្រូវបានដាក់ឲ្យអនុវត្ត បន្ទាប់ពីមានការស្នើសុំពីសាក្សី ដោយសារមានការព្រួយបារម្ភពីបញ្ហាសុវត្ថិភាព ។ យោងតាមសក្ខីកម្មរបស់សាក្សី ស្រី ថន ដែលរៀបរាប់នៅក្នុងអំឡុងពេលសវនាការថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥ សាក្សីរូបនេះគឺជាអតីតយោធាខ្មែរក្រហមនៅភូមិភាគនិរតី ហើយក៏ជាអ្នកដែលបានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងមន្ទីរសុខក្រាំងតាចាន់ ។

ចាប់តាំងពីការចាប់ផ្តើមនីតិវិធីសវនាការលើសំណុំរឿង ០០២ នៅក្នុងឆ្នាំ២០១១ នេះជាលើកទី១ហើយ ដែលសាក្សីចូលមកផ្តល់សក្ខីកម្មបានស្នើសុំវិធានការការពារដោយពុំចង់ឲ្យមានការបង្ហាញអំពីអត្តសញ្ញាណរបស់ខ្លួនជាសាធារណៈ ។ ជាការពិត ការមិនបង្ហាញអត្តសញ្ញាណរបស់សាក្សីជាសាធារណៈ គឺជាមធ្យោបាយមួយដើម្បីធានាសន្តិសុខផ្លូវចិត្តរបស់សាក្សីដែលព្រួយបារម្ភថាអាចនឹងមានបញ្ហាកើតឡើងដោយសារការផ្តល់សក្ខីកម្មរបស់ខ្លួន ។ ម្យ៉ាងវិញទៀត ការសម្រេចផ្តល់វិធានការការពារដល់សាក្សីពីសំណាក់អង្គជំនុំជម្រះ គឺដើម្បីធានាថាសាក្សីមានសន្តិសុខ សុវត្ថិភាព និងមិនមានអារម្មណ៍ភ័យខ្លាចអំពីការផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ និងកន្លែងផ្សេងៗទៀតនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះបីជាអង្គជំនុំជម្រះបានសម្រេចឲ្យមានការបំផ្លែងរូបភាពរបស់សាក្សីតាមរយៈប្រព័ន្ធបច្ចេកវិជ្ជាទំនើប (ធ្វើឲ្យរូបមើលពុំ



មន្ទីរសន្តិសុខក្រាំងតាចាន់ ជាទីកន្លែងដែលមានមនុស្សប្រមាណជាង១៧.០០០ ត្រូវបានសម្លាប់

ច្បាស់) និងមិនអនុញ្ញាតឲ្យបង្ហាញអំពីអាសយដ្ឋានរបស់សាក្សី នៅអំឡុងនៃការផ្ដល់សក្ខីកម្មក៏ដោយ ប៉ុន្តែអង្គជំនុំជម្រះពុំបានហាមឃាត់មិនឲ្យបង្ហាញឈ្មោះរបស់សាក្សីនេះទេ ។

វិធានការការពារដែលត្រូវដាក់ឲ្យអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពុំមែនមានត្រឹមតែការមិនបង្ហាញរូបភាព រូបថត ឬមិនបង្ហាញអំពីអាសយដ្ឋានទេ ប៉ុន្តែមានវិធានការជាច្រើនផ្សេងទៀតដែលអង្គជំនុំជម្រះអាចសម្រេចដាក់ឲ្យអនុវត្ត ដើម្បីធ្វើយ៉ាងណាអាចលាក់បាំងអត្តសញ្ញាណរបស់បុគ្គលដែលទទួលបានការការពារ ដោយពិនិត្យមើលលើកាលៈទេសៈ និងករណីជាក់ស្ដែង ។ វិធានការទាំងនោះមានដូចជា ៖

◆ ការប្រើប្រាស់អាស័យដ្ឋានផ្សេងដើម្បីធ្វើការទំនាក់ទំនង

◆ ការប្រើហស្សនាមនៅពេលនិយាយទៅរកបុគ្គលដែលត្រូវបានការពារ

◆ ការលាក់អត្តសញ្ញាណដោយមិនចាំបាច់សរសេរចូលក្នុងសំណុំរឿង

◆ នៅពេលជនត្រូវចោទ ឬជនសង្ស័យស្នើឲ្យមានការឆ្លើយតទល់គ្នាជាមួយជននោះ គេអាចប្រើប្រាស់បច្ចេកទេសដែលអនុញ្ញាតឲ្យមានការចូលរួមពីចម្ងាយ ឬបំប្លែងសំឡេងដើម ឬបិទភិនភាគរបស់ជននោះ ។

◆ អង្គជំនុំជម្រះអាចរៀបចំសវនាការជាសម្ងាត់ ឬអនុញ្ញាតឲ្យបង្ហាញភ័ស្តុតាងតាមរយៈប្រព័ន្ធអេឡិចត្រូនិច ឬប្រើប្រាស់មធ្យោបាយផ្សេងៗទៀត ។

◆ បង្គាប់ឲ្យធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរដោយរក្សាទុកតាមរបៀបបិទស្លាកបោះត្រា

◆ ការហាមឃាត់សាធារណជនមិនឲ្យចូលពិនិត្យមើលឯកសារពិសេសណាមួយក្នុងសំណុំរឿង ដែលបង្ហាញពីអត្តសញ្ញាណនៃបុគ្គលដែលទទួលបានការការពារ ។

◆ ចេញវិធានការដើម្បីការពារជារូបវន្តដល់បុគ្គលដែលត្រូវការពារ ជាពិសេសផ្ដល់ជាកន្លែងស្នាក់នៅដែលមានសុវត្ថិភាពនៅក្នុង ឬក្រៅប្រទេសកម្ពុជា ។

(សូមមើលលម្អិតនៅក្នុងវិធាន២៩ នៃវិធានផ្ទៃក្នុង និងសេចក្ដីណែនាំស្ដីពីការអនុវត្តវិធានការការពាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលធ្វើវិសោធនកម្មនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៨)

ទោះបីជាសាក្សីមានសិទ្ធិស្នើសុំអង្គជំនុំជម្រះឲ្យចេញបញ្ជាផ្ដល់វិធានការការពារដល់ខ្លួនក៏ដោយ ពុំមែនរាល់ពាក្យសុំទាំងអស់សុទ្ធតែទទួលបានការយល់ព្រមនោះទេ ។ សាក្សីចាំបាច់ត្រូវតែបង្ហាញអង្គជំនុំជម្រះឲ្យឃើញថា ការបង្ហាញខ្លួន និងការផ្ដល់សក្ខីកម្មរបស់ខ្លួនអាចធ្វើឲ្យអាយុជីវិត សុខមាលភាព ឬក្រុមគ្រួសារ ឬញាតិជិតស្និទរបស់ខ្លួន ត្រូវស្ថិតក្នុងសភាពគ្រោះថ្នាក់ធ្ងន់ធ្ងរ ។ ក្រោយពីទទួលបានសំណើសុំពីការពារពីសំណាក់សាក្សី ចៅក្រមនឹងសម្រេចថាតើត្រូវអនុញ្ញាត ឬពុំអនុញ្ញាត ហើយបើអនុញ្ញាតត្រូវប្រើវិធានការបែបណា ដោយត្រូវថ្លឹងថ្លែងអំពីតម្រូវការរបស់សាក្សី និងតម្រូវការរបស់ជនជាប់ចោទដើម្បីឲ្យការជំនុំជម្រះក្ដីអាចធ្វើឡើងប្រកបដោយយុត្តិធម៌ និងស្មើភាព ។

អ្វីដែលគួរឲ្យកត់សម្គាល់ គឺនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលចូលជាធរមាននៅក្នុងឆ្នាំ២០០៧ ពុំបានចែងអំពីវិធានការការពារចំពោះសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីទេ ។ ការខកខាន និងការបន្សល់ទុកឲ្យមានចន្លោះខ្វះខាតនៅក្នុងក្រមនេះ បានធ្វើឲ្យសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីដែលមានការជាប់ពាក់ព័ន្ធនឹងសំណុំរឿងក្ដីនៅតុលាការក្នុងស្រុក មានការព្រួយបារម្ភ ខ្លាចរអា ឬពុំសហការក្នុងការផ្ដល់ចម្លើយជូនចៅក្រមស៊ើបសួរ ឬផ្ដល់សក្ខីកម្មនៅក្នុងសវនាការដោយសារសុវត្ថិភាពសន្តិសុខ និងសុខមាលភាពរបស់អ្នកទាំងនោះពុំត្រូវបានធានាដោយច្បាប់ ។ កត្តានេះអាចនឹងធ្វើឲ្យប៉ះពាល់ដល់ដំណើរការស្វែងរកការពិត និងយុត្តិធម៌សម្រាប់គូភាគីនៃរឿងក្ដី ។ នាពេលអនាគតវិធានទាក់ទងនឹងវិធានការការពារចំពោះសាក្សី និងអ្នកដាក់ពាក្យប្ដឹង គួរត្រូវដាក់បញ្ចូលបន្ថែមទៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដើម្បីបង្កលក្ខណៈងាយស្រួល និងធានាសុវត្ថិភាព និងសន្តិសុខរបស់សាក្សី និងអ្នកដាក់ពាក្យបណ្ដឹង ដែលអាចនឹងទទួលរងការគំរាមកំហែងដោយសារការផ្ដល់សក្ខីកម្មរបស់ខ្លួន ។ ម្យ៉ាងវិញទៀត ការបំពេញបន្ថែមនូវចំណុចកង្វះខាតទាំងឡាយដែលមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះ នឹងធ្វើឲ្យដំណើរការស្វែងរកយុត្តិធម៌កាន់តែមានភាពសុក្រឹត្យ ។ **លឹម ច័យធក្ក**

# ការបំផ្លាញភស្តុតាងដោយអចេតនា

សង្គ្រាមស៊ីវិលរ៉ាំរ៉ៃ និងរបបខ្មែរក្រហមបានធ្វើឲ្យប្រជាជនខ្មែរអស់រាប់លាននាក់ស្លាប់បាត់បង់ជីវិត ។ ប្រជាជនកម្ពុជាក្រោយពីសង្គ្រាមបានកសាងស្តូបគោរពវិញ្ញាណក្ខន្ធ និងប្រមែប្រមូលនូវឆ្អឹងទាំងនោះមកដាក់នៅក្នុងស្តូប ចេតិយ ឬ នៅតាមវត្តអារាមនានាក្នុងសហគមន៍របស់ខ្លួន ។ មជ្ឈមណ្ឌលឯកសារកម្ពុជារកឃើញថា មានស្តូបសម្រាប់គោរពបូជាដល់ជនរងគ្រោះចំនួន៨១ និងរណ្តៅសាកសពចំនួន ១៩.៧៣៣ និង គុកចំនួន ១៩៦ នៅទូទាំងប្រទេសកម្ពុជា គិតត្រឹមឆ្នាំ ២០០៦ ។

ទោះជាមានការយកចិត្តទុកដាក់ពីរដ្ឋាភិបាលកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គការពាក់ព័ន្ធមួយចំនួនដើម្បីប្រមែប្រមូល និងថែរក្សាការចងចាំសម័យខ្មែរក្រហមក៏ដោយ តែការយកចិត្តទុកដាក់លើការថែរក្សាឯកសារជាលាយលក្ខណ៍អក្សរ និងភស្តុតាងបង្ហាញពីការសម្លាប់នៅតាមបណ្តាខេត្តនានានៅមានកម្រិតនៅឡើង ។ ដោយគិតថាវត្ថុតាងទាំងនេះនៅមានអាយុកាលថ្មី មិនគួរទទួលបាននូវការការពារ និងដោយសារសម្ពាធ សេដ្ឋកិច្ចសង្គម ជាហេតុធ្វើឲ្យមានភាពសឹករេចរឹល បាត់បង់ និងទុកចោលដោយគ្មានការថែទាំ ។

សំណួរសួរថា ហេតុអ្វីបានជាយើងត្រូវថែរក្សា និងអភិរក្សភស្តុតាងពីរបបខ្មែរក្រហម?

ភស្តុតាងទាំងនេះមានសារសំខាន់ណាស់ក្នុងការចងចាំ និង



ឆ្អឹង និង លលាដ៍ក្បាល របស់ជនរងគ្រោះ ត្រូវបានគាស់ក្រោយរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩

អប់រំពីប្រវត្តិសាស្ត្រសម័យខ្មែរក្រហមដល់មនុស្សជំនាន់ក្រោយក៏ដូចជាអ្នកសិក្សាស្រាវជ្រាវពីរបបឃោរឃៅបែបនេះនៅលើសកលលោក ដែលអ្នកទាំងអស់នេះពិបាកនឹងជឿថាហេតុការណ៍ដ៏ព្រៃផ្សៃទាំងនេះអាចកើតមកលើប្រជាជនកម្ពុជា និងបណ្តាប្រទេសដទៃទៀត ។ លើសពីនេះ ភស្តុតាងជាឯកសារដើម ឆ្អឹង ខ្នោះឃ្នាងច្រវ៉ាក់ ខ្សែចំណងចងជនរងគ្រោះ សម្លៀកបំពាក់ជនរងគ្រោះ សម្ភារផ្សេងទៀត និងកន្លែងសម្លាប់មនុស្សសុទ្ធសឹងតែជាភស្តុតាងជាក់ស្តែង និងសំខាន់បំផុតក្នុងដំណើរការស្វែងរកការពិត និងយុត្តិធម៌ ។ បើភស្តុតាង និង សាក្សីបាត់បង់ នោះមនុស្សជំនាន់ក្រោយនឹងបាត់បង់នូវឯកសារ និងភស្តុតាងក្នុងការសំអាងនៅក្នុងការសិក្សាស្រាវជ្រាវពីរបបនេះ និងពិបាកជឿជាក់នៅថ្ងៃអនាគតអំពីប្រវត្តិសាស្ត្រមួយនេះ ។ ម្យ៉ាងទៀតប្រជាជនដែលធ្លាប់ឆ្លងកាត់របបនេះ នឹងកាន់តែមានវ័យចំណាស់ដែលគាត់ជាសាក្សីរស់និងអាចប្រាប់ពីរឿងរ៉ាវជីវិតដល់មនុស្សជំនាន់ក្រោយ ។ មានជនរងគ្រោះដែលបានស្លាប់ ហើយបាត់បង់ឱកាសនឹងទទួលបាននូវការគោរព និងយុត្តិធម៌ ។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើសក្ខីកម្មនៅចំពោះមុខតុលាការខ្មែរក្រហម អំពាវនាវដល់មជ្ឈដ្ឋានអន្តរជាតិឲ្យមានការប្រគល់ត្រឡប់មកវិញនូវឯកសារនានាដែលយកចេញពីប្រទេសកម្ពុជា ។ លោកនាយកក៏សូមឲ្យយកចិត្តទុកដាក់លើការថែរក្សា និងឲ្យតម្លៃទៅលើឯកសារទាំងនោះថាឯកសារដើមមួយសន្លឹក គឺមានតម្លៃស្មើនឹងថ្មអង្គរវត្តមួយដុំដែរ ។ ឯកសារ និងភស្តុតាងទាំងនោះមិនត្រឹមតែមានតម្លៃជាប្រវត្តិសាស្ត្រប៉ុណ្ណោះទេ តែវាមានតម្លៃសម្រាប់ជាភស្តុតាងក្នុងការតវ៉ាតាមផ្លូវច្បាប់នៅក្នុងតុលាការដែលធ្វើការជជែកដេញដោលថ្លឹងថ្លែងដោយយោងទៅលើភស្តុតាង ហេតុផលនិងច្បាប់ដែលមាន ។

តាំងតែពីបូរាណមកប្រជាជនខ្មែរ គោរព និងមិនហ៊ានប៉ះពាល់សាកសព ឬ ឆ្អឹងសាកសពនោះទេ ព្រោះមានជំនឿថា របស់ទាំងនោះមានព្រលឹង និងអាចនាំសំណាងល្អ ឬគាំទ្រដល់ខ្លួន និងក្រុមគ្រួសារ ។ ក្រោយមកប្រជាជនដោយមានជីវភាពខ្វះខាត ទើបមិនសូវជាយកចិត្តទុកដាក់នឹងជំនឿ និងគោរពលើព្រលឹងអ្នកស្លាប់ ។ មានកត្តាជាច្រើនទៀតដែលធ្វើឲ្យសីលធម៌នៃការគោរពដល់អ្នកស្លាប់ធ្លាក់ចុះ ។ តាមការសិក្សា និងស្រាវជ្រាវកន្លងមកបានឲ្យដឹងថា ការសឹករេចរឹលវត្ថុតាងនេះគឺដោយសារកត្តាធម្មជាតិ និងកត្តាមនុស្ស ។ ប្រជាជននៅតាមមូលដ្ឋានបានឲ្យដឹងថា មានប្រជាជនខ្លះនៅមានជំនឿគោរពដល់អ្នកស្លាប់ ក៏បានប្រមូលអដ្ឋិធាតុ និងបង្កើតជាទីតាំងគោរពបូជា ដូចជាករណីវត្តថ្មីនៅខេត្តសៀមរាបជាដើម ។ បំណែកអ្នកខ្លះទៀតបាននាំគ្នាគាស់កកាយរកមើលវត្ថុមានតម្លៃជាប់នឹងសាកសពដែលធ្វើឲ្យឆ្អឹងនៅរាយប៉ាយនៅលើដី ទុកឲ្យគោស៊ី



សម្លៀកបំពាក់របស់ជនរងគ្រោះ ដែលព្យួរចោលលើដើមឈើដោយមិនមានការថែរក្សាទុក

និងករណីខ្លះទៀត បណ្តាលមកពីការគាស់ដើម្បីសាងសង់សំណង់ថ្មីៗ ការធ្វើស្រែចម្ការជាដើម ។

ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅតាមខេត្តដើម្បីប្រមូលរកភ័ស្តុតាងមួយចំនួន ដើម្បីនឹងរៀបចំពិព័រណ៍មួយពីរបបខ្មែរក្រហម យើងឃើញថាវត្ថុជាភ័ស្តុតាងជាច្រើន ដូចជា ក្រណាត់រុំមុខ ខ្សែចងអ្នកទោស សម្លៀកបំពាក់ដែលធ្លាប់មាន និងដែលជឿថារក្សាដោយប្រជាជនបានបាត់បង់អស់មួយចំនួនធំ ។ នៅពេលដែលក្រុមការងារសួរថា ហេតុអ្វីបានជាវត្ថុតាងទាំងនោះត្រូវបាត់បង់? អ្នកមើលថែរក្សាទីនោះដែលពីមុនមកធ្លាប់ជាប់គុក បានប្រាប់ថា មុនពេលនឹងកសាងស្តូបដាក់ឆ្អឹងនោះនៅមានក្រណាត់ខោអាវជាច្រើន ក្រមា និងវត្ថុផ្សេងៗទៀតត្រូវក្រុមប្រជាជនរៀបចំប្រមូលដុតចោលអស់ ដោយសម្អាងថាសម្លៀកបំពាក់ទាំងនោះមានក្លិនមិនល្អ និងមិនដឹងថាត្រូវថែរក្សាទុកយ៉ាងដូចម្តេច បើមនុស្សស្លាប់អស់ហើយ ។ អ្នករស់នៅវត្តម្នាក់ទៀតក៏បានឲ្យដឹងថា គាត់មិនដឹងថាមានអ្នកមករកសោះ បើបានដឹងមុន ម៉្លេះសមប្រមូលទុកខោអាវទាំងនោះមួយចំនួន មិនដុតចោលទាំងអស់នោះទេ ។ វត្ថុតាងដែលប្រមូលបាន ហើយរក្សាទុកក្នុងស្តូប ឬ ចេតិយ គឺដាក់គរនៅលើគ្នាដោយមិនមានការថែរក្សាតាមបច្ចេកទេសដែលជាហេតុធ្វើឲ្យខោអាវ និងសម្ភារទាំងនេះងាយនឹងខូចខាត និងបាត់បង់ ។ លើសពីនេះ ឆ្អឹងដែលដាក់គនៅលើគ្នា និងដាក់លាយឡំជាមួយក្រណាត់សម្លៀកបំពាក់ ដោយមិនបានធ្វើការថែរក្សាតាមបែបបច្ចេកទេស និងទុកក្នុងសីតុណ្ហភាពត្រឹមត្រូវក៏នឹងអាចធ្វើឲ្យឆ្អឹងទាំងនោះនឹងខូចខាត និងពុកផុយដែរ ។ យើងទទួលស្គាល់ថា ប្រទេសកម្ពុជាគួរតែមានអ្នកជំនាញបន្ថែមទៀតដែលស្រាវជ្រាវ និងថែរក្សាវត្ថុតាងទាំងអស់នេះ ។ ការថែរក្សាភ័ស្តុតាងទាំងនេះនឹងជួយសម្រួលដល់ការគ្រប់គ្រង និងដំណើរការរបស់ទីតាំងសម្លាប់ និងគុកផ្សេងៗទៀតដែលមានទីតាំងនៅជិតទីក្រុង និង តាមបណ្តាខេត្តនានាដែលនៅជិតក្រុង ។

យើងឃើញថា ទេសចរមកមើលតំបន់ប្រល័យពូជសាសន៍មានការកើនឡើងជាងមុននៅគ្រប់ទីកន្លែងនៅលើពិភពលោក ។ ជាក់ស្តែងសារមន្ទីរហូឡូខស (United States Holocaust Memorial Museum) នៅសហរដ្ឋអាមេរិកដែលមានតាំងបង្ហាញពីឧក្រិដ្ឋកម្មរបស់ពួកណាស៊ី មកលើជនជាតិជ្វីហ ទទួលភ្ញៀវមកទស្សនា ២ លាននាក់ក្នុងឆ្នាំ២០១៤ ។ លើសពីនេះ នៅជំរំឃុំខ្លួនជនជាតិជ្វីហនៅ អោស្វិច (Auschwitz) នៅប្រទេសប៉ូឡូញនៅមានមនុស្ស មកទស្សនា១លាន៥សែននាក់ ក្នុងឆ្នាំ២០១៤ ។ ដូចគ្នានេះដែរ ភ្ញៀវដែលមកទស្សនាទីក្រុងភ្នំពេញគឺភាគច្រើនចង់ទៅមើលសារមន្ទីរទួលស្លែង និងវាលពិឃាតបឹងជើងឯក ។ បើយោងទៅតាមលោកប្រធានមន្ទីរប្រល័យពូជសាសន៍ទួលស្លែងបានឲ្យដឹងថា ចំនួនភ្ញៀវទេសចរណ៍ពេលខែសម្បូរភ្ញៀវ ចំនួនភ្ញៀវទេសចរណ៍ជាមធ្យមប្រហែលជាង១០០០នាក់ និងអាចមានចំនួនច្រើនជាងសារមន្ទីរជាតិទៅទៀតក្នុងមួយថ្ងៃ នៅក្នុងពេលវិស្សមកាល ។

ដោយយោងលើតួលេខទាំងនេះ ភ្ញៀវ និងអ្នកស្រាវជ្រាវគួរតែមើលកន្លែងផ្សេងៗទៀតដែលនៅជិតទីក្រុងភ្នំពេញ ក្រៅពីសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងវាលពិឃាតបឹងជើងឯក ដូចជា ក្រាំងតាចាន់ នៅក្នុងខេត្តតាកែវជាដើម ។

ជារួមភ័ស្តុតាងជាឯកសារ ឆ្អឹង សម្លៀកបំពាក់ ខ្នោះ ប្រវ៉ាក់ ពិតជាមានសារសំខាន់ដើម្បីបញ្ជាក់ពីការសម្លាប់ និងការធ្វើទារុណកម្មមកលើប្រជាជនកម្ពុជា ។ ប្រជាជនកម្ពុជាគួរតែបន្តប្រពៃណីដ៏ល្អដែលគោរពដល់អ្នកស្លាប់ ដោយមិនធ្វើការគាស់កកាយលើផ្នូរទោះជាផ្នូរបូរាណនិងសាកសពសម័យខ្មែរក្រហមក្តី ។ ប្រជាជនគួរគិតថា អ្នកទាំងនោះជាបុព្វបុរស និងជនរងគ្រោះដែលស្លាប់ដោយអយុត្តិធម៌ទាំងនោះគួរទទួលបានការគោរព និងការពារ ។ ព្រលឹងរបស់អ្នកស្លាប់នឹងនៅមិនស្ងប់ និងថែមទាំងត្រូវទទួលការរំលោភបំពានជាលើកទី២ទៀត នៅពេលដែលយើងធ្វើឲ្យប៉ះពាល់ដល់សពរបស់គាត់ ។ ដូចនេះ ក្រសួងពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល ម្ចាស់ជំនួយ និងប្រជាជននៅតាមមូលដ្ឋានគួរជួយថែរក្សាវត្ថុតាងទាំងនោះ និងបណ្តុះបណ្តាលអ្នកជំនាញបន្ថែមទៀត ។

មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការប្រមូលឯកសារនៅសម័យខ្មែរក្រហមក្នុងបំណងលើកកម្ពស់ការចងចាំ និងយុត្តិធម៌ និងការសិក្សាស្រាវជ្រាវលម្អិតពីរបបនេះ ដើម្បីជាប្រយោជន៍ដល់សង្គមខ្មែរ និងពិភពលោក ដើម្បីកុំឲ្យកើតមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងប្រល័យពូជសាសន៍នេះកើតមានជាបន្តទៀត ។

**ហ៊ុយ សម្ភស្ស**

# ប្រព័ន្ធសុខាភិបាលដែលតម្រូវឱ្យមានឆន្ទៈ កំណែទម្រង់ច្បាស់លាស់

អស់រយៈពេលតិចជាងមួយឆ្នាំ ដែលខ្ញុំបានចូលរួមជាវេជ្ជបណ្ឌិតផ្នែកវះកាត់មហារីកនៅមន្ទីរពេទ្យសង់គ្រោល ក៏ប៉ុន្តែខ្ញុំបានរស់នៅក្នុងទីក្រុងភ្នំពេញអស់រយៈពេលបួនឆ្នាំមកហើយក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាគ្រិស្ត ។ ខ្ញុំបានចូលរួមក្នុងឯកទេសនេះអស់រយៈពេល៣០ឆ្នាំនៅប្រទេសហ្វីលីពីន ។ ខ្ញុំទទួលបានការបណ្តុះបណ្តាលផ្នែកវះកាត់នៅក្នុងមន្ទីរពេទ្យរដ្ឋាភិបាលនៅក្រុងម៉ានីឡា និងទទួលអាហារូបករណ៍វគ្គខ្លីផ្នែកវះកាត់នៅមន្ទីរពេទ្យប៉ាស៊ីហ្វិកព្រីបាយស្ទើរៀននៅទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ នៃរដ្ឋកាលីហ្វ័រញ៉ាសហរដ្ឋអាមេរិក ។ ***នៅក្នុងអំឡុងពេលប្រតិបត្តិរបស់ខ្ញុំនៅទីក្រុងភ្នំពេញ ខាងក្រោមនេះ ជាការអង្កេតដែលទាក់ទងនឹងប្រព័ន្ធសុខាភិបាលដែលគួរឲ្យសោកសង្រេងនៅក្នុងប្រទេសកម្ពុជា ៖***

◆ មិនមាននូវបទដ្ឋានវេជ្ជសាស្ត្រ ដែលប្រកបដោយគុណភាពសម្រាប់បុគ្គលិកប្រតិបត្តិវេជ្ជសាស្ត្រទាំងអស់ (វេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកា)

◆ កាលវិភាគវេជ្ជសាស្ត្រ និងថៃទាំវេជ្ជសាស្ត្រ មិនមានលក្ខណៈសមស្របទៅនឹងបទដ្ឋានអន្តរជាតិ

◆ មិនមាននូវកម្មវិធីចុះកម្មសិក្សា សម្រាប់និស្សិតផ្នែកវេជ្ជសាស្ត្រប្រតិបត្តិជំនាញវេជ្ជសាស្ត្រ

◆ ឥរិយាបថផ្តាច់ការលើការគ្រប់គ្រងសម្ភារ និងបុគ្គលិកវេជ្ជសាស្ត្រភាគច្រើនខ្វះសេចក្តីមេត្តាករុណា

◆ ជំនឿតាមបែបសាសនា និងអបិយជំនឿ ដោយពុំមានមូលដ្ឋានវិទ្យាសាស្ត្រ ឬសូម្បីមូលដ្ឋានវេជ្ជសាស្ត្រ ដែលបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់ការសម្រេចចិត្តវេជ្ជសាស្ត្រ ឬការវះកាត់ភាគច្រើន

◆ កង្វះខាតការស្រាវជ្រាវលើបញ្ហាវេជ្ជសាស្ត្រ និងបញ្ហាដែលប៉ះពាល់ដល់សហគមន៍

◆ កង្វះខាតមជ្ឈមណ្ឌលបណ្តុះបណ្តាល ឬ កម្មវិធីបណ្តុះបណ្តាលលើឯកទេសចាំបាច់មួយចំនួន (មានតែអ្នកឯកទេសផ្នែកបេះដូងម្នាក់ និងអ្នកឯកទេសផ្នែកតម្រងនោមម្នាក់ នៅក្នុងទីក្រុងភ្នំពេញទាំងមូល)

◆ កង្វះអង្គភាពគ្រប់គ្រង ដែលកំណត់សមត្ថភាព (អ្នកចេញអាជ្ញាប័ណ្ណ) និងចេញជាច្បាប់កំណត់ អាកប្បកិរិយារបស់បុគ្គលិកវេជ្ជសាស្ត្រ

◆ មន្ទីរពេទ្យរដ្ឋាភិបាល ដែលគួរតែផ្តល់នូវការព្យាបាលវេជ្ជសាស្ត្រ និងការវះកាត់ប្រសើរបំផុត ស្ថិតនៅក្នុងស្ថានភាពយ៉ាប់យ៉ឺន ដោយសារតែសមត្ថភាពរបស់បុគ្គលិក និង

◆ កង្វះសមត្ថភាពក្នុងការគ្រប់គ្រងលើករណីបន្ទាន់វេជ្ជសាស្ត្រ និងការវះកាត់ នៅក្នុងមន្ទីរពេទ្យផ្សេងៗគ្នា

◆ កង្វះអង្គភាពគ្រប់គ្រងក្នុងការចាត់ថ្នាក់រវាងគ្លីនិក និងមន្ទីរពេទ្យ លើផ្នែកបរិក្ខា និងសមត្ថភាពក្នុងការគ្រប់គ្រងលើករណីវេជ្ជសាស្ត្រ និងការវះកាត់ ។

**អនុសាសន៍**

◆ អភិវឌ្ឍកាលវិភាគវេជ្ជសាស្ត្រ និងថៃទាំវេជ្ជសាស្ត្រឲ្យស្របនឹងបទដ្ឋានអន្តរជាតិ

◆ បង្កើតនូវអង្គភាពគ្រប់គ្រង (គណៈកម្មការត្រួតពិនិត្យវិជ្ជាជីវៈ) ដែលកំណត់សមត្ថភាព និងជំនាញរបស់និស្សិតផ្នែកវេជ្ជសាស្ត្រដែលទើបបញ្ចប់ការសិក្សាពីសាលាវេជ្ជសាស្ត្រ (ការប្រលងយកអាជ្ញាប័ណ្ណ) និងចេញច្បាប់លើអាកប្បកិរិយា និងសមត្ថភាពនៃបុគ្គលិកវេជ្ជសាស្ត្រ និងថៃទាំវេជ្ជសាស្ត្រ

◆ បង្កើតអង្គភាពគ្រប់គ្រង ដែលនឹងចាត់ថ្នាក់បរិក្ខាថៃទាំសុខភាពជា បឋម បន្ទាប់ និងតាមតំបន់ ដោយផ្អែកលើសមត្ថភាព និងបរិក្ខាក្នុងការគ្រប់គ្រងអ្នកជំងឺ និងដាក់កម្រិតលើមន្ទីរពេទ្យទាំងនោះក្នុងការទទួលយកអ្នកជំងឺ ដោយផ្អែកលើការចាត់ថ្នាក់របស់ខ្លួន

◆ ផ្តល់ឲ្យនិស្សិត បុគ្គលិកវេជ្ជសាស្ត្រ និងថែទាំវេជ្ជសាស្ត្រ នូវការបណ្តុះបណ្តាលនៅបរទេស ដូចជា សហរដ្ឋអាមេរិក លើឯកទេសវេជ្ជសាស្ត្រ និងការវះកាត់ ដោយអមជាមួយនឹងការព្រមព្រៀងដែលថា បន្ទាប់ពីការបណ្តុះបណ្តាលអ្នកទាំងនេះនឹងត្រឡប់មកប្រទេសកម្ពុជា ដើម្បីបណ្តុះបណ្តាលនិស្សិត និងបុគ្គលិកវេជ្ជសាស្ត្រ និងថែទាំវេជ្ជសាស្ត្រដទៃទៀត

◆ បង្កើតកម្មវិធីអន្តេវាសិកដ្ឋានសម្រាប់មន្ទីរពេទ្យតំបន់លើឯកទេសវេជ្ជសាស្ត្រ និងការវះកាត់ផ្សេងៗ

◆ បង្កើតបណ្តាញសេវាកម្មវេជ្ជសាស្ត្របន្ទាន់មួយរវាងមន្ទីរពេទ្យ

◆ បង្កើតបរិក្ខាវេជ្ជសាស្ត្រ និងមន្ទីរពេទ្យដែលមានឯកទេសលើលក្ខខណ្ឌវេជ្ជសាស្ត្រ និងការវះកាត់ជាក់លាក់ណាមួយជាឧទាហរណ៍ មន្ទីរពេទ្យឆ្អឹង មណ្ឌលសុខភាព មន្ទីរពេទ្យមហារីក មន្ទីរពេទ្យដែលគ្រប់គ្រងលើផ្នែកសតិអារម្មណ៍ជាដើម ។

ស្របជាមួយក្តីសង្ឃឹម និងការបែរបន់ឲ្យមានការផ្លាស់ប្តូរប្រព័ន្ធសុខាភិបាលក្នុងពេលឆាប់ៗ ខ្ញុំក៏ដឹងដែរថា វាទាមទារឲ្យមានឆន្ទៈនយោបាយយ៉ាងខ្លាំងក្នុងការកែប្រែប្រព័ន្ធនេះ ព្រោះបញ្ហានេះ បានចាក់ឫសយ៉ាងជ្រៅ លើបុគ្គលិកប្រតិបត្តិវេជ្ជសាស្ត្រ និងថែទាំវេជ្ជសាស្ត្រជាច្រើន ។

**វេជ្ជបណ្ឌិត ឌេម៉ូស្ទិន ស៊ី.អេយើស**



ក្រុមគ្រូពេទ្យវះកាត់របស់ខ្មែរក្រហម កំពុងធ្វើការវះកាត់អ្នកជំងឺ ។ គ្រូពេទ្យក្មេងៗរបស់ខ្មែរក្រហមមួយចំនួនមិនបានរៀនសូត្រផ្នែកវេជ្ជសាស្ត្រនៅសាលាពេទ្យទេ

# ខ្សែជីវិតរបស់លោកយាយខ្ញុំក្នុងសម័យប៉ុល ពត

លោកយាយរបស់ខ្ញុំឈ្មោះ ថែម យ៉ៃ បច្ចុប្បន្នគាត់មានអាយុ៦៩ឆ្នាំ កើតនៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ ខេត្តបាត់ដំបង (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) ។ គាត់មានឪពុកឈ្មោះ ថែម យុន (ស្លាប់) និងម្តាយឈ្មោះ ឡោក យុក (ស្លាប់) ។ លោកយាយខ្ញុំមានបងប្អូនបួននាក់ (ប្រុស២ ស្រី២) គាត់ជាកូនស្រីទី២ ក្នុងគ្រួសារ ។ ក្នុងឆ្នាំ១៩៧០ តាទួតរបស់ខ្ញុំជាអ្នកចម្ការ រីឯយាយទួតខ្ញុំជាអាជីវករលក់ដូរបន្តិចបន្តួច ក្នុងផ្សារដើម្បីចិញ្ចឹមកូនបួននាក់ ។ មួយឆ្នាំក្រោយមក ក្នុងខែកញ្ញា លោកយាយខ្ញុំបានរៀបការជាមួយលោកតាខ្ញុំឈ្មោះ ជ័យ សាមឿន (ស្លាប់) កើតឆ្នាំ១៩៤៥ មានទីកំណើតនៅខេត្តកំពង់ស្ពឺ តែគាត់បានប្តូរទីលំនៅទៅស្រុកសិរីសោភ័ណ ខេត្តបាត់ដំបង ក្នុងឆ្នាំ១៩៦០ ។ ក្រោយពីរៀបការបានពីរខែ លោកតារបស់ខ្ញុំបានប្រលងជាប់ជាមន្ត្រីរដ្ឋបាលបម្រើការក្នុងបន្ទាយទាហាននៅអូរបែកក្អម នាទីក្រុងភ្នំពេញ ហើយក៏តម្រូវឲ្យលោកយាយខ្ញុំសម្រេចចិត្តចាកចេញពីស្រុកកំណើតទៅតាមប្តីនៅទីក្រុងភ្នំពេញ ។ ឆ្នាំ១៩៧២ ខែមិថុនា លោកយាយខ្ញុំសម្រាលបានកូនស្រីមួយ ហើយគាត់គឺជាម្តាយរបស់ខ្ញុំ ។ លោកតាខ្ញុំស្រឡាញ់ប្រពន្ធកូនណាស់ មិនដែលឲ្យលោកយាយខ្ញុំស្គាល់ទុក្ខលំបាកទេ ចាប់តាំងពីគាត់បានរៀបការជាមួយ ។ ថ្ងៃ១៧ មេសា ១៩៧៥ បន្ទាប់ពីទ័ពខ្មែរក្រហមបានយកឈ្នះលើទ័ព លន់ នល់ ខ្មែរក្រហមបានចូលដល់ទីក្រុងភ្នំពេញហើយប្រកាសប្រាប់ដល់ប្រជាជនទាំងអស់ឲ្យនាំគ្នាភៀសខ្លួនចេញពីក្រុងពីរបីថ្ងៃសិន ព្រោះថាអាមេរិកនឹងទម្លាក់គ្រាប់បែកកម្ទេចទីក្រុង ។ ខ្មែរក្រហមបានបន្ថែមទៀតថា មិនចាំបាច់យកអីវ៉ាន់ទៅតាមខ្លួនច្រើនពេកទេ ព្រោះថាទៅមិនយូរគង់តែមកវិញ រីឯសោផ្ទះក៏ពុំចាំបាច់ចាក់សោដែរ ។ ដោយយល់សភាពការណ៍ពុំសូវស្រួលជីតាខ្ញុំក៏ប្រញាប់ប្រញាល់រត់ទៅផ្ទះរកប្រពន្ធកូន ពេលនោះគាត់បានប្រទះឃើញសាកសពទាហាន លន់ នល់ ជាច្រើននាក់ត្រូវបានសម្លាប់ ។ លុះមកដល់ផ្ទះ មិនបង្អង់យូរលោកតាខ្ញុំបានប្រមូលខោអាវយោធាដុតចោលទាំងអស់ ហើយផ្លាស់សម្លៀកបំពាក់ស៊ីវិលវិញ ដើម្បីកុំឲ្យទាហានខ្មែរក្រហមដឹងពីសាវតាគាត់ ។ លោកតាខ្ញុំបង្គាប់ឲ្យលោកយាយខ្ញុំរៀបអាហារក្រៀមៗ និងមាសប្រាក់បន្តិចបន្តួចដែលបានសន្សំរួចប្រញាប់ចាកចេញ ។ គ្រានោះលោកយាយខ្ញុំបីម្តាយខ្ញុំ ឯលោកតាខ្ញុំកាន់ស្ពាយអីវ៉ាន់ធ្វើដំណើរទៅតាមការជម្លៀសរបស់ទ័ពខ្មែរក្រហម ។ គាត់ឃើញសាកសពទាហាន និងប្រជាជនរាប់រយនាក់នៅតាមចិញ្ចើមផ្លូវ កូនក្មេងយំទ្រហឹងអឺងកង ព្រោះវង្វេងម្តាយឪពុក រទេះ រ៉ឺម៉ក និងស៊ីក្លូពាសពេញផ្លូវ គ្រប់គ្នាពោរពេញដោយភាពតក់ស្លុត និងភ័យខ្លាច ។


ជីតារបស់ខ្ញុំ ជ័យ សាមឿន

លោកតា លោកយាយខ្ញុំ ត្រូវបានខ្មែរក្រហមជម្លៀសទៅដល់ខេត្តកំពង់ធំ ក្នុងខែមិថុនា ឆ្នាំ១៩៧៥ ក្នុងឃុំមួយឈ្មោះឃុំក្រយៀ ដងក្តារ បន្ទាប់មក ខ្មែរក្រហមក៏ចាប់ផ្តើមសង់ខ្ទមធ្វើអំពីកូនឈើតូចៗ ប្រក់ស្បូវឲ្យគាត់ទាំងអស់គ្នារស់នៅ ប៉ុន្តែគាត់ទាំងពីរត្រូវធ្វើការផ្សេងគ្នា រីឯកូនតូចត្រូវយកទៅឲ្យយាយៗមើល ។ លោកតាខ្ញុំត្រូវអង្គការបញ្ជូនឲ្យទៅធ្វើការនៅកន្លែងផ្សេងក្រៅសហករណ៍

ខ្លួន បួនដប់ថ្ងៃទើបបានមកផ្ទះម្តង ។ ចំណែកលោកយាយខ្ញុំមិនត្រូវបានបញ្ជូនឲ្យទៅធ្វើការក្រៅសហករណ៍ទេ គឺធ្វើការនៅជិតៗខ្ទមឬក្នុងតំបន់ក្បែរៗនោះ ។ ជារៀងរាល់ថ្ងៃ លោកយាយ ខ្ញុំក្រោកពីព្រហាមម៉ោងបួន និងធ្វើការពីដប់ទៅដប់ពីរម៉ោង ហើយគាត់ទទួលបានអាហារត្រឹមតែពីរពេលប៉ុណ្ណោះក្នុងមួយថ្ងៃ ។ កន្លងបានប្រមាណជាបួនខែជីតាខ្ញុំកើតជំងឺគ្រុនចាញ់ព្រោះកន្លែងដែលគាត់ធ្វើការជាតំបន់ព្រៃភ្នំ ។

បន្ទាប់មក គាត់ត្រូវបានអង្គការបញ្ជូនឲ្យទៅសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យតាំងក្រសាំង ។ លុះយប់ដដែលនោះសមមិត្ត សារី ដែលជាអ្នករស់នៅក្នុងសហករណ៍ជាមួយ បានមកប្រាប់លោកតាខ្ញុំថាលោកយាយខ្ញុំកំពុងឆ្លងទន្លេនៅឯខ្ទម ។ ដោយក្តីបារម្ភលោកតាខ្ញុំ បានចុះពីលើគ្រែទាំងជំងឺដើម្បីទៅមើលប្រពន្ធទាំងកណ្តាលអាធ្រាតម៉ោងមួយយប់ ។ លុះស្អែកឡើងមិនឃើញគាត់នៅមន្ទីរពេទ្យ អង្គការក៏ចាត់គ្នាឲ្យមករកគាត់នៅខ្ទម ហើយក៏បានជួបលោកតា ខ្ញុំនៅក្នុងខ្ទមមែន ។ លោកតាខ្ញុំត្រូវបានអង្គការបញ្ជូនឲ្យទៅធ្វើការនៅកន្លែងនោះជាថ្មីម្តងទៀតពីព្រោះអង្គការសន្មតថា គាត់បានជាពីជំងឺហើយទើបអាចត្រឡប់មកខ្ទមបានដូច្នេះ ។ បានត្រឹមតែពីរថ្ងៃជំងឺលោកតាខ្ញុំកាន់តែធ្ងន់ធ្ងរឡើងៗ ធ្វើឲ្យគាត់ដួលសន្លប់នៅនឹងកន្លែងធ្វើការនោះតែម្តង ។

អង្គការបានឲ្យលោកតា សារី ដែលជាអ្នកធ្វើការជាមួយលោកតាខ្ញុំបររទេសគោដឹកគាត់ទៅមន្ទីរពេទ្យ ។ ជាអកុសលលោកតាខ្ញុំត្រូវបានទទួលអនិច្ចកម្មនៅពាក់កណ្តាលផ្លូវទៅកាន់មន្ទីរពេទ្យ ។ ក្រោយពីបានទទួលដំណឹងនេះ ហើយធ្វើឲ្យលោកយាយខ្ញុំមានការឈឺចាប់ជាខ្លាំងតែគាត់ខំខាំមាត់សង្កត់ចិត្តមិនហ៊ានយំសោកបោកខ្លួនទេ ព្រោះអង្គការហាមមិនឲ្យបញ្ចេញទុក្ខសោក ភាពសប្បាយរីករាយឡើយ បើពុំនោះទេនឹងត្រូវយកទៅរៀនសូត្រ ។ ក្រោយពីការការដួលរលំនៅថ្ងៃ ៧មករា ឆ្នាំ១៩៧៩ ពូខ្ញុំដែលកើតក្នុងសម័យនោះក៏បានទទួលមរណៈភាពម្នាក់ទៀត ដោយសារជំងឺបន្សល់ទុកនូវស្លាកស្នាមដ៏ឈឺចាប់សម្រាប់លោកយាយខ្ញុំដែលជាស្ត្រីមេម៉ាយរហូតមកដល់បច្ចុប្បន្ន ។ **សុខ ជីវ័ន្ត**



ពីធីរៀបការរវាងជីតារបស់ខ្ញុំ ជ័យ សាមឿន និងយាយរបស់ខ្ញុំ ចែម យ៉ៃ

# មានទោសព្រោះអ្វី?

## ប្រវត្តិជីវិតខ្ញុំក្នុងសម័យប៉ុល ពត

*អក្សរាអ្នកនិពន្ធជាច្រើនបានសរសេរថា "ក្រោយភ្លៀងរលឹមមេឃនឹងស្រឡះល្អ" ។ តែចំពោះមាតុភូមិដ៏កំសត់ក្រីក្រខ្មែរយើងនេះ ក្រោយសង្គ្រាមឆ្នាំ១៩៧៥ គឺបន្សល់តែភាពវិនាសខ្ទេចខ្ទាំគ្រប់យ៉ាង ផ្ទះសម្បែង សាលារៀន អាគារសាធារណៈ ស្ទើរក្លាយជាផេះធូលី ។ ភាពទុក្ខសោកនិរាសព្រាត់ប្រាស បងព្រាត់ប្អូន កូនព្រាត់ម្តាយ ប្រពន្ធព្រាត់ប្តី គឺបានដក់ជាប់ក្នុងដួងចិត្តប្រជាជនខ្មែរស្ទើរគ្រប់រូប ។ រណ្តៅសាកសព គំនរឆ្អឹងមានស្ទើរពាសពេញប្រទេស ទាំងនេះគឺជាសោកនាដកម្មនៃសង្គ្រាម ។*

*ភាពខ្លោចផ្សា ទាំងនេះមិនមែនមានត្រឹមតែមនុស្សចាស់ យុវជន នារី ឬកុមារនោះទេ សូម្បីតែទារកដែលទើបនឹងឃើញពន្លឺព្រះអាទិត្យបានត្រឹមតែមួយនាទី ក៏ត្រូវទទួលរងនូវទារុណកម្មខាងលើនេះដែរ ។*

*នៅថ្ងៃ១៧ មេសា ១៩៧៥ ខ្មែរក្រហមបានវាយលុកចូលកាន់កាប់ក្រុងភ្នំពេញបានជាស្ថាពរ ។ អ្នកទីក្រុងនាំគ្នាសម្តែងការអបអរ និងសង្ឃឹមជឿជាក់ថា នឹងបានលទ្ធិមួយដែលគ្មានការជិះជាន់ គ្មានអំពើពុករលួយ ហើយប្រជាជននឹងមានសុភមង្គលយ៉ាងត្រចះត្រចង់ ។ ជាពិសេស គឺបានរួចចាកផុត ពីសង្គ្រាមដ៏សែនខ្លោចផ្សាដែលឈាមយុទ្ធជនខ្មែរ យុវជនខ្មែរហូរស្រោចផែនដីជារៀងរាល់ថ្ងៃ ដោយសារតែអ្នកដឹកនាំពីរនាក់ដែលមាននយោបាយ និន្នាការមនោគមន៍វិជ្ជាខុសគ្នា បានដឹកនាំខ្មែរឲ្យច្បាំងនឹងខ្មែរគ្នាឯង ដើម្បីបំពេញមហិច្ឆតាដណ្តើមភាពខ្លាំង ភាពធ្វើម្ចាស់ និងភាពជាអ្នកដឹកនាំរៀងៗខ្លួន ។*

*តែក្តីសង្ឃឹម ស្នាមញញឹមដែលផុសចេញពីដួងចិត្តដ៏បរិសុទ្ធស្មោះស្ម័គ្ររបស់អ្នកទីក្រុង មិនទាន់ទាំងរលុបបាត់ផង ស្រាប់តែបញ្ជាមួយរបស់ប៉ុល ពត ឲ្យអ្នកទាំងនោះចាកចេញពីទីក្រុងទៅរស់នៅតាមជនបទ ។ សោកនាដកម្មដ៏ជូរចត់ដែលអ្នកទីក្រុងសង្ឃឹមថាវាបានរលត់ទៅតាមផ្សែងសង្គ្រាមទៅហើយនោះ ក៏បានវិលត្រឡប់មកផ្លាស់ប្តូរពីស្នាមញញឹមមកជាទុក្ខក្រៀមក្រំពីសើចសប្បាយរីករាយ ជំនួសដោយទឹកភ្នែកភ្លាមៗដែរ ។*

*ខ្ញុំជាយុវជន ហើយក៏ជាសិស្សរៀននៅវិទ្យាល័យច្បារអំពៅដែលបានស្នាក់អាស្រ័យជាមួយលោកពូ អ្នកមីងនៅម្តុំពេទ្យរុស្ស៊ី ក៏បានចាកចេញពីលំនៅដ្ឋានមកដើរប្រសេកប្រសាចជាមួយហ្វូងមនុស្សរាប់សែននាក់ ។ ទិដ្ឋភាពដ៏ខ្លោចផ្សាក៏កើតមានឡើងនៅចំពោះមុខខ្ញុំ អ្នកជំងឺនៅក្នុងមន្ទីរពេទ្យក៏ត្រូវបង្ខំអោយចាកចេញដែរ អ្នកខ្លះដើរទ្រេតទ្រោតម្នាក់ឯង គ្មានបងប្អូនជួយគ្រាហ៍ ចំណែកអ្នកខ្លះត្រូវដាច់ខ្យល់ស្លាប់ភ្លាមៗ នៅតាមចិញ្ចើមថ្នល់ក្រោមម្លប់ឈើ ។ សម្រែកទុក្ខសោកសង្រេង ខ្លះព្រាត់ម្តាយ ព្រាត់ប្តី ព្រាត់កូន កំពុងតែទួញយំដង្ហើយហៅរកគ្នាទ្រហឹងអឺងអាប់ ។ ចំណែកខ្លួនខ្ញុំក៏ត្រូវព្រាត់ពីសួនបុប្ផាដែលកំពុងតែរីកស្គុសស្គាយ ហើយជាទីស្រឡាញ់បំផុតសម្រាប់រូបខ្ញុំនោះ គឺវិទ្យាល័យដែលជាឃ្លាំងចំណេះសព្វមុខវិជ្ជា ហើយជាមាគ៌ាដ៏ល្អប្រពៃរបស់យុវជនគ្រប់រូបនៅពេលអនាគត ។*

*ខ្ញុំចេះតែសួរខ្លួនឯងថា តើអនាគតដ៏ត្រចះត្រចង់ដែលខ្ញុំសង្ឃឹមថាបាននោះ នឹងត្រូវបញ្ចប់ត្រឹម ឬយ៉ាងណា? នៅពេលថ្ងៃត្រង់គ្រួសារខ្ញុំបានដើរមកដល់រោងចក្រកែវ នៅទីនេះខ្ញុំឃើញយោធាខ្មែរក្រហមចាប់ចងយុទ្ធជនសាធារណរដ្ឋបណ្តើរទាំងខ្សែៗ មិនដឹងថាយកទៅណាមកណាឡើយទេ ហើយក្នុងចំណោមយុទ្ធជនចាញ់សង្គ្រាមទាំងនោះ ខ្ញុំស្គាល់ច្បាស់ជាងគេគឺ ណុប ណែម គាត់ស្លៀកខោជើងវែងពណ៌ផ្ទៃមេឃ និងអាវយឺតដៃវែងពណ៌ផ្កាឈូកព្រឿងៗ មានក្រឡាតូចៗ ស្ពាយបង្វេចតូចមួយនៅក្រោយខ្នង គាត់ដើរយ៉ាងស្ងៀមស្ងាត់ជាមួយហ្វូងយុទ្ធជនឈ្លើយសង្គ្រាមនោះដែរ ។ ភ្នែកគាត់ខំរំពៃរកហ្វូងមនុស្សដែលណែនណាន់តាន់តាប់ ក្រែងឃើញបងប្អូន ឬប្រពន្ធកូនរបស់គាត់ ។*

*កំពុងតែរន្ធត់ចិត្តនឹងហេតុការណ៍ដ៏ព្រឺព្រួចទាំងនេះ ស្រាប់តែមានអ្នកទាញស្មាខ្ញុំឲ្យឈប់ ហើយបញ្ជាថា៖*

*- ឈប់ មិត្តឯងឈប់សិន!*

ខ្ញុំនាំកមករកម្ចាស់សំឡេងបញ្ជា ខ្ញុំភ្ញាក់ព្រើត ព្រោះឃើញទាហានអាវខ្មៅពីរនាក់កំពុងតែឃាត់ខ្ញុំ អ្នកទាំងពីរស្លៀកខោខ្មៅជើងវែងមូរជើងឡើងត្រឹមជង្គង់ ស្បែកជើងកង់ឡាន និងប្រដាប់ដោយកាំភ្លើងអាកាគ្រប់គ្នា ។

- មានការអ្វីដែរបង?

- មិត្តឯងជាទាហានឬ?

- ខ្ញុំ ខ្ញុំជាកូនសិស្សទេបង

- បើកូនសិស្ស ម៉េចក៏មានសំពៀតទាហានស្ពាយជាប់ខ្លួនអីចឹង?

ខ្ញុំនឹកឃើញកូនសាក់កាដូរបស់ទាហានដែលខ្ញុំដាក់សុទ្ធតែសៀវភៅរៀន ស្ពាយនៅចំហៀងខ្លួនខ្ញុំនេះ ។

- បាទ នេះជាកាតាបខ្ញុំដាក់សៀវភៅរៀនទេបង

អ្នកទាំងពីរក៏ឆែកឆេរខ្ញុំ ហើយរលាក់សៀវភៅខ្ញុំចេញពីកាតាបទម្លាក់ចោលលើចិញ្ចើមថ្នល់ និងរើសកាតសិស្សរបស់ខ្ញុំមកពិនិត្យមើល ហើយនិយាយថាៈ

- នៅទីនេះគ្មានវិទ្យាល័យទៀតទេ គឺមានតែវាលស្រែ និងដីចម្ការ ហើយក៏គ្មានសញ្ញាបត្រអីដែរ មានតែសញ្ញាឃើញនៅតាមការដ្ឋានតែប៉ុណ្ណោះ មិត្តឯងមិនបាច់ស្ពាយនាំតែធ្ងន់ទេ ។

ថាហើយអ្នកទាំងពីរក៏យកជើងឈូសសៀវភៅខ្ញុំទម្លាក់ទៅក្នុងស្រែហើយសំពៀតទាហាននោះក៏យកចេញទៅ ។ នៅពេលព្រលប់ទើបខ្ញុំមកដល់មាត់ស្ទឹងគូរ ខ្ញុំ មីងខ្ញុំ ព្រមទាំងកូនគាត់តូចៗបីនាក់ ទៀតក៏បានឈប់សម្រាកនៅមាត់ស្ទឹងនេះមួយយប់ ។

យប់នេះ សម្រែកសោកសង្រេងលាន់ឮស្ទើរគ្រប់ទិកន្លែង មនុស្សចាស់ និងកូនក្មេងដែលមានជំងឺជាប់ខ្លួនផងនោះ ក៏បានស្លាប់ជាបន្តបន្ទាប់ ព្រោះត្រូវកំដៅថ្ងៃខែចែត្រពេញមួយថ្ងៃមកហើយ ។ គ្រួសារជនរងគ្រោះខ្លះយកកាំបិត ខ្លះយកឈើជីកកាយដីមាត់ស្ទឹងកប់សាកសព ហើយសាកសពខ្លះក៏ត្រូវទុកចោលនៅក្រោមដើមសង្កែទីនោះទៅ ។

ព្រឹកព្រាងថ្ងៃរះឡើង អ្នកជម្លៀសចេញពីទីក្រុង និងគ្រួសារខ្ញុំត្រូវអង្គការបន្ទឹងឲ្យចេញដំណើរទៅមុខទៀត ។ នៅតាមផ្លូវចាប់ពីស្ទឹងគូរនេះទៅ ខ្ញុំឃើញសាកសពយុទ្ធជនសាធារណរដ្ឋដេកស្លាប់រណូករណែលពាសពេញវាលស្រែគួរឲ្យអាណោចអាធ័មក្រៃលែង ព្រោះអ្នកដែលដេកស្លាប់ទាំងនោះ គឺសុទ្ធសឹងជាជនជាតិខ្មែរ ។ ខ្ញុំសង្វេគអ្នកដែលដេកស្លាប់ទាំងនោះណាស់ ព្រោះអ្នកទាំងនោះលែងស្រែកទាមទារតវ៉ាអ្វីទាំងអស់ ទោះសម្រាប់រូបខ្លួន ភរិយា បងប្អូន កូនក្មួយក៏ដោយ ។ គឺលែងត្រូវការអ្វីទាំងអស់ ហើយដេកស្លាប់ក្រោមកំដៅថ្ងៃយ៉ាងសុខសាន្ត ។ តែឈាមរបស់អ្នកទាំងអស់ដែលហូរក្រាលដែនដីនេះហាក់ដូចជាស្រែកផ្តាំដល់ជនជាតិខ្មែរទាំងអស់ថា កុំច្បាំងសម្លាប់ខ្មែរគ្នាឯងទៅទៀតអី កុំធ្វើសង្គ្រាម ដែលគេកំពុងបង្ខំឲ្យយើងធ្វើទាំងខ្លួនយើងមិនចង់ធ្វើនោះ ។ អ្នកស្លាប់បាត់បង់ទៅហើយដោយសារសង្គ្រាម ។ តែអ្នកក្តី ខ្ញុំក្តី មិនបានស្រឡាញ់សង្គ្រាមនេះឡើយ ។

ម្តាយមីងនាំខ្ញុំ និងប្អូនតូចៗទាំង៣នាក់ ដើរក្រោមកំដៅថ្ងៃដ៏ហួតហែងចំនួនពីរយប់បីថ្ងៃទៀត ទើបមកដល់ទីប្រជុំជនចំបក់ នៅតាមផ្លូវនេះ ភាពសោកសៅក៏នៅតែមានហូរហែរហូត នៅពេលប្អូនៗស្រេកទឹក ខ្ញុំមិនអាចទៅរកទឹកឯណាឲ្យបានស្អាតល្អនោះទេ ព្រោះនៅទីណាក៏មានសាកសពអណ្តែតលើផ្ទៃទឹក គ្រាន់តែខ្លះតិច ខ្លះច្រើនតែប៉ុណ្ណោះ ចំណែកអណ្តូងទឹកដែលនៅក្នុងភូមិស្ថានបាក់បែកស្ងាត់ជ្រងំ គ្មានមនុស្សរស់នៅ ក៏មានសាកសពនៅក្នុងនោះដែរ ខ្ញុំដងទឹកតាមថ្លុកត្រពាំងតូចៗដែលគ្មានសាកសព យកមកដាំចម្អិន ទោះបីជាទឹកនោះមានសភាពល្អក់កករយ៉ាងណាក៏ដោយ ក៏ស៊ូទ្រាំផឹកបំបាត់ការស្រេកឃ្លាន ។ ខ្ញុំសម្រាកនៅចំបក់មួយយប់ ហើយនៅទីនោះគេរៀបចំធ្វើពិធីបុណ្យមួយ តែមិនដឹងជាបុណ្យអ្វីទេ ខ្ញុំឃើញតែដោតបដាពណ៌ក្រហមគ្រប់កន្លែង និងសម្រែកជ័យឃោសថា "ជយោ!បដិវត្តន៍" "បរាជ័យពួកអាចក្រពត្តិ" ខ្ញុំគិតថា តើអ្នកណាជាបដិវត្តន៍? ហើយអ្នកណាជាពួកចក្រពត្តិ? បើពលរដ្ឋនៅខាងនេះក៏ជាខ្មែរ ចំណែកអ្នកនៅភ្នំពេញក៏ជាខ្មែរ ហើយជាពលរដ្ឋសាមញ្ញដែលរស់នៅក្នុងសង្គ្រាមដូចតែគ្នាហ្នឹង ។

ស្អែកឡើង នៅពេលរសៀលទើបខ្ញុំមកដល់ភូមិត្នោតដែលជាស្រុកកំណើតរបស់ម្តាយមីងខ្ញុំ នៅទីនេះ ខ្ញុំហាក់ដូចជាធូរស្រាលបន្តិច ព្រោះម្តាយមីងខ្ញុំគាត់បានជួបជុំបងប្អូនរបស់គាត់ ហើយក៏មានផ្ទះសម្បែង បាយទឹកសម្រាកស្រួលបួលជាងនៅតាមផ្លូវ ។ ស្អែកឡើង ខ្ញុំសុំលាម្តាយមីងត្រឡប់ទៅស្រុកកំណើតខ្ញុំវិញម្តងដែលនៅឯឃុំស្វង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

មកតាមផ្លូវខ្ញុំមានកងមួយជិះតែម្នាក់ឯង លាយឡំនឹងហ្វូងមនុស្សជាច្រើននាក់ទៀតដែលកំពុងធ្វើដំណើរវិលត្រឡប់សំដៅទៅស្រុកកំណើតរបស់ខ្លួន ។ តាមផ្លូវនេះ មនុស្សមិនសូវមានច្រើនប៉ុន្មានទេ ។ នៅលើរនាកងខាងក្រោយ ខ្ញុំមានបង្វេចតូចមួយដែលមានខោអាវពីរសម្រាប់ ក្រមាដែលម្ដាយមីងខ្ញុំឲ្យមួយ អង្ករ ឆ្នាំងបាយ ត្រីប្រឡាក់គ្រឿម ១ ដែលគាត់រៀបចំឲ្យមុនចេញដំណើរ ។ ខ្ញុំជិះកងរហូតថ្ងៃត្រង់ទើបខ្ញុំឈប់ដាំបាយហូបនៅក្រោមម្លប់ត្នោត ពេលបាយឆ្អិនខ្ញុំក៏ចាប់រៀបចំបរិភោគ តែខ្ញុំក្រឡេកទៅម្លប់ដើមសង្កែឃើញយុវជនម្នាក់ដែលមានអាយុប្រហែលនឹងខ្ញុំដែរ ដេកស្ងួតស្ងឹងកើយបង្វេចតូចមួយ បន្តិចក្រោយមកក៏ក្រោកអង្គុយ ដែលមានទឹកមុខក្រៀមក្រំ និងហត់ហេវ ខ្ញុំស្រែកហៅ ព្រមទាំង បកដៃឲ្យគាត់ដើរមករកខ្ញុំ ។

- ឯងហូបបាយជាមួយខ្ញុំទេ? គាត់ដូចជារីករាយនឹងសំណួររបស់ខ្ញុំ

- បាទ អរគុណ តែបាយឯងដូចជាតិចណាស់

- បន្តិចបន្តួចយើងចែកគ្នាហូបសិនទៅចាំដល់ពេលល្ងាចចាំយើងដាំឲ្យច្រើនជាងនេះ ព្រោះខ្ញុំមានអង្ករច្រើនគួរសមដែរ ។

ពេលហូបបាយរួចហើយខ្ញុំក៏សាកសួរគ្នាទៅវិញទៅមក ខ្ញុំសួរគាត់មុនៈ

- ឯងគិតធ្វើដំណើរទៅណាទៀត? ហើយឪពុកម្ដាយឯងនៅឯណា? ហើយមានបងប្អូននៅទីនោះទេ?

- គឺគ្នាមិនដឹងទេ ព្រោះគ្នារស់នៅភ្នំពេញតាំងពីនៅតូច ១ ហើយប៉ាគ្នាគាត់បានស្លាប់ក្នុងសមរភូមិ នៅតាំងគោកយូរណាស់មកហើយ ឯម្ដាយគ្នាគាត់នៅបម្រើតាមផ្ទះម្ចាស់ផ្សារទួលទំពូង ចំណែកគ្នាស្នាក់នៅវត្ត ។

ខ្ញុំសួរបន្តទៀត

- ចុះឯងឈ្មោះអី? ហើយម្ដាយឪពុកឯងឈ្មោះអីដែរ?

- គ្នាឈ្មោះ វ៉ិន មករា តែនៅក្នុងវត្ត គេហៅ អាគ្រុយ ។

វាសួរខ្ញុំវិញម្ដង

- ចុះឯងឈ្មោះអី? ហើយមានស្រុកកំណើតនៅឯណា?

ខ្ញុំរៀបរាប់ប្រាប់វិញតាមរឿង តែខ្ញុំមិនប្រាប់ឈ្មោះកំណើតខ្ញុំទេ ខ្ញុំប្រាប់ឈ្មោះខ្ញុំនៅតាមសាលាតែប៉ុណ្ណោះ ។

- ចុះពេលនេះឯងសម្រេចចិត្តទៅទីណាដែរ?

- គ្នាមិនដឹងជាទៅទីណាទេ បើមិនដឹងថាបងប្អូនមានរស់នៅទីកន្លែងណាផងនោះ

- បើអីចឹងឯងទៅជាមួយគ្នាប្រយ៉ាងម៉េចដែរ?

- ទៅក៏ទៅគ្រាន់បានជាគ្នា ហើយគ្នាឯណេះក៏អត់មានអង្ករដាំបាយអ៊ីផង ។

នៅតាមផ្លូវយើងទាំងពីរនាក់ជជែកគ្នារហូត ។ ជិះកងឌុបគ្នាម្ដងម្នាក់ តែខ្ញុំមិនសូវបានឌុបវាទេ វាមានមាឌមាំជាងខ្ញុំ វាធានាឌុបខ្ញុំ ។ តាំងពីពេលនោះមក ខ្ញុំ និងវាបានយល់ចិត្តគ្នា ហើយបានក្លាយជាកល្យាណមិត្តដោយស្ម័យប្រវត្តិ ។ ខ្ញុំទាំងពីរនាក់មិនស្គាល់ផ្លូវទេ ចេះតែសួរគេរហូតទាល់តែឆ្លងទន្លេតូចនេះ ហើយជិះតាមផ្លូវលំរហូតនឹងទៅដល់ដីឥដ្ឋ រួចហើយបន្តទៅអ្នកលឿងឆ្លងទៅព្រៃវែងនឹងបន្តទៅ ដល់ខេត្តកំពង់ចាម ។ ខ្ញុំពីរនាក់ឆ្លងទូក ដែលមានក្មេងប្រុសម្នាក់ជាអ្នកចែវចម្លងមកដល់ត្រើយម្ខាង ខ្ញុំហុចលុយឲ្យក្មេងម្ចាស់ទូក ក្មេងនោះធ្វើភ្នែកឡឹងឡង់ហើយនិយាយថាៈ

- ស្រុកនេះគេអត់ចាយលុយទៀតទេ គឺយករបស់ជាថ្នូរជំនួសលុយ ។

ខ្ញុំគ្មានរបស់អ្វីសំខាន់សម្រាប់ជាថ្នូរសោះ

- ចុះអាវមួយនេះក្មួយយកទេ?

- បាទ ខ្ញុំយក

ខ្ញុំស្រាយបង្វេច យកអាវមួយឲ្យក្មេងម្ចាស់ទូកនោះ ។ ក្រោយពីលើកកងចេញពីទូករួចស្រេចហើយ យើងក៏ចេញដំណើរបន្តទៀត

- អាការា អញឌុបឯងម្ដង!

- ទេ! មិនបាច់ អញមិនទាន់ហត់ទេ!

យើងទាំងពីរជិះកងតាមផ្លូវលំកាត់ភូមិ កាត់វាល កាត់ព្រៃរហូតដល់ពេលព្រលប់ ទើបមកដល់វត្តបាក់បែកមួយ ដែលនៅក្លោងទ្វារគេសរសេរថា “វត្តដីដុះ” នៅទីនេះមានមនុស្សម្នាឈប់សម្រាកច្រើនគួរសម យើងទាំងពីរនាក់ក៏ឈប់សម្រាកនឹងគេ តែដោយគ្មានប៉ោតសម្រាប់ដងទឹកដាំបាយ ក៏នាំគ្នាអូសកងទៅមាត់ទន្លេ ដើម្បីផ្ងូតទឹកផង និងដាំបាយផង ។

ក្រោយពេលស្រស់ស្រូបបាយពេលល្ងាចរួច ក៏នាំគ្នាមកកាន់ទីវត្តដីដុះ រកកន្លែងស្នាក់នៅមួយយប់សិន ព្រោះមេឃងងឹតខ្លាំង

ដែរហើយ ។ ខ្ញុំក្រឡេកឃើញដើមឈើមួយមានមែកសាខាក៏បបួលគ្នាដេក ព្រោះកន្លែងនោះគ្មានមនុស្សឈប់ទេ ។

- អាការា! យើងដេកក្រោមដើមឈើនោះទៅ

- អឺ! ក៏ល្អម្យ៉ាងដែរ ព្រោះមានមែកសាខាអាចការពារសន្សើមបាន ហើយគ្មានមនុស្សដេកនៅទីនោះផង

- អ៊ីចឹងអាការាឯង! រៀបចំបោសកន្លែងចាំអញទៅរកកាច់មែកឈើមកក្រាលដេក ។ ខ្ញុំកំពុងតែបោសសម្អាតកន្លែងស្រាប់តែអាការាវារត់មករកខ្ញុំទាំងព្រលឹងចុងសក់ ។

- អា...អាភា! កុំដេកនៅទីនេះអី ព្រោះនៅខាងក្រោយមានខ្មោច អញដើរជាន់អម្បាញ់មិញហ្នឹងរើយ!

- មិនមែនទេដឹង! ក្រែងគេដេកដែរទេ ។

- ច្បាស់ហើយ! ពេលអញដើរជាន់ អញស្រែកសុំទោស តែអញលូកដៃទៅបោសកន្លែង អញជាន់ ស្រាប់តែត្រជាក់ស្រឹប ហើយរឹងត្អឹងតែម្តង ។

- ចុះបើត្រឹមតែខ្មោចសោះឯងក៏ភ័យខ្លាំងម្ល៉េះអាការា?

ខ្ញុំហួសចិត្ត ព្រោះមិននឹកស្មានថា អានេះវាខ្លាចខ្មោចដល់ថ្នាក់ហ្នឹងសោះ ។ ខ្ញុំឆ្ងល់ដែកកេះមើល ឃើញខ្មោចមនុស្សស្រីអាយុប្រហែល១៦ទៅ១៧ឆ្នាំប៉ុណ្ណឹង ដែលមានរាងកាយស្គមស្គាំងប្រហែលជានាងមានជំងឺយូរថ្ងៃមកហើយ ហើយប្រហែលទើបស្លាប់ព្រឹកមិញនេះទេ ព្រោះសាកសពមិនទាន់ហើមហើយមិនទាន់ធុំក្លិនផង ហើយគ្រួសារនាងប្រហែលគ្មានមធ្យោបាយជីករណ្តៅកប់ទើបគ្របក្រណាត់វាំងននទុកនាងចោលនៅទីនោះ ។ ខ្ញុំក៏សម្រេចចិត្តរើកន្លែងដេកតាមការទាមទាររបស់អាការា ។ ទីវត្តជីដុះនេះគ្មានព្រះសង្ឃទេ ហើយព្រះវិហារកុដិត្រូវបែកបាក់ខ្ទេចខ្ទី ដោយសារគ្រាប់បែក ឬគ្រាប់កាំភ្លើងក្នុងពេលប្រយុទ្ធ ។ ខ្ញុំពីរនាក់នាំគ្នាទៅដេកលើពានជណ្តើរស៊ីម៉ង់ត៍ ដែលនៅសល់ពីការបាក់បែក ។ យប់នេះ យើងទាំងពីរនាក់ដេកពុំបានលក់ស្រួលទេ ព្រោះអត់មានមុង មូសខាំយើងច្រើនណាស់ ។ ស្អែកឡើងខ្ញុំជិះកង់រហូតដល់ថ្ងៃរសៀលទើបមកដល់គគីរជីឥដ្ឋ នៅទីនេះ ខ្មែរក្រហមរៀបចំអ្នកណាទៅខេត្តណាអ្នកណាទៅស្រុកណា គឺសរសេរផ្លាកដាក់ប្រាប់ជាដំណឹង ។

នៅទីប្រជុំជនគគីរ មានមនុស្សកកកុញរាប់សែននាក់ ចំណែកឡាន-ម៉ូតូ អនាថា គ្មានម្ចាស់ចតចោលស្អេកស្កះពេញទឹកពេញដីសូម្បីតែនៅច្រាំងទន្លេក៏មានដែរ ។ កំពុងតែអង្គុយយកកម្លាំងនៅគល់គគីរពីរនាក់អាការា ស្រាប់តែឮឃោសនសព្ទបន្លឺឡើងថា “បើបងប្អូនណាទៅកាន់ខេត្តកំពង់ចាម សូមឡើងលើកប៉ាល់ជាបន្ទាន់ ព្រោះដល់ពេលចេញឥឡូវហើយ” ។

ខ្ញុំស្ទុះស្ទាវលើកបង្វេចស្ពាយនៅស្មា ចំណែកអាការាវាបណ្តើរកង់ចុះទៅច្រាំងទន្លេ ហើយលើកកង់ដាក់លើដំបូលកប៉ាល់ ចំណែកអ្នកមានឡានឬម៉ូតូគេមិនឲ្យដាក់ទេ គឺឲ្យដាក់តែកង់ និងមនុស្សប៉ុណ្ណោះ ។ កប៉ាល់ចាប់ផ្តើមចេញដំណើរ តែខ្ញុំមិនដឹងថាទៅទីណានោះទេ នៅក្នុងទន្លេក៏មានខ្មោចអណ្តែតទឹកច្រើនណាស់ដែរ ។ នៅលើកប៉ាល់រហូតដល់ម៉ោង១០យប់ទើបកប៉ាល់មកដល់ស្វាយសាច់ភ្នំ កប៉ាល់បានចូលចតនៅកំពង់ ។ នៅស្វាយសាច់ភ្នំនេះ អង្គការបានចាត់ចែងឲ្យគេដាំបាយសម្លទទួលអ្នកជម្លៀស ។ ខ្ញុំគ្មានចានដាក់បាយទេ មានតែឆ្នាំងដែល អាការា យកទៅដាក់សម្ល ហើយខ្ញុំដើរទៅកន្លែងចុងភៅ ឃើញមានស្មុគស្លឹកត្នោតពីរ-បី ខ្ញុំក៏សុំយកមកដាក់បាយ ហូបរួចហើយយើងក៏ចុះងូតទឹកទន្លេរួចហើយរកកន្លែងសម្រាក ចំណែក អាការា វាទៅចាំទទួលយកកង់ដែលគេកំពុងរើចុះពីកប៉ាល់ យប់នេះ យើងទាំងពីរនាក់ដេកលើចម្ការថ្នាំហាលសន្សើមមួយយប់ ដោយហត់ហេវ អស់កម្លាំងព្រោះ មិនបានដេកមួយយប់នៅឯវត្តជីដុះនោះ ខ្ញុំដេកគ្មានដឹងថា ត្រូវមូសខាំប៉ុន្មានឡើយ ។

ព្រឹកឡើងខ្ញុំធ្វើដំណើរឆ្ពោះមកទីប្រជុំជនផ្សារស្លូង នៅពេលថ្ងៃត្រង់ខ្ញុំឈប់សម្រាក និងដាំបាយ ស្រាប់តែជួបនឹងអ៊ំចាស់ៗដែលជាអ្នកស្រុកនៅទីនោះ គាត់ទាំងអស់បានសួរខ្ញុំទាំងពីរនាក់ ខ្ញុំប្រាប់គាត់តាមដំណើរ ហើយគាត់លួចខ្សឹបប្រាប់ថា បើទៅខាងមុខមានអ្នកណាសួរ សូមក្មួយប្រាប់ថា រៀនថ្នាក់តូចៗ ឬជាកម្មករបានហើយ ចំពោះថាពាក្យថា ធ្វើប៉ូលីស ធ្វើទាហាន ក្មួយកុំប្រាប់ឲ្យសោះ នោះទើបរស់បានជួបម៉ែ ។ គាត់ក៏បានចាកចេញពីខ្ញុំទៅ ។ ខ្ញុំបន្តមកទៀតរហូតដល់ថ្ងៃរសៀល ទើបខ្ញុំមកដល់ថ្នល់ទទឹង ខ្ញុំជិះកង់តម្រង់មកខាងទន្លេបិទវិញ ព្រោះវង្វេងស្រាប់តែមានម៉ូតូជិះតាមពីក្រោយ ហើយស្រែកថាៗៈ

- ឈប់ៗ! មិត្តទាំងពីរឈប់សិន!

ខ្ញុំងាកមកឃើញក្រុមអង្គការអាវខ្មៅពីរនាក់ ខ្ញុំកេះ អាការាឲ្យឈប់តាមពាក្យឃាត់ ។

- មិត្តឯងទាំងពីរនាក់ហ្នឹងទៅណាវិញ?

- បាទខ្ញុំទៅស្ទួង!

- ហ្អះ? ទៅស្ទួងម្តេចក៏ទៅតាមហ្នឹងវិញ?

- សុំទោសបង! ខ្ញុំមិនស្គាល់ផ្លូវទេ!

ពួកគេសម្លឹងមកខ្ញុំទាំងពីរនាក់

- មិត្តឯងធ្វើទាហានឬ?

- បាទ! អត់ទេខ្ញុំទាំងពីរនាក់ជាសិស្សសាលាទេ

ពួកគេនៅស្ងៀមហើយសុំឆែកបង្វេចខ្ញុំ រួចហើយប្រាប់ខ្ញុំថាៈ

- បើទៅស្ទួង មិត្តឯងជិះកង់តាមផ្លូវនេះគ្រន់ទៅប្រហែល ៧គីឡូទៀតដល់ហើយ ។

ខ្ញុំអរព្រួច ព្រោះពួកគេមិនបានយកទោសពៃរ៍អ្វីទេ ។ នៅពេលព្រលប់ ខ្ញុំបានទៅដល់ទីប្រជុំជនផ្សារស្ទួង តែនៅទីនោះ ខ្មែរក្រហមឃាត់ខ្ញុំមិនឲ្យចូលទៅផ្ទះទេ គឺឲ្យខ្ញុំដេកនៅទីនេះជាមួយអ្នកជម្លៀសឯទៀតៗជាច្រើន ។ អាការា វាសួរខ្ញុំៈ

- អាកា! ហ្នឹងឬស្រុករបស់ឯងនោះ?

- គឺហ្នឹងហើយ! យើងជិះកង់តាមផ្លូវនេះ តែ៥០០ម៉ែត្រទៀតដល់ផ្ទះអញហើយ ។

អាការា ព្ធដូច្នេះ វាជ្រួលច្រាល់អង្គុយបន្តិច ឈរបន្តិច

- យឺស...នៅតែចម្ងាយហ្នឹងសោះ ហេតុអ្វីយើងទៅមិនដល់?

- ចុះធ្វើម៉េច? បើគេមិនឲ្យយើងទៅ ។

បន្តិចក្រោយមក មានអ្នកដើរចែកបាយឲ្យអ្នកជម្លៀសមួយកញ្ចប់ម្នាក់ៗ នៅប្រហែលម៉ោង ៨យប់ទើបឃើញម្តាយខ្ញុំមករកខ្ញុំ ។ គ្រាន់តែឃើញម្តាយ ហើយម្តាយឃើញកូនភ្លាម ទឹកភ្នែកដ៏សោកសៅក៏ហូរមកឯកឯង ជំនួសពាក្យថ្នាថ្នៃងពីក្តីនឹករឭករវាងម្តាយ និងកូនដែលបានព្រាត់អស់ជាយូរឆ្នាំ ។

- កូនមកដល់ថ្មើរណាដែរ?

- បាទ! ខ្ញុំមកដល់តាំងពីព្រលប់ម៉្លេះ ។

- ចុះម៉ែដឹងថាខ្ញុំមកនេះពីអ្នកណា?

- គឺដឹងតាមអ្នកយកបាយមកចែកឲ្យហ្នឹង គាត់ឃើញដូចជាប្រហាក់ប្រហែល តែពុំហ៊ានសួរ ទើបគាត់មកប្រាប់ម៉ែឲ្យមករកមើល ។

- ម៉ែ! ស្អែកនេះគេបញ្ជូនកូនទៅស្រុកតំបែរទៀតហើយ ម្តាយខ្ញុំបង្ហូរទឹកភ្នែក សម្តែងនូវការនឹក និងស្រឡាញ់ខ្ញុំយ៉ាងជ្រាលជ្រៅ ។

- ប្រាំឆ្នាំហើយដែលកូនឃ្លាតពីម៉ែ ហើយប្រាំឆ្នាំនេះហើយដែលម៉ែទន្ទឹងរង់ចាំថ្ងៃកូនថានឹងបានកូនមកនៅរួមរស់ជិតទ្រូងម៉ែវិញ តែអ្វីដែលជាក្តីសង្ឃឹមរបស់ម៉ែត្រូវកាត់ផ្តាច់ចេញពីមនោសញ្ចេតនា រវាងម៉ែ និងកូន ដោយបញ្ញត្តិរបស់អង្គការ ដែលមិនអាចទាមទារឬតវ៉ាអ្វីបានឡើយណាកូន ។

- កូនសង្ឃឹមពីចម្ងាយមកថា នឹងបាននៅរួមរស់ជាមួយម៉ែពុក និងបងប្អូនវិញ តែឥឡូវត្រូវមកបំបែកចេញពីគ្នាឲ្យទៅរស់នៅលើដើងមេឃម្ខាងម្នាក់ដដែលទៀតសោះ ។

ក្រុមឈ្លបឲ្យម្តាយខ្ញុំត្រឡប់ទៅផ្ទះវិញ ។ ស្អែកឡើងរទេះគោជាច្រើនគ្រឿងបានដឹកជញ្ជូនអ្នកជម្លៀសទាំងអស់នេះទៅកាន់ព្រៃភ្នំក្រំថ្ម ជនបទដាច់ស្រយាល ។ គោដើរអូសរទេះឈូសដីហុយទ្រលោម ស្ទើរតែដកជង្គើមមិនរួចនៅតាមវាលស្រែដែលទើបនឹងច្រូតកាត់រួចបន្សល់តែគល់ជញ្ជ្រាំងក្រៀមក្រោះ និងដីស្រែស្ងួតបែកក្រហែង ទិដ្ឋភាពទាំងនេះមើលទៅហាក់ដូចជាស្រងេះស្រងោចខ្លាំងណាស់ សម្រាប់មាតុភូមិដ៏កំសត់នៃយើងនេះ ។ ក្បួនរទេះបានចេញមកដល់ចុងភូមិញ្ញោ ខ្មែរក្រហមក៏ឈប់សម្រាកលាងទឹកគោ ខ្ញុំ និង អាការា អង្គុយក្រោមម្លប់ដើមអំពិលធំមួយ ស្រាប់តែឃើញបងស្រីខ្ញុំជិះកង់បែកញើសពេញខ្លួនមកតាមខ្ញុំ ដើម្បីយកបាយកញ្ចប់ និងម្ហូបក្រៀមៗមួយត្រកតូចថែមទៀតមកឲ្យខ្ញុំ គាត់អង្គុយសម្រក់ទឹកភ្នែក យកដៃអង្អែលក្បាលខ្ញុំថ្នមៗ ហើយគាត់ផ្តាំថាៈ

- សូមប្អូនទៅឲ្យបានសុខ ហើយបើអង្គការប្រើធ្វើអ្វីគឺ ប្អូនធ្វើតាមទៅ កុំទាមទារតវ៉ាអ្វីឲ្យសោះ ប្អូនត្រូវចាំទុកជាប់ជានិច្ចកុំបីភ្លេចណា!

- បាទ! ខ្ញុំនឹងចាំជារៀងរហូត ។

- ហើយចំណែកប្អូនម្នាក់នេះដែលជាមិត្តភ័ក្តិរបស់ប្អូននោះត្រូវជួយមើលគ្នា ជួយដាស់តឿនក្រើនរំឭកគ្នា ហើយកុំឲ្យធ្វើអ្វីដែលខុស និងគោលមាគ៌ារបស់អង្គការអោយសោះ ចាំទុកណាប្អូន!

- បាទ! បងស្រី ។ **(តទៅលេខក្រោយ)** **ឌុំ សុភា**

# ដំណើរភៀសខ្លួនឆ្លងដែនពីរបបកម្ពុជាប្រជាធិបតេយ្យ

*រឿងពិតរបស់ ជា សីហា*

***(តពីលេខមុន)***

## ជាប់ចោទព្រោះទុកចិត្ត

អង្គការចោទប្រកាន់ខ្ញុំជាលើកទីពីរ ។ ដោយខ្ញុំរាប់អាន និងទុកចិត្ត ជាពិសេស ជាមួយបុរសចាស់ម្នាក់ឈ្មោះ សូត ជាអ្នកជិតខាងដែលមានដើមកំណើតពីកម្ពុជាក្រោម ។ ខ្ញុំបានភ្លោយមាត់ឱ្យបប្រាប់តា សូត ថា «ឆ្នាំៗទៅ ចាំបានដៃមកយើងវិញ យើងនឹងលែងកុំឲ្យសល់អំបាតមួយ ព្រោះទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី ព្រោះជាក្រឹត្យក្រមធម្មជាតិ» ។ ក្រោយមកមិនបានប៉ុន្មានថ្ងៃផង ប្រធានសហករណ៍ចាត់ប្រធានក្រុមឲ្យមកហៅខ្ញុំទៅប្រជុំ ។ ទៅដល់កន្លែងប្រជុំដែលជាកន្លែងស្ងាត់នៅកណ្ដាលវាលស្រែជុំវិញនឹងពេលព្រលប់ផង ខ្ញុំមើលពុំឃើញច្បាស់ពីសមាសភាពនៃអង្គប្រជុំនោះទេ ។ ខ្ញុំឮមាត់ប្រធានសហករណ៍បញ្ជាឲ្យខ្ញុំសារភាពកំហុសដែលខ្ញុំបានប្រព្រឹត្តពីថ្ងៃមុន ។ ខ្ញុំចាប់ផ្ដើមនិយាយតាមបែបបទអង្គប្រជុំថា ខ្ញុំសូមគោរពសមមិត្ត សូមគោរពពុកម៉ែ សូមគោរពមិត្តទាំងអស់ ។ អំពើឆ្គាំឆ្គងរបស់ខ្ញុំចំពោះអង្គការ ចំពោះសមមិត្តទាំងអស់គ្នាពិតជាមែនមានដោយអចេតនា ពីព្រោះខ្ញុំនៅល្ងង់ខ្លៅក្នុងបដិវត្តន៍ ហើយកម្មសិទ្ធិក៏មិនទាន់លះបង់អស់ ។ ទោះបីយ៉ាងណាក៏ដោយ ខ្ញុំប្រឹងប្រែងគោរពវិន័យ និងអង្គការចាត់តាំង ខ្ញុំខំប្រឹងបំពេញពលកម្មឲ្យបានមួយហិកតាបីតោនតាមទិសរបស់អង្គការដាក់ឲ្យ ។ ខ្ញុំសព្វថ្ងៃមានកំហុស ប៉ុន្តែ មើលខ្លួនឯងពុំឃើញដូចភក់ប្រឡាក់ខ្នង ។ ខ្ញុំសូមសមមិត្ត សូមពុកម៉ែ សូមមិត្តជួយកែលម្អកសាងរូបខ្ញុំឲ្យបានស្អាតស្អំ ដើម្បីបានបម្រើបដិវត្តន៍តទៅមុខទៀត ។ ខ្ញុំនិយាយមកដល់ត្រឹមណោះ អនុប្រធានសហករណ៍គំហកដាក់ខ្ញុំថា ចុះរឿងទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រីនោះយ៉ាងម៉េច? ។ ខ្ញុំសូមគោរព អង្គប្រជុំ ពាក្យនេះ ខ្ញុំពោលប្រាកដមែនសម្រាប់កែលម្អពុក សូត ពីព្រោះ គាត់ជាមនុស្សរួចលចិត្តត្អូញត្អែរចំពោះពលកម្មបន្តិចបន្តួចថា អង្គការធ្វើបាប គាត់មានអាយុចាស់ប៉ុណ្ណឹងហើយ អង្គការនៅតែប្រើគាត់ទៀត ។ ខ្ញុំតែងតែកសាងគាត់ថា កាលពីដើមពុកឯងជាអ្នកមានតែងមើលងាយកម្មកររបស់ពុកឯង ឥឡូវនេះ អង្គការលើកវណ្ណៈកម្មករ កសិករ ជាវណ្ណៈដឹកនាំវិញ ដូច្នេះ ពុកឯងមិនត្រូវតូចចិត្តទេ ព្រោះទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី ។ ខ្ញុំនិយាយតែប៉ុណ្ណឹងស្រាប់តែគាត់ខឹងនឹងខ្ញុំរហូតមក ដោយពោលថា ខ្ញុំជាក្មេងព្រហើនហ៊ានស្ដីប្រដៅគាត់ ។ មូលហេតុដែលខ្ញុំហ៊ានកសាងគាត់ ព្រោះអង្គការខទ្វេសនាមគ្រប់ពេលឲ្យយើងចេះកសាងគ្នា កែលម្អគ្នាដើម្បីបានបម្រើអង្គការបដិវត្តន៍ឲ្យបានល្អទាំងអស់គ្នា ។ រឿងនេះមានតែប៉ុណ្ណឹង ។ បើខ្ញុំធ្វើដូច្នេះខុសនឹងវិន័យអង្គការ សូមអង្គការកសាងរូបខ្ញុំ ហើយចាប់ពីពេលនេះតទៅ ខ្ញុំលែងហ៊ានកសាងពុក សូត ទៀតហើយ ។ ប្រធានសង្គមកិច្ចនិយាយថា មិត្ត អេង (ឈ្មោះរបស់ខ្ញុំនៅពេលនោះ) មិត្តឯងអត់មានកំហុសទេ ព្រោះយើងកសាងគ្នាដើម្បីឲ្យមិត្តបានល្អ ហើយត្រូវហ៊ានកសាងគ្នាបន្តទៀត ។ ប្រធានសហករណ៍ប្រកាសបិទអង្គប្រជុំ ។ ខ្ញុំវិលមកដល់ផ្ទះវិញ ភរិយាខ្ញុំ និងស្ត្រី ចាស់ៗពីរនាក់ដែលជាអ្នកជិតខាងខ្ញុំ និងចាស់ទុំក្នុងសហករណ៍បានសម្លឹងមុខខ្ញុំដោយសម្ដែងការតក់ស្លុត ហើយសួរមកកាន់ខ្ញុំថា លោកគ្រូយ៉ាងម៉េចទៅហើយ? ពួកយើងភ័យណាស់ អង្គការមានថាអ្វីឲ្យលោកគ្រូឬទេ? ខ្ញុំគ្រាន់តែឆ្លើយថា អង្គការឥតប្រកាន់ខ្ញុំទេ ។ គាត់សម្ដែងសេចក្ដីត្រេកអរ ហើយវិលទៅលំនៅស្ថានរបស់គាត់វិញ ។

## វិនាសកម្មកើតពីគំនិតចៅចាក់ស្មុគរបស់ខ្មែរក្រហម

ឆ្នាំ១៩៧៧ ទើបនឹងដាច់ទៅថ្មីៗនេះ ។ ការអត់ធ្មត់របស់ខ្ញុំលែងទ្រាំបានទៀតហើយ ។ ខ្ញុំកំពុងខ្វាយខ្វល់ជាខ្លាំងអំពីការរកមធ្យោបាយរំដោះខ្លួន និងប្រជាជនឲ្យរួចពីរបបខ្មែរក្រហមអបល្លំណ៍ ។ ពាក្យបណ្ដាំរបស់ឪពុកមុននឹងគាត់លាចាកលោកនេះទៅថា ឲ្យកូនតស៊ូរំដោះជាតិពីរបបខ្មែរក្រហម ។ ពាក្យឪពុកឮរណ្ដំនៅឡើយក្នុងត្រចៀក ។ កូនស្រីរបស់ខ្ញុំទើបតែមានអាយុ៥ខែ តើខ្ញុំជាឪពុកដាច់

ចិត្តទៅចោលកូនដែរឬទេ? គម្រោងថា ទៅវាយដណ្តើមកាំភ្លើងពីយោធាខ្មែរក្រហម ក៏ត្រូវបរាជ័យ ព្រោះ មិត្តភក្តិសុំពន្យារពេល តើអាចត្រូវបែកការណ៍ទេ? ។ ទាំងនេះជាទុកកង្វល់របស់ខ្ញុំនៅពេលនោះ ។ ខ្ញុំបានត្រូវអង្គការចាត់ឲ្យទៅធ្វើ ចម្ការ គឺដាំបន្លែ និងថ្នាំជក់នៅលើទួលប្រាសាទគោកប្រដាក ។ អង្គការដាក់ទិសឲ្យខ្ញុំទៅគាស់យកឥដ្ឋប្រាសាទមកធ្វើចង្ក្រានរួម ។ ខ្ញុំសែនតក់ស្លុតនៅពេលឮប្រធានសហករណ៍ចាត់ខ្ញុំទៅគាស់ប្រាសាទបុរាណ ។ ខ្ញុំភិតភ័យចំពោះការបំពានលើបុរាណវត្ថុរបស់បុព្វបុរស ។ ខ្ញុំសោកស្តាយចំពោះប្រាសាទបែកបាក់មួយដែលត្រូវរលាយក្រោមស្នាដៃខ្ញុំ ។ ចបត្រសេះ ដែលខ្ញុំកាប់គាត់លើឥដ្ឋប្រាសាទ ហាក់ដូចជា ខ្ញុំកាប់លើដើមទ្រូងខ្លួនឯង សែនឈឺចាប់សែនស្តាយ តើឲ្យខ្ញុំគេចវេះពីបញ្ជារបស់អង្គការដូម្តេចបាន? ។ ឯប្រាសាទមួយទៀត ជាមុខព្រួញរបស់ក្រុមឯទៀត ។ ខ្ញុំទៅកាន់ប្រាសាទដែលខ្ញុំទៅកាប់គាស់តែម្នាក់ឯង ។ ខ្ញុំកាច់មែកទន្ទ្រានខេត្ត ផាប់បីកង់ធ្វើជំនួសធូប ។ ខ្ញុំអុជខាងចុងមែកឲ្យឆេះបន្តិចហើយដោតមុខក្លោងទ្វារប្រាសាទ ។ ខ្ញុំនមស្ការដោយស្ងាត់ថា សូមវិញ្ញាណក្ខន្ធបុព្វបុរសជាទីគោរពដ៏ខ្ពង់ខ្ពស់នៃខ្ញុំ ព្រោះមានបញ្ជាពីពួកអបលក្ខណ៍បំផ្លាញសាសនាឲ្យខ្ញុំករុណាមករុះរើបំផ្លាញកេរដំណែលដ៏មានតម្លៃលើសលប់របស់ដូនតា ខ្ញុំព្រះករុណាពុំអាចប្រកែកបាន បើខ្ញុំព្រះករុណា ពុំធ្វើតាមបញ្ជារបស់គេ គេមុខជានឹងសម្លាប់ខ្ញុំ ហេតុនេះសូមដូនតា កុំប្រកែប្រកាន់ខ្ញុំ ខ្ញុំនឹងគាស់ឥដ្ឋបែកបាក់នៃប្រាសាទរបស់ដូនតានៅពេលនេះ ។ ដោយកិរិយាខុសឆ្គងរបស់ខ្ញុំនេះ សូមកុំឲ្យខ្ញុំមានបាប សូមដូនតាកុំចងពៀរនឹងខ្ញុំ ព្រោះខ្ញុំជាអ្នកបម្រើគេ បើដូនតាចង់ចងពៀរ សូមដូនតាទៅផ្តន្ទាខ្មែរក្រហមជាអ្នកបញ្ជាទាំងនោះចុះ ។ សូមទេព្តាធ្វើជាសាក្សីនៃសេចក្តីសច្ចាប្រណិធានរបស់ខ្ញុំព្រះករុណា ។ ខ្ញុំលួចធ្វើបែបនេះរៀងរាល់ព្រឹក នៅពេលទៅដល់ប្រាសាទ ដោយមិនឲ្យអ្នកដទៃឃើញ ។ មានម្តងនោះ ក្រោយពេលធ្វើសច្ចាចប់ ហើយខ្ញុំឮសូរសំឡេងគ្រហែមពីក្រោយខ្នងរបស់ខ្ញុំ ខ្ញុំឃើញមិត្តឆើយ កម្មាភិបាលឈរនៅជិតខ្ញុំ ហើយគាត់ដើរចេញទៅ ។ ខ្ញុំភ័យសែនភ័យ ខ្ញុំនឹកថាជីវិតខ្ញុំនឹងចប់នៅពេលនេះហើយ ប៉ុន្តែ ឥតមានប្រតិកម្មអ្វីពីមិត្តឆើយ សោះ ។ ខ្ញុំនឹកអគុណចំពោះសេចក្តីប្រោសប្រណីរបស់គាត់ ។ គាត់ជាកម្មាភិបាលម្នាក់ដែលមានចរិតស្លូតបូត ចេះអាណិតអាសូរដល់ប្រជាជន ។ រីឯភរិយារបស់គាត់ក៏មានចរិតមិនខុសពីប្តីរបស់គាត់ទេ គាត់ជាមនុស្សស្រស់ស្រាយ រាប់អានប្រជាជនស្មើគ្នា មិនចេះប្រកែប្រកាន់ដូចពួកកម្មាភិបាលដទៃឡើយ ។ ខ្ញុំជីកកកាយរំលើងប្រាសាទមួយទាំងមូលរហូតដល់បាតដែលក្រាលដោយថ្មបាយក្រៀមពណ៌លឿងស្រស់ ។ កម្រាលពីក្រោមថ្មបាយក្រៀមនោះជាខ្សាច់ម៉្យាងម៉ដ្ឋដូចម្សៅអាចជាម្សៅដីលែង ប៉ុន្តែ មានពណ៌ស មិនជ្រាបទឹក ។ ជីកទៅដល់បាតមានជម្រៅប្រមាណ៣ម៉ែត្រពីមាត់រណ្តៅ ខ្ញុំលុតជង្គង់លើកដៃសំពះសំបូងសន្ទ្រូងដល់វិញ្ញាណក្ខន្ធនៃបុព្វបុរសដែលបានកសាងប្រាសាទតូចមួយដែលមានទំហំប្រមាណ៥ម៉ែត្របួនជ្រុងនេះ ប្រកបដោយស្ថាបត្យកម្មដ៏វិចិត្រ ។ យើងពុំដឹងកម្ពស់របស់ប្រាសាទនេះទេ ពីព្រោះដំបូលរបស់ប្រាសាទធ្លាក់បាក់អស់ហើយ នៅសល់តែក្លោងទ្វារធ្វើអំពីថ្មរីងពណ៌ខៀវ ។ ផ្ទាំងក្លោង ទ្វារខាងក្នុងមានអក្សរចារឹកជាអក្សរខ្មែរបុរាណ ។ ខ្ញុំផ្តួលក្លោងទ្វារនេះ ទម្លាក់ទៅក្នុងរណ្តៅហើយ កាយដីកប់ និងផ្នែកខ្លះរបស់ប្រាសាទនោះ ដោយនឹកថា មានមនុស្សជំនាន់ក្រោយមកធ្វើកំណាយមុខជាឃើញផ្ទាំងសិលាចារឹកនេះ ។ នៅពេលជីកគាស់ប្រាសាទនេះ ខ្ញុំបានប្រទះឃើញបដិមាព្រះប្រក់នាគធ្វើអំពីលោហៈពណ៌លឿងប្រមាណប៉ុនបាតដៃរបស់ខ្ញុំ ។ ក្បាលនាគពីរដែលគ្របលើព្រះពុទ្ធ និងបល្ល័ង្កផ្នែកខាងក្រោម ពុកដាច់បាត់ហើយ តួបដិមាទាំងមូលស្រោបដោយកម្ទេចឥដ្ឋយ៉ាងក្រាស់ បញ្ជាក់ថា បដិមានេះមានចំណាស់យូរលង់មកហើយ ។ ការរកឃើញបដិមានេះ ជាចៃដន្យមួយ ព្រោះនៅពេលដែលខ្ញុំយកចបប៉ែលចាក់បំណែកឥដ្ឋហើយគ្រវែងទៅ ខ្ញុំឃើញដុំឥដ្ឋរាងមូលពងក្រពើរមៀលទៅក្រោមពំនូកដី ខ្ញុំនឹកប្លែកក្នុងចិត្ត ក៏ស្ទុះទៅយកដុំឥដ្ឋនោះមកមើល ។ ដោយកាយវិការរបស់ខ្ញុំនោះហើយ បានធ្វើឲ្យមនុស្សម្នាក់ទៀតឈ្មោះ រ៉ាន់ចាប់អារម្មណ៍ ហើយស្រែកសួរខ្ញុំថា មិត្តរកឃើញអ្វី? ខ្ញុំឆ្លើយតាមត្រង់ថា ខ្ញុំឃើញកម្ទេចឥដ្ឋមួយដុំមានរាងមូល ។ នៅពេលខ្ញុំដើរចុះទៅរើសដុំឥដ្ឋក៏ចម្លែកនោះ មិត្ត រ៉ាន់ ក៏មកដល់ល្មម ។ យើងពិនិត្យដុំឥដ្ឋដ៏ចម្លែកនោះជាមួយគ្នា ។ នៅពេលខ្ញុំគោះដុំឥដ្ឋផ្ទប់នឹងដុំថ្ម នៅមាត់ទឹកប្រឡាយ លោហៈពណ៌មាសលេចចេញមក ។ ខ្ញុំមានចិត្តត្រេកអររំភើប ដោយបដិមាពណ៌ជាវត្ថុបុរាណ ប៉ុន្តែ មិត្ត រ៉ាន់ ជាសហការីរបស់ខ្ញុំជាមនុស្សម៉ឺងម៉ាត់ មានជំហរបដិវត្តន៍ដាច់ខាត

ស្រែកដាក់ខ្ញុំថា មិត្តឯងចង់ក្បត់អង្គការឬ? ព្រោះឃើញខ្ញុំយកបដិមាដាក់ក្នុងហោប៉ៅខោ ។ ខ្ញុំឆ្លើយបដិសេធថា កុំចោទខ្ញុំអីចឹង ខ្ញុំនឹងយកទៅជូនអង្គការនៅពេលខ្ញុំនៅដល់ផ្ទះនៅល្ងាចនេះ ។ មកដល់ផ្ទះវិញ ខ្ញុំយកបដិមាពីក្នុងហោប៉ៅខោមកបង្ហាញភរិយារបស់ខ្ញុំនៅក្រោមពន្លឺចង្កៀងខ្វាញ់ត្រី ។ យើងស្ងប់ស្ងែងចំពោះបុរាណវត្ថុនោះណាស់ ។ ដោយប្រញាប់ប្រញាល់នឹងយករតនៈវត្ថុនោះទៅជូនអង្គការឲ្យទាន់ពេល ចៀសវាងការសង្ស័យដែលមិត្តវ៉ាន់ មានចំពោះខ្ញុំ ។ ខ្ញុំស្ទាបអង្អែលព្រះដោយសេចក្ដីគោរព និងស្រលាញ់ជាទីបំផុត ទើបខ្ញុំដួសទឹកមួយផ្ដិលមកដាក់លើគ្រែ ហើយលើកដៃសំពះបួងសួងថា បើព្រះបដិមាមានមហិទ្ធិឫទ្ធិមែន សូមព្រះអង្គបង្ហាញឲ្យខ្ញុំព្រះករុណាបានឃើញនៅពេលនេះផង ។ រួចហើយ ខ្ញុំយកព្រះបដិមាដាក់ក្នុងទឹកផ្ដិល ទើបខ្ញុំទៅដាស់កូនទី៥របស់ខ្ញុំពីដំណេក ខ្ញុំយកទឹកក្នុងផ្ដិលនោះស្រពលើក្បាលកូនរបស់ខ្ញុំហើយ ខ្ញុំសូមផ្សងសច្ចាថា សូមឲ្យកូនខ្ញុំជាពីរោគខ្វាក់មាន់ ។ ភ្លាមនោះ ខ្ញុំបញ្ជាឲ្យកូនខ្ញុំចេញទៅក្រៅខ្ទម ដើម្បីទៅបត់ជើងតូច ដោយត្រូវដើរឆ្លងស្ពានតូចមួយកាត់ប្រឡាយនៅពីមុខផ្ទះ ។ កូនខ្ញុំចេញដើររ៉ុយទៅដោយឥតទើសទាក់អ្វីឡើយ ព្រោះតាមទម្លាប់ ខ្ញុំត្រូវដឹកដៃវាដើរឆ្លងស្ពាន ព្រោះវាកើតរោគខ្វាក់មាន់ពុំអាចមើលផ្លូវ និងស្ពានឃើញទេនៅពេលយប់ ។ ពេលនោះរោគខ្វាក់មាន់ របស់វាបានជាហើយ ។ គួរឲ្យអស្ចារ្យណាស់ ព្រះបដិមាពិតជាមានតេជានុភាពមែន ។ ខ្ញុំយកព្រះបដិមាទៅឲ្យប្រធានសហករណ៍ដោយអាឡោះអាល័យជាទីបំផុត ។ រហូតមកដល់បច្ចុប្បន្ននេះ ពេលវេលាកន្លងទៅរាប់សិបឆ្នាំមកហើយ ខ្ញុំនៅនឹងឃើញព្រះបដិមានោះឥតភ្លេចឡើយ ។ ខ្ញុំពុំអាចរកបដិមានោះបានមកវិញទេ ឯទីតាំងប្រាសាទគោកប្រដាក់ក៏ស្ថិតនៅត្រមោចទាំងគូ ក្នុងគុម្ពោតព្រៃកណ្ដាលវាលស្រែនៃភូមិស្នួល គោងដែលខ្ញុំបានទៅឃើញជាថ្មីទៀតកាលពីអំឡុងឆ្នាំ២០០០ ។

ក្រោយពីការកាប់គាស់យកឥដ្ឋប្រាសាទអស់ហើយ ខ្ញុំលុបដីទៅវិញ ។ ដីនោះ គឺជាកម្ទេចផង់របស់ឥដ្ឋដែលពុកផុយ ។ ខ្ញុំពង្រីកដីចម្ការលើទួលប្រាសាទនោះ បានធំជាងមុន ។ ដីដែលជាកម្ទេចឥដ្ឋជាដីខ្សាច់ គ្មានជីជាតិ ។ ដីចម្ការនោះមានទំហំប្រមាណជិត៤០ម៉ែត្របួនជ្រុង ។ ប្រមាណពាក់កណ្ដាល ទំហំដីចម្ការ ខ្ញុំដាំបន្លែមានស្ពៃខាត់ណា ត្រប់ ល្ពៅ ត្រសក់ ឯកចំណែកពាក់កណ្ដាលទៀត ខ្ញុំដាំថ្នាំជក់ ។ ដាំបន្លែមិនសូវបានផលទេ ពីព្រោះសត្វល្អិត សត្វកណ្ដុរដីច្រើនពាក់ពពូនមកស៊ីបំផ្លាញស្ទើរតែពុំសេសសល់ ។ ដំណាំល្ពៅបានផលខ្លះដែរ តែពុំធ្លូនល្មមនឹងកម្លាំង ។ យើងពុំមានជី ពុំមានថ្នាំកម្ចាត់សត្វល្អិត ដំណាំទាំងនោះពុំអាចលូតលាស់បានឡើយ ។ មានតែដំណាំថ្នាំជក់បានផលជាមធ្យម ។ ខ្ញុំប្រមូលអាចម៍មាន់ពីទ្រុងរួមនឹងថ្នាំជក់ ។ ដើមថ្នាំលូតលាស់ល្អ មានស្លឹកធំៗដោយមានជ័រស្អិតពាសពេញ ។ សត្រូវរបស់ដើមថ្នាំជក់គឺដង្កូវនៅក្នុងដើមធ្វើឲ្យដើមថ្នាំប៉ោងឡើងត្រង់កន្លែងដង្កូវរស់នៅ ។ គេត្រូវវះដើមថ្នាំយកដង្កូវចេញ បើពុំធ្វើទេ ដើមថ្នាំនឹងងាប់ ឬក្រិន ។ ថ្នាំជក់ខ្ញុំដាំមានរសជាតិខ្លាំង ជាថ្នាំមានគុណភាពល្អ ។ មានប្រជាជនខ្លះហៅខ្ញុំថា តាថ្នាំខ្លាំង ។ ក្នុងមួយឆ្នាំ ភោគផលទាំងអស់ដែល ខ្ញុំខំដាំដុះពុំមានតម្លៃស្មើនឹងតម្លៃអង្ករដ៏តិចតួចដែលខ្ញុំបានបរិភោគឡើយ ពីព្រោះភោគផលទាំងនោះរឹតតែតិចជាងតម្លៃអង្ករទៅទៀត ។ ខ្ញុំនឹកថា ខ្ញុំខំធ្វើការដោយហ្មត់ចត់តាំងពីព្រលឹមទល់ព្រលប់មួយឆ្នាំពេញមួយឆ្នាំគ្មានថ្ងៃសម្រាកដល់បានភោគផលមកវិញតិចតួចបំផុតមិនសមនឹងកម្លាំង មកពីកង្វះបច្ចេកទេសធ្វើដំណាំ ដីគ្មានជីជាតិ សត្វចង្រៃបំផ្លាញ ។ ខ្ញុំយល់យ៉ាងច្បាស់ថា សេដ្ឋកិច្ចទូទៅរបស់អង្គការដែលបង្កបង្កើតឡើងដោយទាសកម្មករគ្មានជំនាញពិតជានឹងក្ស័យធនពុំខាន ។

ខ្មែរក្រហមគិតថា នៅសម័យមុន អ្នកស្រែជាអ្នកចិញ្ចឹមអ្នកទីក្រុង ។ អ្នកស្រែជាអ្នកធ្វើការច្រើន ហើយទទួលបានតម្លៃតិចតួច ។ គេចាត់អ្នកស្រែថា ជាវណ្ណៈដែលត្រូវគេជិះជាន់ ។

ចំណែកអ្នកទីក្រុងវិញ ធ្វើការតិច ប៉ុន្តែទទួលបានកម្រៃច្រើន ជាឈ្មួញកណ្ដាល ជាអ្នកកេងប្រវ័ញ្ចលើអ្នកស្រែ ជាអ្នកដើរលេងហ៊ឺហា ជាអ្នកចាំតែស៊ីឥតចេះធ្វើការងារបង្កបង្កើនភោគផលអ្វីសោះ ត្រូវបានខ្មែរក្រហមចាត់ថា ជាវណ្ណៈជិះជាន់គេ ។

តាមគំនិតដែលគេហៅថា ភ្លឺស្វាង មហាលោតផ្លោះ មហាអស្ចារ្យរបស់អង្គការបដិវត្តន៍នោះ យល់ថា បើយកអ្នកទីក្រុងទាំងអស់ឲ្យមកធ្វើស្រែក្រោមការត្រួតត្រារបស់អ្នកស្រែវិញនោះ អង្គការនឹងត្រូវបានចំណេញយ៉ាងច្រើន គឺចំណេញទាំងផ្នែកនយោបាយ និងសេដ្ឋកិច្ច គឺព្រួញមួយបាញ់បានសត្វពីរ ។

ខាងផ្នែកនយោបាយ អង្គការបានវាយកម្ទេចវណ្ណៈជិះជាន់ ហើយលើកតម្កើងវណ្ណៈកសិករ និងកម្មករឲ្យជិះជាន់លើពួកដែលជាអតីតអ្នកជិះជាន់គេវិញម្ដង ។

ខាងផ្នែកសេដ្ឋកិច្ច អង្គការបដិវត្តន៍បន្ថយរបបហូបចុកឲ្យនៅតិចបំផុត ហើយបង្កើនផលិតកម្មឲ្យបានច្រើនបំផុត ដូច្នេះអង្គការមុខជានឹងទទួលបានកំណើនសេដ្ឋកិច្ចដ៏សម្បូរហូរហៀ ។

លទ្ធផលបន្ទាប់ពីធ្វើបដិវត្តន៍បាន៣ឆ្នាំ ខាងផ្នែកនយោបាយ អង្គការទទួលបរាជ័យ ព្រោះផ្ទៃក្នុងបែកបាក់គ្នា កាប់សម្លាប់គ្នាជាបន្តបន្ទាប់ ។ ខាងផ្នែកសេដ្ឋកិច្ច អង្គការត្រូវក្ស័យធន ព្រោះពុំបានធ្វើអ្វីឲ្យរីកចម្រើនសោះ មានតែធ្វើឲ្យប្រជាជនគ្មានបាយហូបហើយដាច់ពោះស្លាប់ ។

ដោយទទួលបរាជ័យទាំងស្រុងដូច្នេះ អង្គការយល់ថា ត្រូវធ្វើអ្វីមួយឲ្យត្រូវចំចំណុចសេរីរបស់ប្រជាជន ដើម្បីលើកមុខមាត់របស់ខ្លួនឡើងវិញ ។ គឺអង្គការលើកទ័ពទៅវាយយួន ព្រោះអាងលើជំនួយរបស់ចិន ។ ដល់ពេលទទួលបរាជ័យក៏បន្ទោសទៅលើពួកបូព៌ាថា ក្បត់អង្គការទៅចូលដៃជាមួយយួន ។ ដល់ពេលយួនវាយបកមកវិញ ហើយចិនជួយមិនទាន់ក៏តាំងរត់បែកខ្ញែកគ្នាទៅពួនតាមព្រំដែនខ្មែរ-ថៃ ។ ទាំងអស់នេះហើយ ជាលទ្ធផលនៃគំនិតចាក់ស្មុគរបស់ខ្មែរក្រហម ។

នៅក្នុងចម្ការ ក្រោយពីធ្វើដើងដើមថ្នាំជក់បានមួយចំនួនរួចមក ខ្ញុំមកកាន់ចង្ក្រានដើម្បីរៀបចំដាំបបរ ។ ពីព្រឹកមិញតាគង្វាលទានៅស្នួលកោងបានឲ្យពងទារលូតពីរមកខ្ញុំ ។ ពងទារលូតពីរជាជំនូនដ៏មានតម្លៃសម្រាប់អ្នកអត់ឃ្លាននៅពេលនោះ ។ ពងទារលូតបាននាំកង្វល់មកឲ្យខ្ញុំ គឺចំណង់នៃការចែករំលែកអាហារក៏ប្រណីតនេះឲ្យទៅប្រពន្ធកូនដែលនៅផ្ទះ ។ ចំណង់របស់ខ្ញុំនេះ ពិតជាពុំអាចធ្វើតាមបានឡើយ ពីព្រោះចម្ការនៅឆ្ងាយពីផ្ទះ នៅផ្ទះក៏គ្មានចង្ក្រានសម្រាប់ចម្អិនដែរ ។

តាមទំហំនៃសេចក្ដីស្រេកឃ្លាន តើខ្ញុំត្រូវយកពងក៏កម្រនេះទៅធ្វើម្ហូបអ្វីបានប្រសើរបំផុតនោះ ។ គិតចុះ គិតឡើង ខ្ញុំនឹកឃើញថា ពងទាចំហុយពិតជាជម្រើសដ៏ល្អបំផុត ពីព្រោះ បានទាំងបរិមាណនិងរសជាតិ ។ ប្រតិបត្តិការនៃការចំហុយពងទាក៏ប្រព្រឹត្តឡើង ។ ខ្ញុំហែកសំបកពងទាទាំងពីរ ហើយចាក់ចូលទៅក្នុងចានធំទើបយកអំបិលម៉្ដចាក់ពីលើពងទានោះ ។ ក្នុងពេលជាមួយគ្នានោះ ខ្ញុំឮស្នូរជើងមនុស្សនៅពីមុខខ្ញុំ ខ្ញុំងើបមុខឡើងសម្លឹងទៅមនុស្សនោះ ស្រាប់តែស្មារតីខ្ញុំរត់ចេញពីរូបទៅបាត់ខ្ញុំកំពុងភាន់ភាំងស្ទើរបាត់វិញ្ញាណ ។ បន្ទឺសូរសព្ទជាសម្ដីរាក់ទាក់មករកខ្ញុំដែលខ្ញុំស្គាល់ច្បាស់ គឺគ្មាននរណាក្រៅពីមិត្ត ឌុំ ប្រធានសហករណ៍ដ៏មានអំណាចនោះឡើយ ។ គាត់សួរខ្ញុំថា តើមិត្តបានអីហូប? ខ្ញុំឆ្លើយទាំងរញ៉េរញ៉ៃថា បានពងទារលូតដែលខ្ញុំរើសបានតាមភ្លឺស្រែ ។ ប្រធានសហករណ៍ក៏បន្តដំណើរទៅមុខទៀត ។ ពេលដ៏ខ្លីដែលខ្ញុំសាសងជាមួយមិត្ត ឌុំ ម្រាមដៃរបស់ខ្ញុំចិបអំបិលដាក់ពីលើពងទាយ៉ាងញាប់ ខ្ញុំមិនដឹងថា មានចំនួនប៉ុន្មានឡើយ ។ ខ្ញុំងើបឈរជូនដំណើរប្រធានសហករណ៍ដោយសេចក្ដីគោរព និងគួរសម ។ ខ្ញុំងាកមើលទៅក្នុងចានពងទា ឃើញអំបិលរលាយចូលជាមួយពងទាបាត់អស់ទៅហើយ ។ ខ្ញុំក៏យកស្លាបព្រាវាយពងទាឲ្យរលាយ ចូលគ្នាសព្វល្អ ហើយក៏លើកចានដាក់ក្នុងឆ្នាំងដាក់ទឹកពីក្រោមចាន ហើយលើកឆ្នាំងដាក់កំណល់លើចង្ក្រាន ហើយដុតភ្លើង ។ ប៉ុន្មាននាទីក្រោយមក ពងទាចំហុយក៏ឆ្អិនឡើងពោរពីលើមាត់ចាន ។ ពោះខ្ញុំក៏ចាប់ផ្ដើមកូរ ព្រោះដឹងថាចំណីឆ្ងាញ់ពិសេសបានឆ្អិនហើយ ហើយមុខជានឹងទទួលឱជារសពីម្ហូបពងទាចំហុយនៅពេលដ៏ខ្លីខាងមុខនេះ ជាពុំខាន ។ ពុទ្ធោអើយ គ្រាន់តែស្លាបព្រាដែលដួសពងទាដាក់ចូលទៅក្នុងមាត់ខ្ញុំភ្លាមទាំងក្ដៅ រសប្រៃល្វីងរបស់ពងទាចំហុយធ្វើឲ្យខ្ញុំពិបាកនឹងលេប ។ រសជាតិឆ្ងាញ់ដែលខ្ញុំសង្ឃឹមទុកប្រែទៅល្វីង ។ ទោះរសប្រៃខ្លាំងក្លាយ៉ាងណា ក៏ឈ្មោះម្ហូបនៅតែដដែល គឺពងទាចំហុយ ។ ខ្ញុំខំប្រឹងលេបទៅតាមកម្លាំងឃ្លាន ព្រោះ តែម្ហូបដែលកម្រមានក្នុងសម័យនោះ ។ ខ្ញុំទទួលទានបានប្រមាណបីបួនស្លាបព្រាក៏លេបលែងរួច ។ ម្ហូបនៅសល់ ខ្ញុំយកទៅឲ្យអ្នកចម្ការជិតខាងបរិភោគអស់គ្មានសល់ ។ រឿងពងទាចំហុយនេះធ្វើឲ្យខ្ញុំព្រឺខ្លួន ពីព្រោះវាជាអំពើក្បត់សមូហភាពរបស់ខ្ញុំ ។ អង្គការលើកឡើងគ្រប់អង្គប្រជុំឲ្យស្មោះត្រង់នឹងសមូហភាពទោះក្ដាមមួយ ឬខ្យងមួយក៏ត្រូវតែយកមកដាក់ក្នុងម្ហូបរួម មិនត្រូវពួនហូបតែម្នាក់ឯងនោះទេ ។ អំពើក្បត់សមូហភាពត្រូវទទួលខុសត្រូវដោយខ្លួនឯង ។ ខ្ញុំបានក្បត់សមូហភាពហើយក្រោមខ្សែភ្នែករបស់ប្រធានសហករណ៍ ។ តើខ្ញុំត្រូវនៅស្ងៀមដោយរង់ចាំមើលប្រតិកម្មរបស់ប្រធានសហករណ៍ ឬខ្ញុំត្រូវទៅសារភាពក្នុងប្រជុំជីវភាពរបស់

អង្គភាពខ្ញុំផ្ទាល់? បើរឿងនេះ បែកការណ៍ឬខ្ចរខ្ចាយទៅ តើខ្ញុំត្រូវមានទោសដូចម្តេច? តើអ្នកគង្វាលទានឹងត្រូវមានទោសដោយសារការអាណិតអាសូររបស់គាត់ចំពោះរូបខ្ញុំយ៉ាងដូចម្តេច? សេចក្តីភ័យព្រួយបានញាំញីចិត្តរបស់ខ្ញុំអស់រយៈពេលយូរក្រៃលរហូតដល់ពេលដែលខ្ញុំបានដំណឹងពីតាប្រធានចម្ការថា សមមិត្តប្រធានសហករណ៍ពុំប្រកាន់ទោសអូសដំណើរដល់រូបខ្ញុំឡើយ ។

## ជាប់ចោទព្រោះកូន

ថ្ងៃមួយនៅចុងខែមីនា ឆ្នាំ១៩៧៨ មានព្រឹត្តិការណ៍មួយដ៏ឃោរឃៅធ្លាក់មកលើកូនទី៤របស់ខ្ញុំ ឈ្មោះ យុពា ។ យុពា នៅពេលមានអាយុ៦ឆ្នាំ ។ យុពា និងកុមារផ្សេងទៀត នៅក្រុមជាមួយគ្នា បានត្រូវអង្គការចាត់តាំងកុមារចាត់ឲ្យទៅប្រមូលលាមកគោនៅតាមស្រែ ។ កុមារទាំងនោះ ពុំបានគោរពបទបញ្ជាឲ្យបានហ្មត់ចត់ ធ្វើខុសវិន័យអង្គការ ដោយនាំគ្នាដើរវាយកណ្តុរយកមកអាំងហូបទៅវិញ ។ សកម្មភាពនេះ ធ្វើឲ្យមេឈ្លបម្នាក់ឈ្មោះ ពុំ ក្រេវក្រោធជាខ្លាំង ហើយចាប់កុមារដែលមានកំហុសមកដាក់ទណ្ឌកម្ម ។ គឺទណ្ឌកម្មដ៏ឃោរឃៅដោយយកកុមារម្នាក់ៗ ទៅច្រកចូលក្នុងបាវមួយរៀងៗខ្លួន ហើយចងមាត់បាវ ។ ដោយខ្វះខ្យល់ដកដង្ហើម កុមារខ្លះក៏សន្លប់នៅក្នុងបាវ កុមារខ្លះទៀតខំរើបម្រះរហូតដល់ចេញលាមកចេញនោមនៅក្នុងបាវ ។ ក្នុងចំណោមកុមារទាំងនោះ មានកុមារ យុពា នៅក្នុងនោះដែរ ។ ខណៈនោះមានកុមារម្នាក់បានរត់ទៅប្រាប់ខ្ញុំនៅចម្ការអំពីរឿងនេះ ។ សេចក្តីក្រេវក្រោធបានគ្របសង្កត់លើខ្ញុំធ្វើឲ្យឃុំគ្រងចិត្តពុំបាន ក៏ស្ទុះទៅយកកាំបិតផ្គាក់លីរត់សំដៅទៅកាន់កន្លែងកើតហេតុ ដើម្បីទៅរំដោះកូនពីក្នុងបាវ ទោះត្រូវប្រយុទ្ធគ្នាក៏ដោយ ។ ចំណែក ផលវិបាកចាំគិតជាក្រោយឲ្យតែបានកូននៅគង់វង្សជីវិត ។

មកដល់ពាក់កណ្តាលផ្លូវ មានមិត្តភក្តិរបស់ខ្ញុំម្នាក់បានស្ទាក់ផ្លូវខ្ញុំ ហើយសូមអង្វរខ្ញុំឲ្យអត់សង្កត់ចិត្តឲ្យបាន បើពុំនោះសោតទេផលអាក្រក់នឹងធ្លាក់មកលើខ្ញុំ លើគ្រួសារខ្ញុំ និងលើអ្នកសហករណ៍ទាំងមូលផងក៏អាចថាបាន ។ ខណៈនោះ ក៏មានមិត្តម្នាក់ទៀតមកប្រាប់ខ្ញុំថា យុពា ត្រូវគេយកចេញពីបាវ ហើយឥតមានគ្រោះថ្នាក់ទេ គ្រាន់តែសន្លប់មួយភ្លែតតែប៉ុណ្ណោះ ។ ឯមេឈ្លបឈ្មោះ ពុំ ត្រូវបានប្រធានសហករណ៍នាំខ្លួនទៅកាន់ផ្ទះរបស់គាត់ ។ ដើម្បីចៀសវាងរឿងរ៉ាវជាយថាហេតុ ខ្ញុំក៏វិលទៅចម្ការវិញ ។ ប្រតិកម្មរបស់ខ្ញុំទាំងប៉ុន្មានក្នុងពេលនោះ ពុំកំបាំងពីភ្នែករបស់កម្មាភិបាលក្តាប់រួមរបស់សហករណ៍ឡើយ ។ នៅល្ងាចថ្ងៃនោះ វេលាព្រលប់ស្នូរជួងបន្លឺឡើងជាសញ្ញាហៅប្រជាជនសហករណ៍ឲ្យទៅប្រជុំនៅវាលស្រែខាងជើង ។ នៅពេលប្រជាជនជួបគ្នាហើយ កម្មាភិបាលម្នាក់បានឡើងខទ្ទេសនាមអំពីមាគ៌ាដ៏ត្រឹមត្រូវរបស់អង្គការដែលបានរំដោះប្រជាជនទូទាំងប្រទេសពីចក្រពត្តិនិយមអាមេរិកាំង និងបរិវាររវា ។ បន្ទាប់ពីបទខទ្ទេសនាមរបស់កម្មាភិបាលម្នាក់នោះចប់ហើយ ស្រាប់តែប្រធាននារីរបស់សហករណ៍ឡើងចាប់អារម្មណ៍ ។ ប្រធាននារីនោះ ឈ្មោះមិត្ត យ៉េន ជាប្រពន្ធរបស់កម្មាភិបាលម្នាក់ឈ្មោះ ថន ។ កម្មាភិបាលទាំងពីរនាក់ប្តីប្រពន្ធនេះល្បីថា កាចណាស់ ។ គ្រប់តែប្រជាជនថ្មីដែលទើបតែជម្លៀសពីទីឆ្ងាយដែលពុំមែនជាប្រជាជននៅម្តុំនោះ ពួកវាតែងតាមដានជជីកសួររកឫសគល់ពីសម័យមុន ។ នៅពេលជួបមុខវាម្តងៗ វាសម្លឹងមើលមកយើងតាមខ្សែភ្នែកជាសត្រូវ វាសម្លឹងមើលរកអំពើខុសឆ្គងរបស់យើងដើម្បីរាយការណ៍ឲ្យថ្នាក់លើរបស់ពួកវា ។ វាពុំដែលនិយាយមករកយើងដែលមកពីទីក្រុងទេ ព្រោះគេចាត់ពួកយើងជាពួកបញ្ញើក្អែក ដែលពួកវាត្រូវកម្ទេចចោលនៅពេលក្រោយ ។ ពួកនេះហើយដែលហៅខ្ញុំឲ្យទៅព្យាបាលកូនរបស់វា ដែលមានជំងឺជាទម្ងន់ កាលពីខ្ញុំនិងគ្រួសារបានមកដល់ក្នុងភូមិទួលគពីដំបូងម៉្លេះ ស្រាប់តែកម្មាភិបាលនារីឈ្មោះ យ៉េន នេះបានសួររកវត្តមានរបស់ខ្ញុំក្នុងអង្គប្រជុំ ហើយនិយាយថា ខ្ញុំឮថាមិត្តឯងខឹងនឹងអង្គការដែលចាប់កូនមិត្តឯងច្រកបាវ តើពិតមែនឬ? ខ្ញុំឆ្លើយតបវិញថា ខ្ញុំឥតខឹងអ្វីនឹងអង្គការទេ ព្រោះអង្គការជាអ្នកមានគុណដែលបានរំដោះខ្ញុំពីចក្រពត្តិអាមេរិក និងបរិវាររវា ។ ប៉ុន្តែ ខ្ញុំអាណិតកូនខ្ញុំដែលគេយកទៅច្រកបាវរហូតដល់សន្លប់ ព្រោះខ្ញុំនៅមានកម្មសិទ្ធិសួនតួមិនទាន់អាចលះបង់បានតាមគំរូរបស់មិត្តនៅឡើយ ខ្ញុំសូមអស់យោបល់ត្រឹមនេះ ។ បន្ទាប់មក មិត្ត យ៉េន គំរាមខ្ញុំថា ខ្ញុំត្រូវសារភាពពីកំហុសឆ្គងរបស់ខ្ញុំដែលខឹងនឹងអង្គការ ព្រោះអង្គការសព្វថ្ងៃត្រូវការវែងយកអង្គរដើម ដើម្បីធ្វើបដិវត្តន៍សង្គមនិយម ។ ខ្ញុំឆ្លើយថា ខ្ញុំសារភាពរួចហើយពីអម្បាញ់មិញនេះ មិត្តឲ្យខ្ញុំសារភាពដូចម្តេចទៀត បើខ្ញុំអត់បានធ្វើអ្វីខុសនឹងអង្គការផង ។ មិត្ត យ៉េន ឆ្លើយបកមកខ្ញុំវិញថា ត្រង់

នេះហើយ ដែលថា មិត្តឯងមិនត្រង់នឹងអង្គការ ព្រោះមិនបាន សារភាពឲ្យអស់ អង្គការសព្វថ្ងៃខ្លាំង ទើបអាចធ្វើបដិវត្តន៍សង្គមនិយមបាន ។ ខ្ញុំអង្គុយនៅស្ងៀម ។ មិត្ត យ៉េន គំរាមខ្ញុំឲ្យខ្ញុំត្រូវតែឡើងសារភាពម្តងទៀតដោយស្មោះស ហើយច្បាស់លាស់ជាងមុន ។ ខ្ញុំនៅតែអង្គុយនៅស្ងៀមដដែល ។ មិត្ត យ៉េន និយាយបង្ខំខ្ញុំម្តងហើយម្តងទៀតឲ្យខ្ញុំសារភាព ។ ដោយឃើញខ្ញុំនៅស្ងៀម តាគោ ដាស់តឿនខ្ញុំឲ្យឡើងសារភាព ដោយពោលពាក្យថា អង្គការសព្វថ្ងៃនេះខ្លាំងណាស់លោកគ្រូ លោកគ្រូ ត្រូវតែឡើងសារភាពទៅ ។ នៅពេលតា គោ និយាយចប់ភ្លាម មិត្ត យ៉េន សួររកមុខថា នរណាថាអង្គការខ្លាំងអម្បាញ់មិញនេះ? ឥតមានចម្លើយ ។ អង្គប្រជុំទាំងមូលស្ថិតក្នុងសភាពស្ងប់ស្ងាត់គួរឲ្យព្រឺក្បាល ទើបមិត្ត យ៉េន ប្រកាសរំសាយអង្គប្រជុំ ។ តា គោ ត្រូវបានគេហៅគាត់ទៅទាំងយប់ ហើយបាត់ដំណឹងឈឹងរហូតមក ។ ខ្លួនខ្ញុំពោរពេញទៅដោយកំហឹង កំហឹងចំពោះការរំលោភសិទ្ធិដ៏ព្រៃផ្សៃមកលើកូនខ្ញុំ ។ កម្មសិទ្ធិអ្វីៗខ្ញុំលះបង់អស់ហើយ តាំងពីកិត្តិយស ទ្រព្យសម្បត្តិ មុខនាទីក្នុងសង្គម រហូតដល់សិទ្ធិសេរីភាព នៅឡើយតែមនោសញ្ចេតនាចំពោះប្រពន្ធកូនតែប៉ុណ្ណោះដែលខ្ញុំពុំអាចលះបង់បានឡើយ ។ ខួរក្បាលរបស់ខ្ញុំវិលវល់គ្មានដំណោះស្រាយ ។ ចិត្តមួយថា ត្រូវតែសងសឹកដោយហិង្សា ចិត្តមួយទៀតគិតឃើញដល់គ្រោះថ្នាក់ដែលនឹងធ្លាក់មកលើគ្រួសារខ្ញុំ និងអ្នកដទៃ ។ ចិត្តចុងក្រោយ គឺជាចិត្តភ្ញាក់រឭកថា ត្រូវតែរត់ទៅតស៊ូ រត់ទៅតស៊ូពីព្រៃមកវិញ ពីព្រោះជាឱកាសដែលត្រូវតែរត់ទៅតស៊ូកម្ចាត់ពួកអបលក្ខណ៍នេះឲ្យបានក្នុងនាមជាពលរដ្ឋស្នេហាជាតិទៅតាមបណ្តាំដ៏ឧត្តមថ្លៃថ្លាបំផុតរបស់ឪពុកខ្ញុំ ។ យប់នោះ ខ្ញុំបិទភ្នែកមិនជិតសោះ ។ កង្វល់អំពីផែនការរត់ចេញពីសហករណ៍ អំពីគ្រោះថ្នាក់ដែលអាចមានចំពោះខ្លួន ចំពោះប្រពន្ធកូន និងញាតិមិត្ត ។ ខ្ញុំត្រូវតែហ៊ានធ្វើការសម្រេចចិត្តមួយដ៏ម៉ឺងម៉ាត់បំផុត បើពុំនោះសោតទេ ខ្ញុំនឹងទៅជាមនុស្សកំសាក ជាកូនអកតញ្ញូ ។ គុណវិបត្តិទាំងពីរម៉ាត់នេះដែលខ្ញុំចៀសវាង ព្រោះធ្វើឲ្យមនុស្សបាត់បង់មនុស្សភាព សេចក្តីថ្លៃថ្នូរ ភាពខែងរ៉ែងជាមនុស្ស ពុំគួរឲ្យមាននៅក្នុងជីវិតឡើយ ។ ស្អែកឡើង ខ្ញុំក្រោកទៅចម្ការពីព្រលឹមជាងសព្វដង ដើម្បីទៅយកអង្ករជារបបរបស់ខ្ញុំឲ្យបានច្រើន ព្រោះយុវនារីដែលកាន់ក្តាប់អង្ករនៅមន្ទីរពេទ្យច្រើនដំអក់ក្នុងដំណេកក្នុងពេលព្រលឹមស្រាង ។ នៅពេលថ្មើរនោះ បើខ្ញុំទៅបើកអង្ករ ប្រាកដជាមិត្តនារីនោះឲ្យទៅកើបអង្ករយកដោយខ្លួនឯង ខ្ញុំនឹងកើបយកឲ្យបានទ្វេដង ។ ទៅដល់ចម្ការ ខ្ញុំយកអង្ករនោះទៅដាំបាយ ហើយចាក់ហាលថ្ងៃឲ្យក្រៀម ដោយប្រយ័ត្នប្រយែងបំផុត ។ ខ្ញុំប្រព្រឹត្តរបៀបនេះចំនួនបីថ្ងៃជាប់គ្នា ខ្ញុំបានបាយក្រៀមមួយថង់ ។ ខ្ញុំគិតថា បាយក្រៀមមួយកូនថង់នោះ ល្មមអាចបរិភោគសម្រន់ពោះបាន នៅពេលរត់ភៀសខ្លួន ។ ខ្ញុំយកថ្នាំជក់ដែលខ្ញុំលាក់ទុកឲ្យទៅជាងដែក ដើម្បីឲ្យគាត់ធ្វើកាំបិតផ្គាក់មួយដ៏ល្អឲ្យខ្ញុំដោយប្រាប់គាត់ថា ខ្ញុំត្រូវទៅឆ្ការព្រៃ ។ ដូចបំណងរបស់ខ្ញុំមែន ពីរថ្ងៃក្រោយមកជាងដែកស្រែកហៅខ្ញុំឲ្យចូលទៅយកកាំបិតផ្គាក់ដ៏មុតមួយ ។ ខ្ញុំយកកាំបិតនោះទៅសម្ងៀងរហូតដល់កោរពុកមាត់ដាច់ ។ កាំបិតនេះហើយជាគ្រឿងការពារ និងប្រើប្រាស់នៅពេលគេចខ្លួន ។ ខ្ញុំរៀបប្រដាប់ប្រដារសម្រាប់ធ្វើដំណើរមានធាតុរបស់ឪពុកខ្ញុំ ចិញ្ចៀនត្បូងកណ្តៀងមួយវង់ដែលមិត្តខ្ញុំម្នាក់ឈ្មោះ តាំង ស្រេង ឲ្យខ្ញុំកាលនៅបប៉ៃលិនក្នុងឆ្នាំ១៩៧៣ កាំបិតផ្គាក់ ដែកកេះ កាទឹក ព្រះពុទ្ធបដិមាមួយអង្គធ្វើអំពីថ្មនាងពួន ខ្សែបង្កេះ និងកន្សែងយ័ន្តដ៏ស័ក្តិសិទ្ធិដែលជាព្រះកេរ របស់ព្រះចៅ អធិការវត្តភ្នំត្នាក ។ នៅមានបាយក្រៀមមួយថង់ និងថ្នាំជក់មួយដុំទៀត ។ ប្រដាប់ប្រដារសម្រាប់រត់ភៀសខ្លួនត្រៀមរួចរាល់ហើយ ។

បន្ទាប់ពីការប្រជុំដ៏តឹងតែងរបស់មិត្តនារី យ៉េន មក មនុស្សម្នាក់ៗ នៅក្នុងសហករណ៍ ជាពិសេសរូបខ្ញុំហាក់មានសម្ពាធដ៏ធ្ងន់ធ្លាក់មកលើ ។ ម្នាក់ៗរក្សាភាពស្ងប់ស្ងៀម ស្រពាប់ស្រពោន ហាក់ដូចជារង់ចាំការវែងយកអង្ករដើមរបស់អង្គការ ដែលមិត្តនារី យ៉េន លើកឡើងក្នុងអង្គប្រជុំ ។

នៅពេលរសៀលស្ងាត់ ខ្ញុំតែងតែឡើងលើដើមអំពិលរហូតដល់ចុង បើកភ្នែកសម្លឹងទៅទិសខាងលិច ឃើញស្រមោលភ្នំស្ទើររលុបបាត់ក្នុងជើងមេឃ ។ ភ្នំនោះហើយដែលខ្ញុំសន្មតថា ជាភ្នំម៉ាឡៃមូលដ្ឋានទ័ពសេរីកា ។ ខ្ញុំនឹកក្នុងចិត្តថា មិនប៉ុន្មានថ្ងៃទៀតទេ ខ្ញុំនឹងទៅដល់ទីនោះ ខ្ញុំមុខជានឹងជួបមិត្តភក្តិចាស់ៗរបស់ខ្ញុំ ដែលជាអតីតមេប៉ូលីសនៅប៉ោយប៉ែត ខ្ញុំនឹងវិលមកសហករណ៍នេះវិញ ដោយដៃមានកាន់កាំភ្លើងស្វ័យប្រវត្តិដ៏អស្ចារ្យ ហើយកម្ទេចខ្មាំងរំដោះប្រជាជនឲ្យផុតពីក្រញាំមច្ចុរាជខ្មែរក្រហមឲ្យបាន ។ ខ្ញុំនឹងទៅជាវីរបុរសដែល

ប្រជាជនទូទាំងប្រទេសគោរពរាប់អានខ្ញុំ ។ ក្តីស្រមើស្រមៃរបស់ខ្ញុំដ៏វែងអន្លាយប្រៀបបាននឹងយល់សប្តិនេះ ជាបាតុភាពនៃអារម្មណ៍ទាល់ច្រក អារម្មណ៍នៃកំហឹង អារម្មណ៍សងសឹក ។ ខ្ញុំកំពុងលង់នៅក្នុងអារម្មណ៍រវើរវាយ នឹកដល់វាសនារបស់ប្រពន្ធកូនខ្ញុំនៅពេលដែលខ្ញុំចាកចេញចោលទៅ តើខ្មែរក្រហមធ្វើទុក្ខបុកម្នេញដល់រូបគេយ៉ាងណាទៅ? តើខ្ញុំមករំដោះពួកគេបានទាន់ពេលឬទេ? គ្រាន់តែរឿង តា គោ ដែលគាត់គ្មានកំហុសទាល់តែសោះ គាត់គ្រាន់តែបានបន្ទឺពាក្យដាស់តឿនខ្ញុំពីរបីម៉ាត់ឲ្យខ្ញុំទទួលសារភាពកំហុសដែលខ្ញុំពុំបានធ្វើនោះ ក៏ត្រូវខ្មែរក្រហមនាំយករូបគាត់ទៅបាត់ ។ ចុះរូបខ្ញុំវិញ ដែលជាអតីតអ្នករដ្ឋការលន់ នល់ មានវណ្ណៈអនុធន ជាមនុស្សរបឹងទៀត តើអង្គការទុកជីវិតឲ្យឬទេ? បើគង់តែស្លាប់ដដែល ម្តេចក៏ខ្ញុំមិនក្រោកឡើងតស៊ូ វាប្រសើរជាងការឱបដៃរង់ចាំសេចក្តីស្លាប់ដូចអ្នកដទៃក្នុងកាលកន្លងមក ។ គិតទៅគិតមក ដំណោះស្រាយដ៏ល្អបំផុត គឺរត់ ។

## ដំណើររត់ភៀសខ្លួន

ពីរថ្ងៃក្រោយមក ខ្ញុំនៅលើដើមអំពិលដូចសព្វដង នៅពេលទំនេរពីការងារ ខណៈភ្នែករបស់ខ្ញុំមើលទៅទិសសហករណ៍ឃើញមនុស្សម្នាក់ដើរមកពីចម្ងាយសំដៅមកចម្ការដែលខ្ញុំធ្វើការ គឺមិត្តឡាយ ។ គាត់ជាមិត្តជិតដិតរបស់ខ្ញុំ យើងស្គាល់ចិត្តគ្នាល្មមឲ្យទុកចិត្តបាន ។ ខ្ញុំក៏ចុះពីដើមអំពិលមកដីចាំទទួលមិត្តឡាយ ។ គាត់មានអាកប្បកិរិយាត្រហេបត្រហប ។ ខ្ញុំជជីកសួរគាត់ថា មានរឿងអ្វីកើតឡើង ។ គាត់រៀបរាប់យ៉ាងរន្ធត់អំពីរឿងរ៉ាវដែលអ្នកធ្វើការជាមួយគ្នាក្នុងផ្ទះបាយក្រុមអូរប្រគាប ចោទប្រកាន់គាត់អំពីសីលធម៌ជាមួយមិត្តនារីម្នាក់នៅភូមិស្នួលកោង ។ រឿងនេះធ្ងន់ធ្ងរណាស់ ។ បើអង្គការជឿលើការចោទប្រកាន់នេះ អង្គការអាចប្រហារជីវិតគាត់ជាបន្ទាន់ ។ គាត់បារម្ភថា នៅយប់នោះអង្គការនឹងយកគាត់ទៅកាត់ទោសហើយ ។ គាត់បានសម្រេចចិត្តរួចហើយ ថាគាត់នឹងរត់ចេញពីសហករណ៍នៅព្រលប់ថ្ងៃនេះ ។ គាត់អង្វរដោយទឹកភ្នែកសស្រាក់ឲ្យខ្ញុំធ្វើដំណើរទៅជាមួយគាត់ ពីព្រោះគាត់ពុំអាចរត់ទៅតែឯងបានឡើយ ដោយគាត់មានចរិតជាអ្នកខ្លាចច្រើន ។ ខ្ញុំនឹកក្នុងចិត្តថា ចុះហេតុអ្វីបានជាមានរឿងជាន់គ្នាដូច្នេះ ព្រោះខ្ញុំបានសម្រេចចិត្តថា នឹងរត់ចេញពីសហករណ៍នៅថ្ងៃស្អែក គឺថ្ងៃ១៣រោច ខែចេត្រ ស្រាប់តែហ៊ា ឡាយ មកបបួលខ្ញុំឲ្យរត់ទៅជាមួយគាត់នៅល្ងាចនេះ ។ ដោយខ្ញុំមានជំនឿលើក្បួនហោរា តាមក្បួនឃើញថា បើចេញដំណើរនៅល្ងាចនេះ ពុំសូវល្អទេ នឹងជួបឧបសគ្គជាមួយពួកអមនុស្ស ។ បើចេញដំណើរនៅថ្ងៃស្អែក នឹងត្រូវចំពេលល្អ ។ ហ៊ា ឡាយ គាត់ទទូចថា ត្រូវតែចេញដំណើរនៅល្ងាចនេះ ។ ហ៊ា ឡាយ គាត់ទទូចថា ត្រូវតែចេញដំណើរនៅល្ងាចនេះ ។ គាត់ជឿថា ជាថ្ងៃល្អ ជាថ្ងៃ១២រោច ខែចេត្រ ឆ្នាំម្សាញ់ ត្រូវនឹងថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៧៨ ពីព្រោះកាលពីយប់មិញ គាត់យល់សុបិន្តឃើញសត្វគោ ។ ខ្ញុំរក្សាភាពស្ងប់ស្ងៀម មិនពិភាក្សាច្រើនជាមួយគាត់ទេ ។ នៅពេលនោះ ការសម្ងាត់អ្វីៗ ត្រូវប្រុងប្រយ័ត្នជាទីបំផុត ។ ក្នុងចិត្តខ្ញុំ ខ្ញុំសម្រេចថា នឹងរត់ភៀសខ្លួនជាមួយហ៊ា ឡាយ នៅល្ងាចនេះវិញ បើបង្អង់មួយម៉ួយថ្ងៃទៀត ខ្លាចបែកការណ៍ ។ ខ្ញុំផ្តែផ្តាំហ៊ា ឡាយ ឲ្យទៅរោងបាយដែលគាត់ធ្វើការសិនទៅ ហាមមិនឲ្យទៅផ្ទះលាប្រពន្ធកូនជាដាច់ខាត ។ ម៉ោង៦ល្ងាច យើងជួបគ្នានៅក្នុងរណ្តៅប្រាសាទគោកប្រដាក ។ យើងបែកគ្នាត្រឹមនេះសិន ចាំជួបគ្នាតាមពេលណាត់ ។ ហ៊ា ឡាយ ចេញពីចម្ការខ្ញុំបាត់ទៅ ចំណែកខ្ញុំក៏ធ្វើដំណើរទៅផ្ទះពុក គឹម ដែរ ។ ពុកគឹម ជាជនជាតិខ្មែរម្នាក់មានប្រពន្ធជាជនជាតិលាវ ។ ខ្ញុំហៅគាត់ថា ពុក ព្រោះជាទម្លាប់ហៅមនុស្សចាស់ ក្រោមរបបខ្មែរក្រហម ។ ហៅស្ត្រីចាស់ថា ម៉ែ ។ កាលពីមុនសម័យបដិវត្តន៍ គាត់ប្រកបរបរថ្មើរព្រៃក្នុងនាមដូនសំ ។ ពុក គឹម ជាមនុស្សចាស់ម្នាក់គួររាប់អានជាមនុស្សស្មោះ មានចិត្តទូលាយមិនចូលចិត្តមុខមាត់ក្នុងសង្គម ។ ខ្ញុំទុកគាត់ជាញាតិម្នាក់នៅក្នុងសហករណ៍ ។ ខ្ញុំទៅដល់ផ្ទះពុក គឹម ខ្ញុំឃើញគាត់នៅម្នាក់ឯង ខ្ញុំចាប់ផ្តើមសារភាពប្រាប់គាត់ថា ខ្ញុំនឹងរត់ភៀសខ្លួននៅពេលវេលាល្ងាចនេះហើយ ។ ខ្ញុំមកជួបគាត់នៅពេលនេះ ដើម្បីមកលាជង និងមកសុំត្រីវិស័យពីគាត់ ព្រោះពីអតីតកាលគាត់ជាអ្នកថ្មើរព្រៃពិតជាមានត្រីវិស័យជាក់ជាពុំខាន ។ គាត់ឆ្លើយថា ចាំកូនគាត់ឈ្មោះ ចន្ធី មកពីធ្វើពលកម្មសិន ព្រោះកូនគាត់ម្នាក់នេះ ជាអ្នកយកត្រីវិស័យរបស់គាត់ទៅកប់ទុក ។ រំពេចនោះ ចន្ធី ក៏មកដល់ ។ ពុក គឹម ខ្សឹបប្រាប់ ចន្ធី ឲ្យទៅគាស់យកត្រីវិស័យមកឲ្យខ្ញុំ ។ ចន្ធី ចេញទៅក្រោយផ្ទះមួយភ្លែត ក៏បានយកត្រីវិស័យ នៅក្នុងដៃមកហុចឲ្យខ្ញុំ ដោយទឹកភ្នែករលីងរលោងជាមួយនឹងពាក្យផ្តាំផ្ញើមកកាន់ខ្ញុំថា បង! សូមឲ្យបងសម្រេចតាមបំណងរបស់នេះជារបស់

បងហើយ បើបងជួបហេតុការណ៍មិនល្អ សូមបងកុំឆ្លើយថា បានរបស់នេះពីខ្ញុំ ។ ខ្ញុំងក់ក្បាលជាសញ្ញាថា នឹងរក្សាការសម្ងាត់នេះ ហើយខ្ញុំចាប់ដៃនាងលាគ្នាដោយអាល័យបំផុត ។ ខ្ញុំចេញពីផ្ទះពុក គឹម សំដៅត្រង់មកផ្ទះខ្ញុំដែលនៅមិនឆ្ងាយពីគ្នា ។ ផ្ទះកម្សត់របស់ខ្ញុំដែលធ្វើដោយផ្ទាល់ដៃ ។ ខ្ទមដែលមានដំបូល និងក្តារក្រាល ប៉ុន្តែគ្មានជញ្ជាំង ។ ខ្ញុំយកសម្បកបាវក្រចៅចាស់ៗមកដេរភ្ជាប់ធ្វើរនាំងព័ទ្ធជុំវិញខ្ទម ។ ដេរបាវធ្វើជាជញ្ជាំងខ្ទមមានប្រយោជន៍ត្រង់ យើងនៅក្នុងខ្ទមមើលទៅក្រៅឃើញអ្វីៗទាំងអស់ ។ អ្នកខាងក្រៅមើលមកក្នុងមិនឃើញឡើយ ។ ខ្ញុំដើររកក្តារតាមផ្ទះចាស់ៗក្នុងភូមិដែលគេបោះបង់ចោលបន្តិចម្តងៗ រហូតបានក្រាលពេញខ្ទមរបស់ខ្ញុំដែលមានទំហំប្រមាណ៤ម៉ែត្រ៤ជ្រុង ។ ក្តារក្រាលលើកផុតពីដីប្រមាណ៧តឹក ។ ពេលកងឈ្លបចង់ចូលមកលួចស្តាប់ការណ៍នៅក្រោមផ្ទះរបស់ខ្ញុំពិតជាពុំងាយស្រួលឡើយ ។

មកដល់ខ្ទមខ្ញុំ ជាពេលស្ងាត់ជ្រងំនាំឲ្យខ្ញុំមានអារម្មណ៍ស្រងេះស្រងោចនឹកថា ចាប់ពីល្ងាចនេះទៅ ខ្ញុំទៅចោលអ្នកជាស្ថាពរហើយ ។ ខ្ញុំឡើងលើក្តារក្រាលមើលអីវ៉ាន់ដែលខ្ញុំត្រូវយកទៅតាមខ្លួន និងទុកអ្វីខ្លះឲ្យប្រពន្ធកូន ។ ឃើញសព្វគ្រប់ហើយ ខ្ញុំលើកកូនបង្កើចទុកនៅកន្លែងដដែលវិញ ហើយដើរទៅរកធុងទឹកនៅការដ្ឋាន ដើម្បីរែកទឹកដាក់ឲ្យពេញពាង ។ ការងាររួចរាល់ហើយ ក៏ស្រាប់តែឃើញពុក គឹម ដើរមករកខ្ញុំ ។ គាត់និយាយតិចៗប្រាប់ខ្ញុំថា គាត់ពុំគួរបណ្តោយឲ្យខ្ញុំធ្វើដំណើរកាត់ព្រៃដែលខ្ញុំពុំដែលស្គាល់សោះតែម្នាក់ឯងឡើយ ។ គាត់ត្រូវតែជូនខ្ញុំទៅ ព្រោះគាត់ចាស់ហើយអស់មានបន្ទុកអ្វីទៀត ហើយត្រូវតែជូនខ្ញុំទៅព្រៃដើម្បីតស៊ូ ទោះគាត់ត្រូវស្លាប់ក៏អត់មានអ្វីត្រូវស្តាយដែរ ។ ខ្ញុំលើកដៃប្រណម្យឱនសំពះគាត់ដោយសេចក្តីត្រេកអរ ។ នៅប្រមាណតែជាងមួយម៉ោងទៀត យើងត្រូវទៅកន្លែងណាត់ជាមួយហ៊ា ឡាយ ហើយចេញដំណើរតែម្តង ។ ពុក គឹម ត្រឡប់ទៅផ្ទះគាត់វិញ ។ ខ្ញុំដើរសំដៅទៅរោងគោទៅទទួលយកកូនសម្លាញ់របស់ខ្ញុំ តូចៗទាំងពីរនាក់ គឺ វលី និងចាទី ដែលផ្ញើទុកនឹងយាយៗមកផ្ទះវិញ ។ ខ្ញុំបាននិយាយផ្តាំនឹងយាយៗថា ឲ្យអាណិតកូនខ្ញុំទាំងពីរនេះផង ហើយខ្ញុំថ្លែងអំណរគុណដល់គាត់មុននឹងលាគាត់មកផ្ទះជាមួយកូនវិញ ។ បន្តិចទៀត ម្តាយរបស់វានឹងមកដល់ដែរ ក្រោយពីបំពេញការងារនៅរោងធ្វើអង្ករ ។ ខ្ញុំឆ្លៀតជួបកូនៗទាំងពីរជាលើកចុងក្រោយ ។ ខ្ញុំយកកូនទាំងពីរទៅងូតទឹក ហើយស្លៀកពាក់ឲ្យវិញដោយផ្តាំឲ្យ ចាទី មើលប្អូន វលី ទម្រាំម្តាយមកដល់ ។ ខ្ញុំក៏រូតរះលាកូនទៅដោយក្តុកក្តួលស្ទើរដកដង្ហើមមិនរួច ។ អាណិតស្រណោះកូននៅតូចៗ ដល់កូនធំទៅ មុខជាគ្មានអ្នកអប់រំ តើកូនៗនឹងទៅជាយ៉ាងណាក្នុងពេលអនាគត? ខ្ញុំត្រូវចាកចេញទៅឲ្យបានមុនភរិយាខ្ញុំមកដល់ដើម្បីចៀសវាងពីភាពសោកសៅរបស់ខ្ញុំនៅចំពោះមុខគាត់ ។

ខ្ញុំទៅដល់ប្រាសាទគោកប្រដាកមុនសហសេវិករបស់ខ្ញុំទាំងពីរនាក់បន្តិច ។ ខ្ញុំចុះទៅបាតរណ្តៅ ដើម្បីរៀបចំប្រដាប់ប្រដារខ្ញុំជាថ្មីឡើងវិញដោយមូរនឹងក្រមា ហើយយកទៅក្រវាត់ចង្កេះឲ្យជាប់បង្ការក្រែងជ្រុះបាត់នៅពេលរត់ក្នុងគ្រាអាសន្ន ។ រួចរាល់ហើយ ខ្ញុំយកកំណាត់ដើមទន្ទ្រានខែត្រងាប់មកជំនួសធូបបីសរសៃ ខ្ញុំលើកដៃសំពះសំបូងសង្រួងដល់គុណព្រះរតនត្រ័យ បារមីថែរក្សាប្រាសាទគោកប្រដាក គុណឪពុកម្តាយ សូមឲ្យលោកជួយគាំពាររក្សាយើងខ្ញុំឲ្យបានទៅដល់គោលដៅដូចសេចក្តីប្រាថ្នា ដើម្បីបានវិលត្រឡប់មករំដោះជាតិ និងសាសនាឲ្យរួចផុតពីកណ្តាប់ដៃនៃពួកអន្យតិរ្ថិយព្រៃផ្សៃវិញ ។ បើខ្ញុំគ្មានសំណាងបានវិលមករំដោះជាតិវិញទេ សូមឲ្យស្លាប់ក្នុងព្រៃនេះពេលរត់ចុះ ។

ចិត្តរបស់ខ្ញុំនៅពេលនោះពោរពេញដោយសេចក្តីឈឺចាប់ ឈឺចាប់ ព្រោះគ្មានសេរីភាព គ្មានសង្ឃឹមលើជាតិ គ្មានសង្ឃឹមលើអន្តរជាតិ ស្តាយខ្លួនមិនរត់ចោលស្រុកតាំងពីដំបូង ព្រោះតែគំនិតជាតិនិយមជ្រុលរបស់ខ្ញុំ ។

ក្រោយពីធ្វើការសំបូងសង្រួង និងទុកដាក់ប្រដាប់ប្រដាររួចរាល់ហើយ ខ្ញុំឡើងពីរណ្តៅមកជួប ពុក គឹម ហ៊ា ឡាយ ដែលរង់ចាំខ្ញុំនៅមាត់រណ្តៅប្រាសាទយ៉ាងអន្ទះសារ ។ ដល់ពេលព្រលប់ល្មម យើងចេញដំណើរសំដៅទៅទិសខាងលិច ។ ខ្ញុំ និងហ៊ា ឡាយ ទុកឲ្យពុក គឹម នាំផ្លូវ ។ ខ្ញុំដើរផងខ្ញុំស្ទាបរកពុទ្ធបដិមា ដែលមូរនឹងក្រមាក្រវាត់ចង្កេះ ដើម្បីបន់ស្រន់ឲ្យដំណើររបស់ពួកយើងប្រព្រឹត្តទៅដោយរលូន កុំឲ្យមានឧបសគ្គតាមផ្លូវឲ្យសោះ ប៉ុន្តែស្ទាបរកពុំឃើញពុទ្ធបដិមា ។ ខ្ញុំសន្និដ្ឋានថា ខ្ញុំភ្លេចព្រះនៅក្នុងរណ្តៅប្រាសាទគោកប្រដាកបាត់ទៅហើយ ឬព្រះពុំសព្វព្រះទ័យយាងតាមខ្ញុំក្នុងដំណើរភៀសខ្លួននេះ? មេឃកាន់តែងងឹតស្លុងមើលផ្លូវពុំឃើញអ្វីទាំងអស់ ។ យើងដើរព្រាវៗ លើកជើងឲ្យខ្ពស់ ចៀសវាងជំពប់ ។ ប្រមាណពីរម៉ោង

ក្រោយមក យើងហាក់ដូចជាដឹងថា យើងដើរកាត់ភូមិមួយ ។ ខ្ញុំខ្សឹបសួរពុក គឹម ថា យើងមកដល់ទីណាហើយ? គាត់ឆ្លើយថា ប្រហែលជាភូមិផ្លូវដីរនៅជិតភូមិល្វា ។ មួយភ្លែតក្រោយមក ពុក គឹម ដើរទៅដល់ជញ្ជាំងមួយឮសូរប្រាវ ។ គាត់ស្ទុះបកមកក្រោយវិញ មកប៉ះយើងទាំងពីរនាក់អូសដៃគ្នារត់ ។ ពេលនោះ ខ្ញុំឮសូរសំឡេងស្រែកសួរពីក្នុងខ្ទមថា នរណាគេហ្នឹង? យើងឥតឆ្លើយព្រោះតែស្លន់ ហើយអូសដៃគ្នា គេចឲ្យឆ្ងាយតាមដែលអាចធ្វើទៅបាន ។ មួយសន្ទុះក្រោយមកទៀត សំឡេងជួងប្រកាសអាសន្នលាន់ឮឥតឈប់ ។ ភ្លើងចន្ទុះព្រោងព្រាត់រត់សំដៅមករកយើង ។ សហសេវិករបស់ខ្ញុំទាំងពីរនាក់ច្រួលច្របល់ភ័យស្លន់ស្លោ ។ ខ្ញុំឃើញសភាពការណ៍មិនស្រួល ខ្ញុំនិយាយប្រាប់គាត់ថា បូលពុក និងហ៊ា កុំភ័យ មកឈរពីក្រោយខ្ញុំមក ខ្ញុំនឹងសូត្រគាថាបំបាំងខ្លួន ។ ដូចចិត្តខ្ញុំមែន គាត់ស្ទុះមកឈរពីក្រោយខ្ញុំ កាំបិតដាក់ផ្ទុប់ និងជើងក្រែងមានចំណាំងផ្លាតនៅពេលមានពន្លឺភ្លើងមកជិត ។ យើងស្ថិតនៅក្រោមដើមរាំងមួយដើមធំ ។ ខ្ញុំចាប់ផ្តើមសូត្រធម៌ឮខ្លះ មិនឮខ្លះ ព្រោះខ្ញុំចាំធម៌ព័ទ្ធសីមាពុំសូវច្បាស់ ។ យ៉ាងណាក៏ដោយ ខ្ញុំត្រូវតែសូត្រធម៌ដើម្បីឲ្យពុក គឹម និងហ៊ា ឡាយទុកចិត្តខ្ញុំ បើពុំនោះសោតទេ គាត់គិតតែពីរត់ឆ្វេឆ្វានាំឲ្យគេឃើញស្រមោលរបស់គាត់បានយ៉ាងងាយ ។ «ខមស្មឹរាជសីមាយំខេត្តេ សមន្តាមន្តីយោជនៈ សត្តសហ ស្សាមិ ពុទ្ធា ធម្មា សង្ឃាជាលបរខេត្តេ រខន្តុ សុរខន្តុ» សូត្ររួចមួយមេហើយ ថែមមួយមេទៀតថា «មអករណីជើងខ្ញុំ ឈ្មោះ អេង ជាន់ដីខមសិទ្ធីស្វាហៈ» សូត្រផងយកមេជើងចុចដីទាត់ទៅគ្រប់ទិស ។ ត្រង់នេះ ខ្ញុំសូមលោកអ្នកបេះដឹងធម៌អាថ៌ទាំងនេះ មេត្តាខន្តីអភ័យទោសដល់ខ្ញុំ ក្រែងធម៌ដែលខ្ញុំសរសេរនេះ ពុំត្រឹមត្រូវ ប៉ុន្តែ ធម៌នេះហើយ ដែលខ្ញុំបានសូត្រការពារខ្លួននៅពេលនោះ ។ នៅពេលដែលយើងជួបគ្រាអាសន្នទាល់ច្រកជួ មិនដឹងបានអ៊ីធ្វើជាទីពឹង ក៏នឹកឃើញសូត្រព្រះបាលីដែលយើងនៅចាំ បើមិនមានប្រសិទ្ធភាពក៏ជាគ្រឿងកម្លាចិត្តមិនឲ្យស្លន់ស្លោខូចការណ៍ដែរ ។ ខ្ញុំតាំងចិត្តរួចហើយថា បើខ្មាំងរត់មកដល់យើងនឹងប្រហារវាដោយកាំបិតដ៏មុតរបស់យើង យើងពុំឲ្យវាចាប់យើងបានជាដាច់ខាត ។ សំណាងល្អរបស់យើង ភ្លើងចន្ទុះទាំងប៉ុន្មានរត់ហួសពីយើងមិនបានមកជិតយើងឡើយ ។ មួយសន្ទុះមកទៀត ឮសំឡេងឆ្កែព្រូសបីបួនក្បាលរត់សំដៅមកទីលាក់ខ្លួនរបស់យើងទៀត ។ ខ្ញុំនឹកស្តាយថា មិនបានរៀនបាលីចងមាត់ឆ្កែ ។ បាលីនេះ ខ្ញុំធ្លាប់ឃើញក្នុងសៀវភៅមួយរបស់លោកគ្រូខ្ញុំ ។ ឆ្កែទាំងនោះ ក៏ពុំបានមកដល់យើង វារត់ទៅតាមអ្នកកាន់ចន្ទុះដែលនៅពីមុខវា ។ យើងទាំងបីនាក់បានស្រាកស្រាន្តក្នុងទ្រូងហើយ ។ យើងស្រូតរូតចេញដំណើរពីក្រោមដើមរាំងឆ្ពោះទៅទិសខាងលិចតទៅទៀត ។ បានចម្ងាយប្រមាណហាសិបម៉ែត្រ យើងដើរពានទៅលើមនុស្សដេកបីបួននាក់នៅកណ្តាលវាល ។ អ្នកដេកស្រែកថា «អាណាដើរជាន់អញ» ខ្ញុំឆ្លើយវិញថា «អត់ទោស ខ្ញុំមើលមិនឃើញ» ។ ពួកយើងខំស្រូតរូតទៅមុខទៀតទើបទៅដល់ស្ទឹង ។ ស្ទឹងមានទឹកពេញ ។ សំណាងល្អ ពួកយើងចេះហែលទឹកគ្រប់គ្នា ហើយមានកាទឹកជំនួយផង ។ ទៅដល់ត្រើយម្ខាង យើងដាក់ទឹកបំពេញកា ហើយចេញដំណើរទៅទៀត ក្នុងសភាពងងឹតសូន្យសុង ។ ការហេវហត់របស់ខ្ញុំ បន្ទាប់ពីបានត្រូវទឹកត្រជាក់សព្វសារពាង្គកាយ ក៏ព្រឺសចិត្តជាថ្មី ។ យើងដើរបានបន្តិចក៏ទៅដល់ដីអាចម៍បំណះធំៗ ។ ដីដែលគេទើបនឹងភ្ជួរដោយត្រាក់ទ័រ ។ យើងខំប្រឹងដើរកាត់ដីអាចម៍បំណះដោយលំបាក ព្រោះជំហាននីមួយៗធ្វើឲ្យជើងយើងផុងកប់ទៅក្នុងដី ។ ខ្ញុំចាប់ផ្តើមរោយជើងរោយស្មឹងត្រគាក ពុំអាចធ្វើដំណើរទៅបានលឿនឡើយ ។ យើងឃើញពន្លឺភ្លើងផ្ទុងៗឯនាយឆ្ងាយសន្ធឹម ។ ពន្លឺភ្លើងនោះពិតជាភ្លើងនៃពួកកងភ្ជួរត្រាក់ទ័រ ។ ពួកនោះធ្វើការទាំងយប់ឥតសម្រាក ។ ខ្ញុំនិយាយប្រាប់ពុក គឹម ថា ពុក! ខ្ញុំដើរលែងរួចហើយ សូមពុកសំដៅទៅរកព្រៃ ។ គាត់នាំយើងងាកទៅឆ្វេងដៃ គាត់ប្រាប់យើងថា សំដៅទៅដំណាក់ព្រះអង្គ ។ ដំណាក់ព្រះអង្គជាឈ្មោះរបស់ភូមិមួយនៅជិតអន្លង់សំណរ ។ ដល់ពេលទៀបភ្លឺ យើងឃើញស្រមោលព្រៃព្រាលៗពីមុខយើង ។ ខ្ញុំមានសេចក្តីសង្ឃឹមបន្តិច ព្រោះឃើញព្រៃ ។ ជើងខ្ញុំទាំងទ្វេលែងស្តាប់បញ្ជារបស់ខ្ញុំ ព្រោះសន្ទាក់ត្រគាកតាំងទាំងអស់ ។ ខ្ញុំហៅសហសេវិករបស់ខ្ញុំឲ្យជួយអូសខ្ញុំទៅព្រៃ ។ គាត់ទាំងពីរនាក់ក៏ហេវហត់ណាស់ដែរ ព្រោះយើងដើរដោយអស់ទំហឹងពេញមួយយប់ ។ នៅពេលគេដាក់ខ្ញុំចុះឲ្យដេកបានមួយសន្ទុះ ជើងរបស់ខ្ញុំក៏កម្រើកបានខ្លះឡើងវិញ ។ ពុក គឹម និងហ៊ា ឡាយ គ្រាហ៍ខ្ញុំចូលព្រៃ ។ ពន្លឺព្រះអាទិត្យព្រាងៗឯជើងមេឃ យើងចូលដល់ព្រៃល្ហម ។

**(តទៅលេខក្រោយ)**

**ជា សីហា**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៤ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោម៖**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 182, 2015 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.